# មាតិកា


សេចក្តីថ្លែងអំណរគុណ ------------------------------------------------------- v

អារម្ភកថា -----------------------------------------------------------------vi

ទស្សនៈអ្នកនិពន្ធ ---------------------------------------------------------- vii


## ជំពូកទី ១


I.និយមន័យ -------------------------------------------------------------១

II.គោលបំណងឃោសនា ----------------------------------------------------១

III. ដំណើរការឃោសនា ---------------------------------------------------៣

១-វិភាគឱកាស ---------------------------------------------------------៣

២-សិក្សាពតិមាន និងរៀបចំប្រព័ន្ធពតិមាន -------------------------------------៣

ក-ស្រាវជ្រាវពតិមាន -------------------------------------------------៣

ខ-វិធីសាស្ត្រប្រមូលពតិមាន-------------------------------------------- ៤

គ-តួនាទីរបស់ភ្នាក់ងារពតិមាន ---------------------------------------- ៤

៣-ភ្នាក់ងារចារកម្ម------------------------------------------------------ ៥

ក-ភ្នាក់ងារពតិមាន---------------------------------------------------៥

ខ-ភ្នាក់ងារតាមតំបន់ -----------------------------------------------៥

គ-ភ្នាក់ងារក្នុងជួរ----------------------------------------------------៦

ឃ-ភ្នាក់ងារស្ងួន-----------------------------------------------------៦

ង-ភ្នាក់ងារស្លាប់-----------------------------------------------------៦

ច-ភ្នាក់ងារពិសេស -------------------------------------------------៦

ឆ-កម្លាំងពិសេស ---------------------------------------------------៦

៤-បរិយាកាសនយោបាយ ----------------------------------------------៧

ក-គណបក្សនយោបាយ ----------------------------------------------៨

ខ-កាត់ទោសខ្មែរក្រហម ------------------------------------------ ១០

គ-ជម្លោះដីធ្លី ------------------------------------------------------ ១១

ឃ-អំពើពុករលួយ --------------------------------------------------១៣

៥-ទំនោរ និងនិន្នាការប្រជាពលរដ្ឋ ----------------------------------------១៤

៦-គោលដៅវាយលុក -----------------------------------------------------១៤

## ជំពូកទី ២

## ផែនការ

I.ការធ្វើគំរោង ------------------------------------------------------------១៦
១-កំណត់បញ្ហា ------------------------------------------------------១៦
២-ជ្រើសរើសប្រធានបទ ------------------------------------------------- ១៧
៣-ជ្រើសរើសគោលដៅឃោសនា -------------------------------------- ១៧
៤-យុទ្ធសាស្ត្រឃោសនាផ្សេងៗ -------------------------------------------១៨
ក-បង្ហាញគោលការណ៍ និងអង្គការនយោបាយ ---------------------------- ១៨
ខ-ទីកន្លែងឃោសនា និងឱកាស ------------------------------------- ១៩
គ-ប្រជាពលរដ្ឋ ----------------------------------------------------- ១៩
ឃ-ឃោសនិក ------------------------------------------------------- ២០
ង-រូបភាពខាងក្រៅ ----------------------------------------------២១
ច-តំលៃអង្គការនយោបាយ ------------------------------------------២១
ឆ-សកម្មភាព ពាក្យពេចន៍ និងអត្ថន័យឃោសនា ---------------------------២២
ជ-សកម្មភាពជួយរាល់ទុក្ខលំបាកប្រជាពលរដ្ឋ ------------------------------២២
ឈ-ទិន្នផលការងារ និង ស្នាដៃមេដឹកនាំ------------------------------២៣
ញ-ចំបញ្ហាប្រជាពលរដ្ឋ ---------------------------------------------២៣
ដ-ប្រតិកម្មភ្លាមៗ----------------------------------------------------- ២៤
៥-កម្មវិធីប្រតិបត្តិការ -------------------------------------------------២៤
៦-វិភាគលើលទ្ធផល ខាត ឬចំណេញ ---------------------------------------២៤
៧-ត្រួតពិនិត្យ ------------------------------------------------------២៥
II. គូរប្លង់យុទ្ធសាស្ត្រឃោសនា -----------------------------------------------២៥
III.យុទ្ធសាស្ត្រឃោសនាជាសាធារណៈ ------------------------------------------២៦
IV. គ្រប់គ្រងបណ្តាញ ---------------------------------------------------- ២៧

## រៀបចំ

I.រៀបចំរចនាសម្ព័ន្ធ------------------------------------------------------២៨
១-រៀបចំបែងចែកមុខងារ ----------------------------------------------២៨
២-រៀបចំតាមភូមិសាស្ត្រ-----------------------------------------------២៨

៣-រៀបចំការបែងចែក តាមប្រភេទប្រជាពលរដ្ឋ ----------------------------------២៨
II. ការរៀបចំបណ្ដាញ --------------------------------------------------២៨
១-រៀបចំគំរោងបណ្ដាញ ---------------------------------------------២៨
២-គោលដៅបណ្ដាញ ------------------------------------------------២៩
៣-យុទ្ធសាស្ត្របណ្ដាញ ----------------------------------------------២៩
៤-រចនាសម្ព័ន្ធបណ្ដាញ---------------------------------------------- ៣០
៥-ទំហំបណ្ដាញ --------------------------------------------------- ៣០
៦-ការទូទាត់បណ្ដាញ ----------------------------------------------- ៣០
៧-ជ្រើសរើសមេបណ្ដាញ-------------------------------------------- ៣០
៨-ហ្វឹកហាត់មេបណ្ដាញ--------------------------------------------- ៣១
៩-លើកទឹកចិត្តមេបណ្ដាញ ------------------------------------------ ៣១
១០-វាយតំលៃបណ្ដាញ --------------------------------------------- ៣១
១១-បង្កើនប្រសិទ្ធភាពបណ្ដាញ ------------------------------------- ៣១
១២-ការហ្វឹកហាត់ភាពជាអ្នកធ្វើបណ្ដាញ -------------------------------- ៣២
១៣-ឯកទេសចរចារ------------------------------------------------ ៣២
១៤-ជំនាញការបង្កើតទំនាក់ទំនង ----------------------------------------៣៣

## អនុវត្តន៍

I.ទទួលស្គាល់ និង កំណត់បញ្ហា ------------------------------------------ ៣៤
II.វាយតំលៃក៏រិតអង្គការនយោបាយ ------------------------------------ ៣៤
III.អនុវត្តន៏វិធីសាស្ត្រឃោសនា------------------------------------------- ៣៤
១-ចិត្តសាស្រទូទៅ ------------------------------------------------- ៣៤
២-សង្គ្រាមចិត្តសាស្ត្រ ---------------------------------------------- ៣៥
៣-សង្គ្រាមនយោបាយ --------------------------------------------- ៣៥
៤-មនោគមន៏វិជ្ជានយោបាយ ----------------------------------------៤២
ក-មនោគមន៏កុម្មុយនិស្តយួន -----------------------------------៤៣
ខ-សាសនាព្រះពុទ្ធជាឧបករណ៏នយោបាយ ---------------------------- ៤៤
គ-ចារនារីស្អាត ទាក់ស្ដេច សី ហនុ ធ្វើជាខែល ----------------------------- ៤៥
ឃ-ជឿគ្មានហេតុផលគ្មានការពិត ----------------------------------- ៤៧
ង-យួន ហ៊ុន សែន ត្រួតត្រាសារពតិមាន ---------------------------------- ៤៧
ច-ពុទ្ធទំនាយ រងចាំអ្នកមានបុណ្យ ------------------------------------ ៤៨

ឆ-សន្តិភាព និង ប្រជាធិបតេយ្យ ---------------------------------------- ៤៨
ជ-កុំអោយខ្មែររើសអើងពូជសាសន៍ -------------------------------------- ៤៨
ឈ-មិនបាត់បង់ទឹកដីខ្មែរសព្វថ្ងៃ ---------------------------------------- ៤៩
ញ-បំភិតបំភ័យ គំរាម សម្លាប់ ------------------------------------------- ៥០
ដ-ខ្មែរក្រីក្រ រហេមរហាម ------------------------------------------------ ៥១
ឋ-ដឹងគុណ ៧ មករា------------------------------------------------------ ៥១
ឱ-ឈប់អោយខ្មែរគិតគូររឿងជាតិ-------------------------------------- ៥២
៥-យុទ្ធសាស្ត្រនយោបាយឈ្នះ----------------------------------------------------៥២
IV.វាយតម្លៃលទ្ធផលអនុវត្តន៍ ----------------------------------------------------៥២

## ត្រួតពិនិត្យ

I. ត្រួតពិនិត្យផែនការប្រចាំឆ្នាំ ------------------------------------------------- ៥៣
II. ត្រួតពិនិត្យផលប្រយោជន៍------------------------------------------------------ ៥៣
III. ត្រួតពិនិត្យប្រសិទ្ធភាព ------------------------------------------------------- ៥៣
IV. ត្រួតពិនិត្យយុទ្ធសាស្ត្រឃោសនា -------------------------------------------------៥៤
V. ត្រួតពិនិត្យផ្នែកឃោសនា ---------------------------------------------------------៥៤
VI-ការសន្និដ្ឋាន ------------------------------------------------------------------------៥៦
ឯកសារយោង ---------------------------------------------------------------------------៥៧

# សេចក្តីថ្លែងអំណរគុណ (Acknowledgment)

ជាបឋមខ្ញុំសូមលើកហត្ថថ្វាយបង្គំព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក អ្នកម្តាយ និងជាតិខ្មែរ ជាអ្នកមានគុណដ៏លើសលុប ដែលបានផ្តល់ជីវិត ផ្តល់កំណើតកូន ខិតខំចិញ្ចឹមបីបាច់ថែរក្សាកូន និងអោយខ្ញុំកើតជាខ្មែរ ។

ជាពិសេស ខ្ញុំព្រះករុណាសូមអរព្រះគុណចំពោះ ព្រះតេជគុណគ្រប់ព្រះអង្គ ដែលបានខិតខំជួយសំរួលក្នុងកិច្ចការនេះ ។

សូមគោរពថ្លែងអំណរគុណលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ដែលបានផ្តល់ចំណេះដឹងដល់ខ្ញុំ និងកុលបុត្រ កុលធីតាខ្មែរគ្រប់រូប ។

សូមថ្លែងអំណរគុណ អស់លោក លោកស្រី ដែលបានជួយឧបត្ថម្ភគាំទ្រ ។ សៀវភៅនេះចងក្រងឡើងដើម្បីឧទ្ទិសដល់អ្នកដឹកនាំ អ្នកស្នេហាជាតិ និងអ្នកជាតិខ្មែរនិយម ដែលសុខចិត្តលះបង់ កំលាំងកាយ ចិត្ត រហូតដល់បូជាជីវិត ដើម្បីបុព្វហេតុការពារជាតិមាតុភូមិខ្មែរគ្រប់ជំនាន់ អោយបានគង់វង្សរហូតមកដល់បច្ចុប្បន្ននេះ និងសូមឧទ្ទិសដល់ជនរួមឈាមខ្មែរ ដែលស្លាប់ដោយអយុត្តិធម៌ជាបន្តបន្ទាប់ ដោយសារកុម្មុយនិស្តយួន និងជនផ្តាច់ការបំរើផលប្រយោជន៍យួន **ហ៊ុន សែន** ។

សៀវភៅនេះ ខ្ញុំខិតខំចងក្រងឡើងក្នុងគោលបំណងរួមចំណែក ដើម្បីបណ្តុះបង្កើនសមត្ថភាព ចំណេះដឹងបទពិសោធន៍ ដល់សមាជិកជាតិខ្មែរ ប្រជាជាតិខ្មែរ អោយមានការយល់ដឹងបន្ថែមអំពី **យុទ្ធសាស្ត្រឃោសនា** ដែលជាបទពិសោធន៍ និងការស្រាវជ្រាវសៀវភៅផ្សេងៗមួយចំនួនទៀត គួបផ្សំនិងគំនិតផ្ទាល់របស់អ្នកនិពន្ធ ដើម្បីចែកចាយដល់ជនរួមឈាមខ្មែរ អ្នកស្នេហាជាតិខ្មែរ ។ សៀវភៅនេះអាចជួយបង្ហាញផ្លូវ ដល់អ្នកស្នេហា-ជាតិខ្មែរ កូនខ្មែរទាំងអស់ ហ៊ានងើបឡើង ការពារជាតិខ្លួន អោយរួចផុតពីក្រញ៉ាំ **អាណានិគមន៍កុម្មុយនិស្ត-យួនបែបថ្មី** សព្វថ្ងៃ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជួយបំភ្លឺដល់ ព្រះតេជគុណ សិស្ស និស្សិត ជំនាន់ក្រោយ និងអស់លោក លោកស្រី ដែលមានឈាមជ័រជាខ្មែរ សំរាប់ខិតខំប្រឹងប្រែងជួយរំដោះសង្គមជាតិខ្មែរ ប្រជាពលរដ្ឋខ្មែរ កំពុងតែដង្ហោយហៅ ។ ខ្ញុំយល់ថា តាមរយៈសៀវភៅនេះ អាចជាគំនិតតិចតួចស្តួចស្តើង មិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ តែអាចយកទៅសិក្សាបន្ថែមដើម្បីអោយស៊ីជំរៅ ដើម្បីជាជំនួយដល់ស្នេហាជាតិខ្មែរ ក៏ដូចជាជាតិខ្មែរ ពីព្រោះថា *ការរៀនមិនចេះចប់ឡើយ គឺរៀនរហូតដល់បញ្ចប់ជីវិតនៅលើលោកនេះ*។ ខ្ញុំរីករាយនិងទទួលយកនូវការរិះគន់ កែលម្អ គ្រប់បែបយ៉ាង អំពីលោកអ្នកអាន ។

ជាចុងបញ្ចប់នេះ ខ្ញុំសង្ឃឹមថា អស់លោកអ្នកអាន ពិតជានិងទទួលបាននូវគំនិតយុទ្ធសាស្ត្រឃោសនា ដើម្បីយកទៅអនុវត្តអោយមានប្រសិទ្ធភាពសំរាប់ សង្គ្រោះ រំដោះ ការពារ **ជាតិ សាសនា ប្រជាជាតិខ្មែរ** នាពេលបច្ចុប្បន្ននេះ ។

ធ្វើនៅទីក្រុងវ៉ាស៊ីនតោន

ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨

**ស ធម្មរង្សី**

# អារម្ភកថា

សៀវភៅយុទ្ធសាស្រ្តឃោសនា ដែលអស់លោកអ្នកកំពុងអាននៅក្នុងដៃនេះ គឺជាកូនសៀវភៅតូចមួយសំរាប់បំភ្លឺផ្លូវដល់អស់លោកអ្នក និងកុលបុត្រកុលធីតាខ្មែរ អោយបានយល់ដឹងបន្ថែម អំពីវិធីឃោសនា ដើម្បីជួយជ្រុំជ្រែង ក្នុងការងាររំដោះប្រទេសជាតិមាតុភូមិខ្មែរ អោយរួចពីផែនការយួនកុម្មុយនិស្ត (ឥណ្ឌូចិន) ដែលកំពុងតែត្រួតត្រា ទាំងខ្មែរក្រោម និងប្រទេសខ្មែរនាពេលបច្ចុប្បន្ន។ ខ្មែរគ្រប់រូបមានតែការឈឺចាប់ ពីមួយជំនាន់ ទៅមួយជំនាន់ តែការឈឺចាប់នេះ នៅតែគរលើគំនរទុក្ខប្រជាពលរដ្ឋខ្មែរដដែល។ ដោយប្រជាពលរដ្ឋខ្មែរមិនដឹងរិះរកវិធីមួយណា ធ្វើយ៉ាងដូចម្តេច ដើម្បីដោះស្រាយបញ្ហា ដែលកំពុងតែកើតមានឡើងនេះអោយចប់ និងរួចផុតពីក្តៀបរបស់កុម្មុយនិស្តយួន រហូតខ្មែរទទួលបានសុខក្សេមក្សាន្តឡើយ។ ខ្មែរយើងមានតែកម្លាំងចិត្ត តែខ្វះកម្លាំងប្រាជ្ញា តាមយុទ្ធសាស្រ្តលោក ស៊ុន ស៊ូ *បើយើងចង់យកឈ្នះសត្រូវ យើងត្រូវយកឈ្នះខាងយុទ្ធសាស្រ្ត*។ ហេតុដូច្នេះហើយ អ្នកនិពន្ធខិតខំចងក្រងសៀវភៅនេះឡើងទុកជាក្បួនខ្នាត គឺក្នុងគោល-បំណងរួមចំណែកផ្សព្វផ្សាយដល់កុលបុត្រកុលធីតាខ្មែរ អ្នកស្នេហាជាតិខ្មែរ ពីគ្រប់មជ្ឈដ្ឋាន អោយបានយល់ដឹងខ្លះៗ អំពីរបៀបឃោសនា ដើម្បីចូលរួមចំណែក រំដោះប្រទេសជាតិយើង អោយមានឯករាជ្យភាព សន្តិភាព សិទ្ធិសេរីភាពពេញលេញ ឧត្តមភាព រុងរឿង ក្នុងនាមជាខ្មែរ មិនព្រមស្លាប់ដូចពស់ រស់ដូចកង្កែប ដូចសព្វថ្ងៃនេះឡើយ។ កូនខ្មែរទាំងអស់ត្រូវដឹងថា វាសនាអនាគតជាតិខ្មែរ គឺស្ថិតនៅលើកណ្តាប់ដៃរបស់អស់លោកអ្នក ដែលមានសៀវភៅនេះអានក្នុងដៃហើយ។ បើលោកអ្នកបានយល់ហើយ ឃើញហើយ សូមរួមចំណែក លះបង់ គាំទ្រ មិនថាតិច ឬច្រើន តាមលទ្ធភាព នោះជាតិយើងនិងរស់ស្មើមុខជាតិសាសន៍ដទៃ មិនព្រមស្ថិតនៅក្រោមការត្រួតត្រារបស់បរទេស ដូចយួនត្រួតត្រាខ្មែរសព្វថ្ងៃ តាមរយៈ **ហ៊ុន សែន** ប្រើជាកូនអុក និងយកឈ្មោះស្តេច **សីហនុ** ជារនាំង អោយខ្មែរយើងស្ងប់ចិត្ត យល់ខុសថា ប្រទេសខ្មែរមានសុខសន្តិភាព វាធ្វើអោយខ្មែរមើលឃើញ មានឡាន លុយ វីឡា ជារឿងអស្ចារ្យ តែគួរអោយអាណិតអាសូរឈាមខ្មែរពេកក្រៃ ដែលនៅតែហូរ នៅតែក្រីក្រ និងគួរអោយសង្វេកដល់ឈាមខ្មែរដែលបានស្លាប់ នៅលើសមរភូមិ និងអ្នកស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យកន្លងមក។ ជនរងគ្រោះខ្មែរសព្វថ្ងៃ រស់នៅរងទុក្ខវេទនា គ្មានអ្នករកយុត្តិធម៌ គ្មានអ្នកយកចិត្តទុកដាក់ តែផ្ទុយទៅវិញ យួនសុខចិត្តបូជាជីវិត និងធ្វើអ្វីគ្រប់យ៉ាង ដើម្បីគោលដៅធំបំផុតរបស់វា គឺយកទឹកដីខ្មែរ ព្រោះទឹកដីខ្មែរសំខាន់ជាងវត្ថុ និងសម្ភារៈទាំងអស់នោះ គឺពួកវាប្រើនយោបាយត្រដាក់មកដណ្តើមយកផលប្រយោជន៍ពីខ្មែរ និងត្រួតត្រាក្នុងក្រសួងសំខាន់ដូចជា ប៉ូលីស ទាហាន ក្រសួងការបរទេស ហើយយួនបង្កើត សមាគមន៍១៩ ខេត្តក្រុង ដើម្បីបញ្ជូនជនជាតិយួនបន្តិចម្តងៗ មកតាំងទីលំនៅ លើទឹកដីខ្មែរ ទីបំផុតខ្មែរក្លាយជា ជនជាតិភាគតិចរបស់យួន ដូចមាន ចាម និង ខ្មែរក្រោម ជាឧទាហរណ៍ស្រាប់។

# ទស្សនៈអ្នកនិពន្ធ

ដោយមើលឃើញ ភាពមហន្តរាយគ្រោះថ្នាក់សំរាប់ប្រទេសជាតិ និងប្រជាជាតិខ្មែរ ព្រោះយួនមានមហិច្ឆតាលេបយកផលប្រយោជន៍ពីខ្មែរ និងត្រួតត្រាលើទឹកដីខ្មែរបច្ចុប្បន្ន តាមរយៈការប្រើនយោបាយត្រជាក់ ដើម្បីសំរេចគោលដៅនេះ។ ក្នុងនាមជាកូនខ្មែរ ដែលមានឈាមជ័រជាខ្មែរមួយរូប មិនទុកឱកាសបណ្តោយអោយបរទេស មកជាន់ឈ្លី ជាតិ សាសនា និងប្រជាជាតិខ្មែរ រហូតដល់បាត់បង់អធិបតេយ្យភាពបូរណភាពទឹកដី ឯករាជ្យទាំងស្រុង ដូចប្រទេសចម្ប៉ា និងខ្មែរក្រោមនោះឡើយ។ យើងជាខ្មែរទាំងអស់គ្នាធ្លាប់មានអរិយធម៌រុងរឿងនាសម័យអង្គរ បុព្វបុរសខ្មែរ បានលះបង់ឈាមស្រស់ សាច់ស្រស់ ដើម្បីកុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយ រស់នៅមានសេចក្តីសុខសុភមង្គល តែបើយើងទាំងអស់គ្នា ជាកូនចៅខ្មែរជំនាន់នេះ ឃើញហើយ ដឹងហើយ ឮហើយ អំពីគ្រោះថ្នាក់ប្រទេសជាតិខ្លួនបែបនេះ តែមិនហ៊ានលះបង់ មិនហ៊ាននិយាយ មិនហ៊ានធ្វើ ព្រោះខ្លាចស្លាប់ តើវាមានប្រយោជន៍អ្វី ដែលទុកអោយជាតិទាំងមូលស្លាប់?។ យើងជាខ្មែរម្នាក់ៗត្រូវតែជាអ្នកទទួលខុសត្រូវចំពោះជាតិខ្លួននៅជំនាន់យើងនេះ យើងមិនសុខចិត្តបណ្តោយអោយប្រវត្តិសាស្ត្រតិះតិះដៀលថាមនុស្សកំសាកឡើយ។ ដូច្នេះ យើងត្រូវនាំគ្នាភ្ញាក់រឭកឡើង ក្រោកឡើង រួបរួមសាមគ្គីគ្នាឡើង ដើម្បីការពារ ជាតិ សាសនា ប្រជាជាតិខ្មែរ ទឹកដីខ្មែរ កុំអោយបាត់បង់ជាដាច់ខាត ការពារផលប្រយោជន៍ជាតិខ្មែរ ធ្វើយ៉ាងណាអោយខ្មែរមានសិទ្ធិសេរីភាព ឧត្តមភាព ស្មើមុខប្រទេសនានា ក្នុងតំបន់ និងសកលលោក។ យើងទាំងអស់គ្នាសូមសច្ចាយ៉ាងម៉ឺងម៉ាត់ថា មិនបណ្តោយអោយទឹកដីខ្មែរបាត់បង់ ដូចទឹកដីខ្មែរក្រោមជាដាច់ខាត។ យើងមិនត្រូវបណ្តោយអោយប្រទេសខ្មែរធ្លាក់ក្នុងការត្រួតត្រារបស់យួនដូច សព្វថ្ងៃនេះឡើយ។ បើសិនជាប្រទេសយើងធ្លាក់ក្នុងដៃយួនដូចសព្វថ្ងៃ តែយើងមិនភ្ញាក់ខ្លួន ឬឈឺចាប់នោះទេ រស់ដើម្បីតែក្រពះ តាមយុទ្ធសាស្ត្ររបស់យួន និង **ហ៊ុន សែន** ជាអ្នករៀបនោះ កូនចៅខ្មែរជំនាន់ក្រោយនិងរងទុក្ខវេទនាគ្មានទីបញ្ចប់ឡើយ ហើយប្រវត្តិសាស្ត្រខ្មែរ និងក្លាយទៅជាប្រវត្តិសាស្ត្រឥណ្ឌូចិន ក្នុងអំឡុងពេល ៥០ ឆ្នាំទៀត។ និយាយអោយចំ ឥឡូវនេះទឹកមិនទាន់ដល់ច្រមុះទេ យើងត្រូវតែនាំគ្នាស្ទុះស្ទារឡើង កុំចាំរហូតដល់ទឹកចូលច្រមុះហើយទើបយើងនាំគ្នាភ្ញាក់ឡើង ពេលនោះ ជាតិខ្មែរយើងហួសពេលទៅហើយ។

អ្វីដែលអ្នកនិពន្ធខិតខំ បង្ហាញនូវវិធីសាស្ត្រទាំងអស់នេះ មិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ហើយក៏ *មិនអាចឈានទៅដល់គោលដៅជោគជ័យសំរាប់ជាតិខ្មែរបានដែរ បើសិនជាគ្មានការចូលរួមពីប្រជាពលរដ្ឋខ្មែរទាំងមូល ជាពិសេស អស់លោកអ្នកដែលស្នេហាជាតិខ្មែរពិតៗ ពីគ្រប់មជ្ឈដ្ឋាន ដែលកំពុងអានសៀវភៅនេះនៅក្នុងដៃ។*

ប្រទេសមួយចំនួនដែលរឹងប៉ឹងទៅបាន លុះត្រាតែការដឹកនាំមានជំហរឯករាជ្យ មិនពឹង និងស្ថិតនៅក្រោមគំនាបបរទេស ហើយមេដឹកនាំត្រូវមានគំនិតស្នេហាជាតិមួយដ៏រឹងប៉ឹង ដូចជាប្រទេស សហរដ្ឋអាមេរិច បារាំង អង់គ្លេស រុស្ស៊ី ជប៉ុន កូរ៉េខាងត្បូង ថៃ និង មួយចំនួនទៀតសហគមន៍អឺរ៉ុបជាដើម។ ក្រោយពីសង្គ្រាមលោកលើកទី

២ សន្ធិសញ្ញាអន្តរជាតិស្តីពីពាណិជ្ជកម្មសេរី មិនអនុញ្ញាតអោយបណ្តាប្រទេស នៅអឺរ៉ុបមួយចំនួន ប្រើនយោបាយដាក់អាណានិគមទៀឡើយ។ ប្រទេសមួយចំនួន បានទាមទាឯករាជ្យជាបន្តបន្ទាប់ ហើយធ្លាក់ចូលមកជាសង្គ្រាមត្រជាក់រវាង កុម្មុយនិស្តនិងសេរី ពេលនោះប្រទេសខ្មែរស្ថិតនៅក្រោមការត្រួតត្រារបស់យួន កុម្មុយនិស្តទាំងស្រុងនាចន្លោះឆ្នាំ (១៩៧៩-១៩៩១)។ ចុះហេតុអ្វីឥឡូវនេះ យើងបណ្តោយអោយពួកកុម្មុយនិស្តយួនត្រួតត្រាខ្មែរទៀត។ យួនប្រើខ្មែរបំរើកុម្មុយនិស្តនោះ ជារនាំងបិទបាំង ប្រជាពលរដ្ឋខ្មែរ ធ្វើមនោគមន៍លើខ្មែរស្លូតត្រង់អោយលង់ជឿការបោកប្រាស់របស់វា ធ្វើអោយជាតិខ្មែរទទួលរងគ្រោះដោយសារ ពួកកុម្មុយនិស្តនេះ ម្តងហើយម្តងទៀត។

ខ្ញុំមានការសោកស្តាយជាខ្លាំង ពេលដែលឃើញមេដឹកនាំខ្មែរ មួយចំនួន ដូចជា **សី ហានុ** និង **ហ៊ុន សែន** ដែលបំរើនយោបាយអោយពួកកុម្មុយនិស្ត សុខចិត្តអោយប្រជារាស្ត្រខ្លួនស្លាប់រាប់លាននាក់ និងរងទុក្ខវេទនាគ្មានពេលល្ហែ ដោយសារតែការដឹកនាំធ្វើតាមខ្សែរញាក់របស់បរទេស ដែលគ្មានចំណេញអ្វីដល់ខ្មែរបន្តិចសោះឡើយ ថែមទាំងចំអកអោយខ្មែរ ថាការស្លាប់នេះជារឿងនយោបាយរបស់ឪទៅវិញ។

ខ្ញុំសង្ឃឹមថា អស់លោកដែលមានគំនិតស្នេហាជាតិ មាតុប្រទេសទាំងឡាយ មិនបណ្តោយអោយឈាមខ្មែរនៅតែហូរដូចសព្វថ្ងៃ មិនទុកអោយប្រជាពលរដ្ឋខ្មែរនៅតែយំ ដោយយើងសំងំយកសុខ លើគំនរទុក្ខរបស់ជាតិខ្លួននោះឡើយ។ ខ្ញុំសូមបួងសួងដល់វត្ថុសាកសិទ្ធិទាំងឡាយក្នុងដែនដីខ្មែរ ពិសេស បុព្វបុរសខ្មែរអ្នកស្នេហាជាតិខ្មែរគ្រប់ជំនាន់ ដែលបានថែរក្សាទឹកដីខ្មែរ ចូលមកសន្ថិតក្នុងដួងព្រលឹងកូនខ្មែរជំនាន់នេះ ដើម្បីជួយថែរក្សាការពារជាតិខ្មែរ អោយរួចផុតពីការការជិះជាន់ត្រួតត្រារបស់យួន របបកុម្មុយនិស្ត **ហ៊ុន សែន** ភាពក្រីក្រ អំពើពុករលួយ និងអយុត្តិធមិផ្សេងៗ។

ជាទីបញ្ចប់នេះ ខ្ញុំសូមអំពាវនាវ ដល់អ្នកស្នេហាជាតិខ្មែរទាំងអស់ ដែលមានទឹកចិត្តចូលរួម ក្នុងកិច្ចការរំដោះជាតិខ្មែរនេះ មេត្តាជួយថតចំលងចែកចាយ និងផ្សព្វផ្សាយដល់សមាជិកជាតិខ្មែរតៗគ្នាផង ដើម្បីជួយពង្រឹងចំណេះដឹងដល់សមាជិកទាំងអស់អោយកាន់តែទូលំទូលាយ។

# ជំពូកទី ១



ព្រះបាទជ័យវរ្ម័នទី ៧ តំណាងមហាវិរក្សត្រស្នេហាជាតិខ្មែរ

## I-និយមន័យ (Definition)

ការឃោសនា គឺជាដំណើរការបញ្ចេញនូវគោលនយោបាយ និងទស្សនៈផ្សេងៗរបស់អង្គការនយោបាយជាតិខ្មែរ ទៅដល់ប្រជាពលរដ្ឋដើម្បីអោយមានការគាំទ្រ និងចូលរួមក្នុងអង្គការនយោបាយយើង។ អង្គការនយោបាយយើងនេះ គឺមិនមែនធ្វើសំរាប់ផលប្រយោជន៍បុគ្គល ឬបក្សណាមួយទេ គឺធ្វើឡើងដើម្បីផលប្រយោជន៍ ជាតិសាសនា និងប្រជាជាតិខ្មែរពិតៗ។ ការឃោសនានេះ ជាកត្តាសំខាន់ណាស់សំរាប់អង្គការនយោបាយយើង ដើម្បីទាក់ទាញអ្នកគាំទ្រ ទាក់ទាញប្រជាពលរដ្ឋខ្មែរពីគ្រប់ស្រទាប់ក្នុងសង្គមអោយចូលរួមជាអតិបរមាតាម គោលការណ៏នយោបាយ រហូតបានសំរេចជោគជ័យតាមចក្ខុវិស័យរបស់អង្គការដឹកនាំនយោបាយ ដែលបានកំណត់។

គោលការណ៏នយោបាយរបស់យើងត្រូវផ្លាស់ប្តូរ *មេដឹកនាំ ប្រព័ន្ធគ្រប់គ្រង* ដែលមានអំពើពុករលួយ កែប្រែប្រជាពលរដ្ឋក្រីក្រ និងភាពអយុត្តិធម៌ ទៅជាជាតិមួយដែលថ្លៃថ្នូរ ស្អាតស្អំ យុត្តិធម៌ ស្មើមុខ មានឧត្តមភាពដូចប្រទេសនានាលើពិភពលោក។ *នយោបាយដឹកនាំ* ពីរបបកុម្មុយនិស្តក្រោមយួនត្រួតត្រា ទៅជារបបប្រជាធិបតេយ្យ មានឯករាជ្យពិតប្រាកដ *មិនស្ថិតនៅការក្រោមការត្រួតត្រា ឬពឹងពាក់យួន*។ នៅក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋជាម្ចាស់នៃអំណាច ហេតុដូចនេះ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពក្នុងការ គិត និយាយ បញ្ចេញមតិផ្សេងៗ និងធ្វើការសំរេចចិត្តក្នុងការជ្រើសរើសតំណាងរបស់ខ្លួន ដើម្បីបំរើផលប្រយោជន៏ជាតិ និងប្រជាពលរដ្ឋទូទៅ ដូចដែលខ្លួនចង់បាន។

## II. គោលបំណងឃោសនា (Goal of Propaganda)

ឃោសនិកនីមួយៗត្រូវមានគោលបំណង និងគោលដៅរបស់ខ្លួនអោយច្បាស់លាស់ នៅពេលដែលខ្លួនចាប់ផ្តើមធ្វើការឃោសនា។ យើងជាឃោសនិកត្រូវដឹងថា យើងមានភារកិច្ច និងតួនាទីធ្វើអ្វីខ្លះ?។ គោលដៅរបស់យើង គ្រប់ទីកន្លែង និងគ្រប់ពេលវេលា ត្រូវធ្វើការឃោសនាដល់ប្រជាពលរដ្ឋខ្មែរ គ្រប់មជ្ឈដ្ឋាន អោយភ្ញាក់រលឹកស្រឡាញ់ជាតិខ្លួន ស្រឡាញ់ប្រជាពលរដ្ឋខ្មែរ អាណិតអាសូរចង់ជួយជាតិខ្មែរ និងអោយមើលឃើញអំពីគ្រោះមហន្តរាយរបស់ប្រទេសជាតិ។ យើងត្រូវធ្វើយ៉ាងណាអោយមានការគាំទ្រកាន់តែច្រើនជាអតិបរមា ដល់អង្គការនយោបាយរបស់យើង។ យើងធ្វើយ៉ាងណាអោយប្រជាពលរដ្ឋខ្មែរ យល់ដឹងការពិត អំពីប្រវត្តិសាស្រ្តខ្មែរ បញ្ហានានាដែលកើតកំពុងកើតឡើងនាពេលបច្ចុប្បន្ន ដូចជា អំពើពុករលួយ អយុត្តិធម៌ និងភាពក្រីក្រជាដើម។ យើងត្រូវនាំមុខក្នុងការគិតគូរសិទ្ធិសេរីភាពខ្មែរផលប្រយោជន៏ជាតិខ្មែរ ជាផលប្រយោជន៏របស់យើង ទាំងអស់គ្នា មិនមែនជាផលប្រយោជន៏របស់បុគ្គលណាម្នាក់ឡើយ។ ដូច្នេះ យើងទាំងអស់គ្នាដែលមានឈាម ជ័រជាខ្មែរដូចគ្នា យើងមិនត្រូវអល់អែកស្ទាក់ស្ទើរ និងឆ្ងល់ហេតុអ្វីបានតែក្រីក្រ គិតតែក្រពះ ឬអាត្មានិយម។ ហេតុអ្វីយើងសិក្សារៀនសូត្រចប់ គេមិនអោយតំលៃ គ្មានការងារ ផ្តល់ប្រាក់ខែមិនគ្រប់គ្រាន់ នេះបណ្តាលមកពីមេដឹកនាំ និងនយោបាយដឹកនាំគ្មានឯករាជ្យ ក្រោមការត្រួតត្រាយួន។ ហេតុនេះ ដើម្បីដោះស្រាយបញ្ហា យើងត្រូវនាំគ្នាដោះស្រាយឫសគល់នៃបញ្ហា យើងមិនអាចដោះស្រាយតែ ចុងបញ្ហាថាចប់ឡើយ។ យើងជាខ្មែរត្រូវរួមចំណែក តាំងចិត្តមុតមាំ យល់ដឹងគ្រប់បែបយ៉ាងអំពីនយោបាយ ដែលជាកិច្ចការធំ ជាផលប្រយោជន៏ជាតិ ជាអាយុជីវិត

ប្រជាពលរដ្ឋខ្មែរទាំងអស់ យើងទាំងអស់គ្នាឈប់គាំទ្រគណបក្សប្រជាជន **ហ៊ុន សែន**។ មេដឹកនាំនយោបាយគឺជាអ្នកកាច់ចង្កូតប្រទេសជាតិ អោយរីកចំរើន ឬអន្តរាយ រឹងប៉ឹង ឬទន់ខ្សោយ ប្រជាពលរដ្ឋមាន ឬក្រ ស្លាប់ ឬរស់ ។ យើងត្រូវបង្ហាញប្រជាពលរដ្ឋខ្មែរថា ផលប្រយោជន៏ទាំងឡាយ អាយុជីវិតរបស់ពួកគាត់ម្នាក់ៗគឺអាស្រ័យលើមេដឹកនាំនយោបាយ ពីព្រោះនយោបាយនេះអាចអោយគាត់ សុខ ឬលំបាកវេទនា។ អាស្រ័យហេតុនេះ យើងមិនត្រូវទុកចិត្តតែលើមនុស្សម្នាក់ដឹកនាំនោះទេ គឺយើងទាំងអស់គ្នានេះហើយ មានភារកិច្ចការពារផលប្រយោជន៏ជាតិរបស់យើងដោយខ្លួនឯង ទទួលខុសត្រូវចំពោះជាតិយើង ធ្វើយ៉ាងណាអោយប្រជាពលរដ្ឋខ្មែរចាប់អារម្មណ៏ និងយកចិត្តទុកដាក់យល់ដឹងអំពីរឿងនយោបាយនេះ។ យើងរស់នៅក្នុងសង្គមមួយ មិនអាចគេចចេញអោយផុតពីនយោបាយបានទេ ទោះជាខិតខំគេចរត់ទៅណា ក៏មិនអាចចៀសផុតពីនយោបាយបានឡើយ។ មនុស្សម្នាក់នៅក្នុងសង្គមគ្រួសារ គ្រួសារម្នាក់ក្នុងសង្គមមនុស្ស សង្គមមនុស្សនៅក្នុងសង្គមជាតិមួយ ដូចនេះបើមនុស្សមិនគិតពីនយោបាយ (ផលប្រយោជន៏) មានន័យថា ផលប្រយោជន៏សង្គមជាតិទាំងមូល និងត្រូវបាត់បង់ហើយផលប្រយោជន៏បុគ្គលត្រូវតែបាត់បង់តាមនោះដែរ។ យើងប្រៀបធៀបនយោបាយជាតិ ទៅនិងពាងទឹកមួយបើពាងទឹកនោះមានទឹកពេញ យើងអាចយកកែវ ទោះតូចឬធំ ទៅដងយកបានពេញដែរ តែពាងនោះគ្មានទឹកពេញទេ ទោះជាយើងយកកែវធំទៅដង ក៏មិនអាចបានពេញដែរ។ យ៉ាងណាមិញ ផលប្រយោជន៏បុគ្គលក៏យ៉ាងដូច្នេះដែរ កាលណាផលប្រយោជន៏ជាតិទាំងមូលបាត់បង់ហើយ ផលប្រយោជន៏បុគ្គលក៏បាត់បង់ដែរ។ ជាតិខ្មែរកើតចេញពី ពលរដ្ឋខ្មែរ ទឹកដីខ្មែរ រដ្ឋឯករាជ្យ និងរដ្ឋាភិបាលនេះឯង។

កាលណាប្រជាពលរដ្ឋចូលរួមគាំទ្រអំពីនយោបាយហើយ ការដឹកនាំប្រទេសមានការរីកចំរើន ព្រោះមានការចូលរួមគាំទ្រពីប្រជាពលរដ្ឋ។ យើងធ្វើយ៉ាងណាអោយប្រជាពលរដ្ឋខ្មែរ យកចិត្តទុកដាក់អំពីផលប្រយោជន៏ជាតិខ្មែរជាធំ ឈប់គិតផលប្រយោជន៏បុគ្គល។ ជាក់ស្តែង សម័យអង្គរដែលខ្មែររីកចំរើនរុងរឿងក្លាយជាអាណាចក្រខ្មែរ ព្រោះកាលនោះ មេដឹកនាំខ្មែរ *ប្រជាពលរដ្ឋខ្មែរជាអ្នកស្នេហាជាតិ និងមានឯកភាពជាតិ* យ៉ាងខ្លាំង។ ចំណែកឯប្រទេសជប៉ុន ពេលដែលខ្លួនចាញ់សង្គ្រាមលោកលើកទី២ ដោយសារគំនិតស្នេហាជាតិជប៉ុនអាចធ្វើអោយប្រទេសរីកចំរើននៅក្នុងតំបន់អាស៊ី។ ចំណែកប្រទេសដទៃទៀត ដូចជា សហរដ្ឋអាមេរិក អង់គ្លេស បារាំង ចិន កូរ៉េ និងយួន ជាដើម ពួកគេសុទ្ធតែគិតផលប្រយោជន៏ជាតិគេធំជាងផលប្រយោជន៏បុគ្គលដែលខុសពីមេដឹកនាំខ្មែរបច្ចុប្បន្ន ដូច **សី ហនុ** និង **ហ៊ុន សែន** គិតតែលួចជាតិមកដាក់បុគ្គល លោភមុខមាត់ អំណាច បុណ្យស័ក្ក។ យើងជាខ្មែរមិនត្រូវប្រកាន់បក្សពួកណាមួយឡើយ យើងធ្វើកិច្ចការដើម្បីជាតិខ្មែរទាំងមូល ដូច្នេះ យើងត្រូវធ្វើយ៉ាងណា អោយប្រជាពលរដ្ឋខ្មែរគ្រប់និន្នាការនយោបាយ និងអ្នកស្នេហាជាតិពិតប្រាកដចូលរួមគាំទ្រគោលនយោបាយរបស់យើង។ យើងជាអ្នកឃោសនា ត្រូវទាញចំណេញពីគ្រប់ស្ថានការណ៏ ដែលយើងអាចមើលឃើញ។ គោលដៅចុងក្រោយរបស់យើង គឺ ជាតិខ្មែរទាំងមូល ជាអ្នកទទួលផលប្រយោជន៏ ជោគជ័យលើគូរប្រកួតប្រជែងរបស់យើង។

## III.ដំណើរការឃោសនា (Process of Propaganda)

### ១.វិភាគឱកាស (Opportunity Analyze)

ការវិភាគឱកាសនេះ មានសារៈសំខាន់ណាស់សំរាប់ឃោសនិក ។ យើងជាឃោសនិកត្រូវតាមដានស្ថានការណ៍ និងប្រមូលពតិមាន ពីគូរប្រកួតប្រជែងរបស់ខ្លួន ពីគ្រប់ស្ថានការណ៍ និងពីគ្រប់មជ្ឈដ្ឋាន ដើម្បីយកមកវិភាគ រិះរកចំណុចខ្សោយ (Weakness) និងចំណុចខ្លាំងរបស់សត្រូវ (Strength) ទាញចំណេញពីឱកាស (Opportunity) និង ការគំរាមគំហែងរបស់សត្រូវ (Threats) ។

*បើយើងសិក្សាដឹងអំពីចំណុចខ្សោយរបស់សត្រូវច្បាស់លាស់ហើយ យើងត្រូវវាយលុកតែត្រង់ចំណុចខ្សោយរបស់សត្រូវ លុះត្រាតែសត្រូវទទួលបរាជ័យ ។ បើយើងសិក្សាដឹងចំណុចខ្លាំងរបស់សត្រូវ យើងត្រូវបំបែកចំណុចខ្លាំងរបស់វាអោយខ្សោយ ទើបយើងធ្វើការវាយលុក ត្រង់ចំណុចខ្សោយនោះជាក្រោយ។* ដូចជាចំណុចខ្សោយរបស់គណបក្សប្រជាជន គឺវាធ្វើនយោបាយ ដើម្បីបំរើផលប្រយោជន៍អោយយួន និងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មេដឹកនាំអវិជ្ជាមួយចំនួន មិនមែនដើម្បីផលប្រយោជន៍ខ្មែរ និងប្រជាពលរដ្ឋខ្មែរឡើយ ។ យួនមួយចំនួនត្រួតត្រាខ្មែរមាន **ហុក ឡុងឌី ម៉ិន សម ចាយ សាំងយុន សុខ អាន សុខ គង់** និងជាច្រើននាក់ទៀតនៅក្នុងជួប៉ូលីស និងទាហាន ពួកវារៀនភាសាខ្មែរ និយាយភាសាខ្មែរ ចេះភាសាខ្មែរ ជាងជនជាតិខ្មែរទៅទៀត ។ បក្សពួក **ហ៊ុន សែន** បានអនុញ្ញាតអោយនិគមយួនចូលមករស់នៅលើទឹកដីខ្មែរ គគ្រឹកគគ្រេងស្រេចតែចិត្ត ដណ្តើមផលប្រយោជន៍ខ្មែរ ដណ្តើមការងារខ្មែរ ដណ្តើមដីប្រជាពលរដ្ឋខ្មែរដែលក្រីក្រ ធ្វើអោយខ្មែរឈឺចាប់រងទុក្ខវេទនាឥតល្ហែ។ ក្រុម **ហ៊ុន សែន** បានកាត់ទឹកដីខ្មែរអោយយួនតាមសិទ្ធិសញ្ញា មិត្តភាព សន្តិភាព និងសហប្រតិបត្តិការនាឆ្នាំ ១៩៧៩ ១៩៨០ ១៩៨១ ១៩៨៣ ១៩៨៥ (កោះត្រល់ និង ដីខ្មែរ តាមព្រំដែន និងដែនសមុទ្រខ្មែរមួយចំនួនទៀត) ។ ក្រោមល្បិចកលរបស់យួន ដែលប្រើ **ហ៊ុន សែន** ប្រទេសខ្មែរ នៅតែមានអំពើពុករលួយ អយុត្តិធម៌ក្នុងសង្គម និទណ្ឌភាព (ឈាមខ្មែរនៅតែហូរ ដូចជា **ជា វិជ្ជា ពិសិដ្ឋ ពលីការ ជោ ជោដ្ឋរិទ្ធ ឱម រ៉ាត់សាឌី** ជនរងគ្រោះក្នុងគណបក្សសមរង្ស៊ីកន្លងមក និងជនរងគ្រោះផ្សេងទៀត ដូចជា **ទូចស្រីនិច ពៅ បញ្ញាពេជ្រ** ពួកអាជ្ញាធរផ្តាច់ការ **ហ៊ុន សែន** មិនដែលចាប់ឃាតករមកផ្តន្ទាទោសបានឡើយ តែពួកវាចាប់ជនស្លូតត្រង់ អ្នកទន់ខ្សោយ ជនរងគ្រោះមកដាក់ទោស ជំនួសវិញ ដូចជា **ប៊ន សំណាង** និង **សុខ សំអឿន** ជាដើម) ។

### ២.សិក្សាពតិមាន និងរៀបចំប្រព័ន្ធពតិមាន

(Information Research and Information System)

#### ក-ស្រាវជ្រាវពតិមាន (Information Research)

យើងជាឃោសនិក ត្រូវចេះសិក្សាស្រាវជ្រាវពតិមានដោយខ្លួនឯង ធ្វើយ៉ាងណាដើម្បីអោយខ្លួនយើងស្គាល់ យល់ដឹងគ្រប់ស្ថានការណ៍ នៅក្នុងប្រទេស និងនៅលើពិភពលោក ជាពិសេស ពតិមានផែនការសម្ងាត់របស់គូរប្រកួតប្រជែងយើង ។ ការសិក្សាពតិមានជាកត្តាមួយសំខាន់ណាស់ ដើម្បីអោយយើងស្គាល់ ដឹងអំពីតំរូវការប្រជាពលរដ្ឋ បញ្ហាពិតប្រាកដរបស់ប្រជាពលរដ្ឋ និងនិន្នាការនយោបាយរបស់ប្រជាពលរដ្ឋ ។ ការសិក្សា

ពតិមានធ្វើឡើងក្នុងគោលបំណងប្រមូលនូវពតិមានសំខាន់ៗទាក់ទងទៅនឹងប្រជាពលរដ្ឋ បរិយាកាសនយោបាយ ចំនួនគណបក្សនយោបាយ ព្រឹត្តិការណ៍ គូរប្រកួតប្រជែង មតិសារធារណៈ សង្គមស៊ីវិល មតិប្រជាពលរដ្ឋ ឬ មតិសាធារណៈ។ យើងត្រូវបែងចែកទំនោររបស់ប្រជាពលរដ្ឋអោយច្បាស់លាស់ ថាតើតំបន់ណាប្រជាពលរដ្ឋ មានទំនោរទៅរកគណបក្សប្រជាជន តំបន់ណាទំនោរទៅគណបក្សប្រឆាំង។ យើងអាចបែកចែកទំនោរនយោបាយ ជាបីផ្នែកធំ គឺ រាជានិយម (គណបក្ស ហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិ) កុម្មុយនិស្ត (គណបក្ស ប្រជាជន និង គណបក្សចំរើននិយម គណបក្សប្រជាធិបតេយ្យ ដែលយួនបង្កើត) ប្រជាធិបតេយ្យ និងសេរី (គណបក្សសមរង្ស៊ី និង គណបក្សសិទ្ធិមនុស្ស និងមួយចំនួនទៀត) ។ ដូច្នេះ យើងត្រូវមានតារាងស្រាវជ្រាវ អំពីទំនោរប្រជាពលរដ្ឋនេះ អោយបានច្បាស់លាស់។ ប្រជាពលរដ្ឋអាចបែងចែកតាម ទីតាំងភូមិសាស្ត្រ (ខេត្ត ក្រុង ស្រុក ឃុំ ភូមិ) ចំនួន ប្រជាពលរដ្ឋ (ច្រើន មធ្យម តិច) តាមប្រភេទអាជីព( កម្មករ គ្រូបង្រៀន ម៉ូតូឌុប ពាណិជ្ជករ ទាហាន ប៉ូលីស) កំរិតជីវភាព មាន ឬក្រ។

**ខ-វិធីសាស្ត្រប្រមូលពតីមាន** (Gathering Information Method)

យើងអាចប្រមូលយកពតិមានទាំងនេះបាន តាមរយៈប្រព័ន្ធសារពតិមាន (ការសែត វិទ្យុ ទូរទស្សន៍ អ៊ិនតាណែត ទូរស័ព្ទ ទូរសារ អ៊ីម៉ែល សៀវភៅ ខិតប័ណ្ណ ភាពយន្ត ខ្សែអាត់) ឬ តាមរយៈការស្ទាបស្ទង់មតិ និងឯកសារផ្សេងៗ ដោយការអង្កេត ឬយើងសម្ភាសផ្ទាល់មាត់ ជាមួយប្រជាពលរដ្ឋតាមគោលដៅដែល យើងចង់ បានពតិមាន។ ដើម្បីទទួលបានពតិមានដែលអាចទុកចិត្តបាន យើងត្រូវបង្កើតភ្នាក់ងារពតិមានដែលមានបរិយាយ លំអិតខាងក្រោម។ (សូមសិក្សាលំអិត អំពីសង្គ្រាមពតិមាន) ពតិមានដែលទទួលបានមុនពេលធ្វើប្រតិបត្តិការ (សង្គ្រាម) មិនអាចជាពតិមានដែលយើងយកធ្វើផែនការបានទេ ពីព្រោះ ពេលដែលយើងចាប់ផ្តើមធ្វើនោះ ពតិមានតែងតែមានការប្រែប្រួល ហេតុនេះ មេដឹកនាំត្រូវមានការប្រមើលមើល ឬ ទស្សន៍ទាយ ឬត្រូវមានការ ស្រមើលស្រម័យលើស្ថានការណ៍ថ្មីមួយអោយត្រឹមត្រូវ។

**គ-តួនាទីរបស់ភ្នាក់ងារពតីមាន** (Roles of Intelligence)

- ត្រូវមានចំណេះវិជ្ជា ចំណេះខាងបច្ចេកវិទ្យា និងឯករាជ្យ
- លទ្ធភាពក្នុងការប្រមូលពតិមាន
- ពង្រីកទំនាក់ទំនង
- បង្កើនតួនាទីក្នុងមតិសាធារណៈ
- ទទួលយកនូវភ្នាក់ងារមួយចំនួន
- លទ្ធភាពខាង (បច្ចេកវិទ្យា និង ចិត្តវិទ្យា)

## ៣.ភ្នាក់ងារចារកម្ម (Espionage)

### ក-ភ្នាក់ងារពត៌មាន (Information Intelligences)

ការរៀបចំបណ្តាញពតិមាននេះ មានសារៈសំខាន់ណាស់សំរាប់ប្រមូលពតិមានសម្ងាត់ផ្សេងៗ ដែលគូរប្រកួតប្រជែងលាក់បាំង ជាពិសេស ផែនការសម្ងាត់ដែលយើងមិនអាចដឹងបាន។ *អ្នកដែលខ្លាំង គឺជាអ្នកដែលធ្វើអោយភ្នំអាចរំកិលបាន មិនមែនអ្នកដែលលើកសក់មួយសសៃនោះឡើយ ភ្នែកដែលភ្លឺ គឺជាភ្នែកដែលមើលឃើញក្នុងទីងងឹត មិនមែនមើលឃើញព្រះអាទិត្យ និងព្រះច័ន្ទឡើយ រីឯត្រចៀកដែលពូកែ គឺត្រចៀកអាចស្តាប់ឮអ្វីដែលគេមិននិយាយ មិនមែនស្តាប់ឮរន្ទះ ឬផ្គរឡើយ*។ ភារកិច្ចបណ្តាញពតិមាននេះ គឺត្រូវសិក្សាអោយដឹងច្បាស់ អំពីពតិមានរបស់គូរប្រកួតប្រជែងរបស់ខ្លួន ដូចជា កម្លាំង សម្ភារៈ សេដ្ឋកិច្ច យុទ្ធសាស្ត្រ ស្មារតី ទីតាំង ចំណុចខ្សោយ និងចំណុចខ្លាំងរបស់គូរប្រកួតប្រជែង។ មេបណ្តាញទីមួយៗត្រូវរៀបចំអោយបានគ្រប់ ២៤ ខេត្តក្រុង ចាប់ពីខេត្តរហូតដល់ ស្រុក ឃុំ ភូមិ និងគ្រប់ផ្នែករបស់ប្រជាពលរដ្ឋ (ប្រជាពលរដ្ឋធម្មតា ម៉ូតូឌុប កម្មករ យុវជន គ្រូបង្រៀន ប៉ូលីស ទាហាន ទាំងប្រុស ទាំងស្រី)។ បើយើងប្រមូលពតិមានបានទូទាំងប្រទេសនេះ គឺមានន័យថា យើងអាចមានជ័យជំនះបាន ៥០ភាគរយ ពីព្រោះការរៀបចំឃោសនា វាអាស្រ័យទៅលើ ពតិមានដែលទទួលមកទាន់ពេលវេលា ហើយជាពតិមានពិតប្រាកដ ទើបយើងអាចធ្វើផែនការបាន។ បណ្តាញពតិមានត្រូវចងក្រង ប្រមូលពតិមានយកមកសិក្សាអោយយល់ច្បាស់។ យើងត្រូវចេះអំពីវិធីយកពតិមាន និងចំរាញ់ពតិមាន និងជ្រើសរើសយកពតិមានដែលមានផលចំណេញ ដើម្បីរាយការណ៍ពតិមាន ដែលមានប្រយោជន៍សំរាប់អង្គការនយោបាយយើង។

### ខ-ភ្នាក់ងារតាមតំបន់ (Local Intelligences)

ភ្នាក់ងារនេះ គឺជាសមាជិកនៅក្នុងតំបន់ដែលយើងជ្រើសរើសចេញពីតំបន់នោះ ដូចជាជ្រើសរើសចេញពីខេត្ត ក្រុង ស្រុក ឃុំ ភូមិ នោះ។ ភារៈកិច្ចសមាជិក ត្រូវធ្វើប្រតិបត្តិការនៅក្នុងតំបន់របស់ខ្លួននោះដដែល។ យើងត្រូវធ្វើយ៉ាងណា លើកទឹកចិត្ត បញ្ចុះបញ្ចូល ទាក់ទាញ ប្រជាពលរដ្ឋ អោយចេះស្រឡាញ់ជាតិខ្មែរ ការពារផលប្រយោជន៍ជាតិខ្មែរ បន្ទាប់មកទើបយើងជ្រើសរើសពួកគាត់ អោយចូលមកជាសមាជិកក្នុងអង្គការនយោបាយយើង។ ពេលដែលធ្វើជាសមាជិកហើយ យើងត្រូវធ្វើតាមគោលការណ៍របស់យើង ទទួលខុសត្រូវចំពោះកិច្ចការភារះកិច្ច ដែលបានប្រគល់ជូន ដូចជា ផ្តល់ពតិមាន កិច្ចការឃោសនា និងកិច្ចការជួយជាតិផ្សេងៗទៀត។ ការរៀបចំបណ្តាញ ពតិមាននៅក្នុងតំបន់នោះ ដើម្បីជួយអោយយើងធ្វើការកាន់តែមានប្រសិទ្ធភាព ដូចជាស៊ើបពតិមានសំងាត់ និងផែនការសម្ងាត់ផ្សេងៗរបស់ខ្មាំង។

ឧទាហរណ៍ កាលដែលយួនបង្កើតបក្សកុម្មុយនិស្ត យួនបានបង្កើតអោយមានបណ្តាញកុម្មុយនិស្តតាមប្រទេសនៅ ឥណ្ឌូចិន មាន លាវ និងខ្មែរ ដើម្បីអោយបំរើផែនការនយោបាយកុម្មុយនិស្តរបស់វា។ យួនបានចាប់ខ្មែរ ទៅបំពាក់បំប៉នមនោគមន៍កុម្មុយនិស្ត នៅប្រទេសយួន ហើយគេហៅពួកនេះថា ខ្មែរយៀកមិញ ខ្មែរកុម្មុយនិស្ត ដូចជា **ហ៊ុន សែន ហេង សំរិន ជា ស៊ីម** ជាដើម។

**ត -ភ្នាក់ងារក្នុងជួរ** (Inside Agents)

ភ្នាក់ងារក្នុងជួរ ជាភ្នាក់ងារដែលយើងជ្រើសរើសចេញពីគណបក្សប្រជាជន ឬភ្នាក់ងារដែលយើងជ្រើសរើសចេញពីគូរប្រកួតប្រជែងរបស់យើង ដើម្បីអោយពួកគេលួចផ្តល់ពត៌មានសម្ងាត់ និងធ្វើការអោយយើង ។ ភ្នាក់ងារនេះ គេធ្វើការនៅក្នុងគណបក្សប្រជាជនមែន តែជាអ្នកស្នេហាជាតិ និងជាអ្នកប្រឆាំងកុម្មុយនិស្តយួន **ហ៊ុន សែន** ព្រោះពួកគេគ្មានជំរើស ប៉ុន្តែ យើងមិនត្រូវអោយពួកគេដឹងកិច្ចការរបស់យើងច្រើនឡើយ ។ ភ្នាក់ងារទាំងអស់ត្រូវលាក់បាំងមិនអោយមនុស្សទី ៣ ដឹងជាដាច់ខាត ។

**ឋ -ភ្នាក់ងារស្ទួន** (Double Agent)

ភ្នាក់ងារស្ទួននេះ គឺជាភ្នាក់ងារដែលបំរើនយោបាយគូរប្រកួតប្រជែងយើងផង ជាភ្នាក់ងារបំរើនយោបាយអង្គការនយោបាយយើងផង ។ ហេតុដូច្នេះហើយ នៅពេលដែលយើងជួបនឹងភ្នាក់ងារស្ទួននេះ គឺចាំបាច់ត្រូវចេះបំភ័ន្តពត៌មាន មិនអោយគេដឹងច្បាស់ និងយកពត៌មានពីយើង ប៉ុន្តែ យើងត្រូវទទួលយកពត៌មានពីភ្នាក់ងារនេះ ។ ត្រូវចាំថា ភ្នាក់ងារបែបនេះ ច្រើនតែជាមនុស្សដែលមានលក្ខណៈលោភលន់លុយកាក់ និងសម្ភារៈ មុខមាត់ ដោយមិនមែនជាអ្នកស្នេហាជាតិពិតប្រាកដទេ ជាមនុស្សដែលគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន ។ គេនិងស្មោះចំពោះ ភាគីណាដែលយកចិត្តទុកដាក់ និងបានផលប្រយោជន៍ច្រើនជាង ។

**ង -ភ្នាក់ងារស្លាប់** (Dead agents)

ភ្នាក់ងារនេះ គឺជាភ្នាក់ងារសំរាប់បំភ័ន្តសត្រូវឬបំភ័ន្តពត៌មាន ដើម្បីអោយសត្រូវយកពត៌មានមិនពិតទៅផ្តល់អោយខាងភាគីរបស់គេ ឬក៏សំរាប់បញ្ឆោតសត្រូវអោយចូលអន្ទាក់របស់យើង ។

**ច -ភ្នាក់ងារពិសេស** (Special Intelligences)

ភ្នាក់ងារនេះ គឺជាអ្នកនាំពត៌មានមកអោយយើងវិញ និងធ្វើការយ៉ាងសកម្មបំផុតអោយយើង ។ ភ្នាក់ងារពិសេសនេះ គឺជាមនុស្សពិសេស ដែលមាននិន្នាការដូចគ្នា និងឆន្ទៈដូចគ្នា ដែលយើងទុកចិត្តជាងគេក្រោយពីធ្វើការសាកល្បង និងធ្វើកិច្ចការសំខាន់ផ្សេងៗសំរេចជោគជ័យ តាមផែនការរបស់នយោបាយយើង ។ សមាជិកប្រភេទនេះ គឺជាមនុស្សដែលស្នេហាជាតិ ស្មោះត្រង់ ប្រាកដប្រជា ទទួលខុសត្រូវ ក្លាហាន មុះមុត និងលះបង់ខ្ពស់បំផុត ។

**ឆ -កងកម្លាំងពិសេស** (Special Forces)

កងកម្លាំងពិសេសនេះ គឺជាកម្លាំងអន្តរាគមគ្រប់ស្ថានការណ៍ដែលកើតឡើង ។ គឺជាកម្លាំងដែលមុតស្រួច មុះមុត និងមានសមត្ថភាពគ្រប់យ៉ាងលើសកម្លាំងផ្សេងទៀត ។ កងកម្លាំងពិសេសនេះ ជាមនុស្សដែលមានសមត្ថភាពខាងកងទ័ព នយោបាយ និងយុទ្ធសាស្ត្រផ្សេងៗ ដែលមានជំហររឹងប៉ឹង និងស្នេហាជាតិមុតស្រួចមិនងាករេ ក្លាហានមុះមុត និងលះបង់ខ្ពស់បំផុត ។

## ៤. បរិយាកាសនយោបាយ (Political Environment)

យើងជាឃោសនិកត្រូវតែគ្រប់គ្រងស្ថានការណ៍អោយបាន យល់ដឹងទាំងអស់អំពីព្រឹត្តការនយោបាយ ដែលកំពុងកើតឡើងនៅក្នុងប្រទេសខ្មែរ ឬក្រៅប្រទេស ជាពិសេស ដំណើរវិវឌ្ឍន៍នយោបាយនៅក្នុងប្រទេសខ្មែរ។ បច្ចុប្បន្ននេះ បើយើងមើលប្រទេសខ្មែរពីសំបកក្រៅ យើងឃើញគណបក្សប្រជាជន ដែលមានយួន នៅពីក្រោយខ្នង ពួកវាកាន់អំណាចកុម្មុយនិស្តផ្តាច់ការ តែវាយកសំបកប្រជាធិបតេយ្យមកពាក់ផ្លាក បន្លំប្រជាពលរដ្ឋខ្មែរ។ តាមការពិតដំណើរការនយោបាយ និងប្រព័ន្ធគ្រប់គ្រងទាំងអស់បែបជាកុម្មុយនិស្ត ដែលស្ថិតក្រោមការត្រួតត្រារបស់យួន។ តាមការដកស្រង់ចេញពីវិបសាយ យូធូប (Youtube) **ហ៊ុន សែន** និយាយសារភាពផ្ទាល់ថា *ខ្ញុំនិយាយត្រង់តែម្តង គឺថាខ្ញុំអាយ៉ងយួន ឥឡូវមានទាហានយួន ជាស៊ីវិល ១០០ ០០០ នាក់ នៅក្នុងប្រទេសខ្មែរ*។ ការដែលយួនរៀបយុទ្ធសាស្ត្រអោយមានព្រះមហាក្សត្រ គណបក្សប្រជាជន **ហ៊ុន សែន** និង សាសនាព្រះពុទ្ធនេះគ្រាន់តែកក្តាចិត្តសាស្ត្រនយោបាយមួយ សំរាប់ធ្វើជាគំរបបិទបាំងខ្មែរ ដើម្បីអោយខ្មែរអស់ចិត្តថា អ្វីៗទាំងអស់ជារបស់ខ្មែរ ខ្មែរឯករាជ្យ ខ្មែរមានសន្តិភាព ក៏ប៉ុន្តែ ផលប្រយោជន៍ជាតិខ្មែរ ទឹកដីខ្មែរទាំងមូលនឹងត្រូវធ្លាក់លើកណ្តាប់យួន ជាតិខ្មែរនឹងស្លាប់ ប្រៀបដូចជាដង្កូវដួងវាចូលស៊ីរូង ដល់បណ្តូលឈើ ហើយទីបំផុតឈើនោះត្រូវស្លាប់ឯងតែម្តង។ យួនចូលមកប្រទេសខ្មែរ រស់នៅស្រេចតែចិត្ត ដណ្តើមផលប្រយោជន៍ខ្មែរ ត្រួតត្រាខ្មែរ ធ្វើវេច្ឆេទកម្មផ្សេងៗ កាប់សម្លាប់ខ្មែរ ដោយបន្លំធ្វើជាខ្មែរ មានអត្ត សញ្ញាណប័ណ្ណជាខ្មែរ និងមានសិទ្ធិបោះឆ្នោត។ ប្រជាពលរដ្ឋខ្មែរពិតប្រាកដ ក្រីក្រ រហេមរហាម សុំទានគេ ហើយខិតខំធ្វើការជាខ្ញុំបំរើគេ ជាកម្មករសំណង់ផ្សេងៗ ទទួលប្រាក់ខែតិចតួចមិនបានគ្រប់គ្រាន់ខ្លះទៀតរត់មកសុំទានគេ ខ្លះធ្វើជាកម្មករនៅក្រៅប្រទេសទៀតផង។




**ប្រទេសខ្មែរស្ថិតក្រោមអាណានិគមន៍កុម្មុយនិស្តយួន** ដែលមាន **គណបក្សប្រជាជន** **ហ៊ុន សែន** និង **ស្តេច** ជារនាំងបិទបាំង

## ក-គណបក្សនយោបាយ (Political Parties)

គណបក្សប្រជាជន គឺជាគណបក្សដែលយួនជាអ្នកបង្កើតឡើង មានរយៈពេល ៥៧ ឆ្នាំហើយ ដំបូងយួនបានដាក់ឈ្មោះ **បក្សបដិវត្តប្រជាជនខ្មែរ** នៅឆ្នាំ១៩៥១ ឬសគល់របស់វាកើតចេញពីបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលយួន **ហូ ជីមិញ** បានបង្កើតនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៣០ នៅទីក្រុង ហុង កុង។ ហេតុដូចច្នេះ **គណបក្សប្រជាជន** ជាអ្នកបំរើ និងធ្វើជាអាយ៉ង អនុវត្តតាមនយោបាយរបស់យួន។ ពួក **ហ៊ុន សែន** បំរើផលប្រយោជន៏អោយយួន ដើម្បីអំណាចលួចជាតិ លក់ជាតិឯងតែប៉ុណ្ណោះ។ ពួក **ហ៊ុន សែន ជា ស៊ីម** និង **ហេង សំរិន** នេះជាមនុស្សរបស់យួនដែលបានលើកបន្តុបអោយកាន់អំណាចកាលពីទសវត្ស ១៩៨០ ពេលដែលយួនចូលមកឈ្លានពានទឹកដីខ្មែរនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី៣ (អំឡុងពេលសង្គ្រាមត្រជាក់)។ បើសិនជា **ហ៊ុន សែន** មិនធ្វើតាមនយោបាយយួន វាសនារបស់ពួកនេះ នឹងដូច **ចាន់ ស៊ី (ចាក់ថ្នាំសម្លាប់លើ យន្តហោះ) ប៉ែន សុវណ្ណ (យួនចាប់នៅដាក់គុក នៅហាណូយ)** ជាមិនខាន។ ហេតុដូច្នេះហើយ បានជាយួនបង្កើតជាគោលការណ៍នយោបាយ មិត្តភាព សន្តិភាព និងសហប្រតិបត្តិការ រវាងយួន និងខ្មែរ ដើម្បីបំភ័ន្តប្រជាពលរដ្ឋខ្មែរថា យួនជាអ្នកមានគុណលើខ្មែរ។ តែតាមពិត ខ្មែរនៅក្រោមការត្រួតត្រារបស់យួន។ យួនប្រើល្បិចសម្លាប់ទាំងខ្មែរក្រោម ទាំងខ្មែរសព្វថ្ងៃ ខ្មែរមិនមានឯករាជ្យ ខ្មែរគ្មានសិទ្ធិសេរីភាពពេញលេញ ខ្មែរបាត់បង់ផលប្រយោជន៏ជាច្រើន ដូចជា កាត់ទឹកដីអោយយួន ចុះហត្ថលេខាសន្ធិសញ្ញាបំពេញបន្ថែមជាមួយយួន នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៥ លើសន្ធិសញ្ញាខុសច្បាប់ ឆ្នាំ ១៩៧៩ ១៩៨០ ១៩៨៣ ១៩៨៥។ ខ្មែរគ្មានសិទ្ធិក្នុងការនិយាយស្តីពេញលេញអំពីប្រទេសជាតិ ត្រូវយួនប្រើ **ហ៊ុន សែន** គំរាម សម្លាប់តាមគ្រប់មធ្យោបាយ ទាំងសេដ្ឋកិច្ច ស្មារតី និងអាយុជីវិត។ ជនជាតិយួន ចូលមករស់នៅក្នុងទឹកដីខ្មែរគគ្រឹកគគ្រេង បង្កើតសមាគម ១៩ ខេត្តក្រុង បង្កើតគណបក្សនយោបាយ (**គណបក្សចំរើនខ្មែរ គណបក្ស ប្រជាធិបតេយ្យ**) ជាដើម។ យួនបានប្រើពួកយួនដែលចេះខ្មែរ ឬប្រើខ្មែរខ្លះអោយទិញដី ដណ្តើមដីដោយស្របច្បាប់ ពីប្រជាពលរដ្ឋខ្មែរ ក្រោមលេសថា **វិនិយោគ** និង **អភិវឌ្ឍន៏**។ ការបាត់បង់ដីធ្លីនេះ បានធ្វើអោយប៉ះពាល់ដល់ ជីវភាពប្រជាពលរដ្ឋខ្មែរយ៉ាងខ្លាំង ពីព្រោះថា ប្រជាពលរដ្ឋខ្មែរសង្ឃឹមលើទឹកភ្លៀង និងមានដីស្រែចំការបន្តិចបន្តួច ដែលជាឆ្នាំងបាយ ដើម្បីចិញ្ចឹមក្រពះ។ ពេលដែលគេរំលោភគំរាម ដណ្តើមដីធ្លីរបស់គាត់ហើយ តើប្រជាពលរដ្ឋខ្មែរ បានអ្វីសំរាប់ចិញ្ចឹមជីវិត ចំអែតក្រពះ ដើម្បីរស់តទៅទៀត។ ដូច្នេះ ពួកជនកុម្មុយនិស្ត វាពូកែខាងភូតភរកុហក បំភ័ន្តភ្នែក អោយប្រជា-ពលរដ្ឋខ្មែរ យល់ច្រឡំវង្វេងណាស់។ ព្រោះវាសម្លាប់អ្នកចេះអស់ហើយ អ្នកដែលនៅរស់ជាអ្នកដែលមិនបានសិក្សារៀនសូត្រជ្រៅជ្រះ ហើយត្រូវលង់ក្នុងមនោគមន៏របស់យួន ដែលវារៀបចំមក។ វាធ្វើអ្វីគ្រប់យ៉ាងតាមគោលការណ៏នយោបាយរបស់យួន ច្បាប់ធ្វើឡើងដើម្បីការពារអំណាច និងផលប្រយោជន៏អ្នកមានអំណាច មិនមែនការពារផលប្រយោជន៏ជាតិខ្មែរទេ។ ច្បាប់មានតែលើក្រដាស តែវាមិនអនុវត្តតាមឡើយ និយាយអោយចំ បើអ្នកស្នេហាជាតិខ្មែរណាដែលហ៊ានប្រឆាំងនយោបាយយួន ពួកវាត្រូវបញ្ជាអោយកូនអុកវា គឺ **ហ៊ុន សែន** តាមចាប់ បង្រ្កាប សម្លាប់ភ្លាម ឧទាហរណ៏ដូចជា **ជា វិជ្ជា** ព្រះតេជគុណ **សំ ប៊ុនធឿន** អ្នកការសែតខ្មែរ

ព្រះសង្ឃខ្មែរក្រោម សមាជិកគណបក្សសមរង្សី និងសមាជិកគណបក្សកឹមសុខា ដោយគ្មានរកឃាតករឃើញទេ រហូតមកដល់បច្ចុប្បន្ន។ តែបើយួនស្លាប់នៅលើទឹកដីខ្មែរវិញ **ហ៊ុន សែន** និងបក្សពួកស្រែកក្តែងៗ តាមប្រដាប់បំពងសម្លេង ខ្វាយខ្វល់ខ្លាំងណាស់ អោយរកឃាតករ មកផ្តន្ទាទោសអោយបាន។

ចំណែកគណបក្សនយោបាយផ្សេងៗ ដែលជាអ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យ យួនវាបញ្ជាអោយ **ហ៊ុន សែន** រកវិធីសម្លាប់ផ្សេងៗ តាមរបៀបភាវរកម្ម បំបែកបំបាក់ខ្មែរខ្ទេចខ្ទី។ **ហ៊ុន សែន** លោភអំណាច និងទ្រព្យសម្បត្តិ លង់មនោគមន៍កុម្មុយនិស្តយួន ភ្លេចគិតអំពីជាតិខ្មែរ និងឈាមខ្មែរដូចគ្នា ធ្វើតាមយួនប្រើល្បិចដូចសម័យ **ប៉ុល ពត** ដែលវាបានសម្លាប់ខ្មែររាប់លាននាក់កន្លងមក។ វាធ្វើយ៉ាងនេះ គឺធ្វើអោយខ្មែរយើងទន់ខ្សោយគ្រប់បែបយ៉ាង តាំងពីសេដ្ឋកិច្ច ប្រាជ្ញា និងស្មារតី (ឃ្លាន ខ្លៅ ខ្លាច) ដើម្បីងាយស្រួលយួនត្រួតត្រា ដណ្តើមផលប្រយោជន៍ខ្មែរ ហើយទីបំផុត យួនលេបយកទឹកដីខ្មែរទាំងមូលដោយវិធីត្រជាក់បំផុត។ យួនគ្រាន់តែលើកបន្តុបពួកលោភអំណាច បុណ្យស័ក្តិ មុខមាត់សម្ភារៈ ពួកលួចជាតិ ដើម្បីផលប្រយោជន៍ខ្លួន អោយធ្វើជាគំរបបិទបាំងជាតិខ្មែរ ប្រជាជាតិខ្មែរ និងអន្តរជាតិតែប៉ុណ្ណោះ។ *ដូច្នេះគ្មាននណាអាចជួយខ្មែរក្រៅពីខ្មែរជួយខ្មែរខ្លួនឯងឡើយ* ។

គណបក្សប្រឆាំងទាំងអស់ ត្រូវបានគណបក្សប្រជាជន **ហ៊ុន សែន** ប្រើល្បិចកុម្មុយនិស្តបំបែកជាគណបក្សតូចៗ ដែលមិនអាចយកជ័យជំនះលើគណបក្សរបស់វាបានឡើយ ព្រោះគណបក្សប្រជាជនមានកងទ័ពទាហានយួន និងប្រជាជនយួនសំរាប់ជួយ។ គណបក្សប្រជាជនមានប្រៀបខាងសេដ្ឋកិច្ច ខាងឃោសនា ដោយសារពួកវាលក់ជាតិ និងលួចពីជាតិខ្មែរជាច្រើនឆ្នាំមកហើយ។ ប្រព័ន្ធពតិមានស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងរបស់ពួកវា ពតិមានមិនឯករាជ្យ ពតិមានធ្វើតាមនយោបាយរបស់ពួកកុម្មុយនិស្ត។ ពួកគេបានបិទបាំងប្រជាពលរដ្ឋខ្មែរមិនអោយដឹងការពិត បិទសិទ្ធិសេរីភាពប្រជាពលរដ្ឋខ្មែរមិនអោយតវ៉ាជាដើម។ ដូច្នេះបើយើងវិភាគលើគណបក្សដទៃទៀត មិនអាចយកឈ្នះលើគណបក្សប្រជាជន ដែលបំរើនយោបាយអោយយួនទេ តែវាក៏អាចបង្អាក់ដំណើរនយោបាយយួន និងជួយអោយខ្មែរភ្ញាក់រលឹកមួយចំនួនដែរ។ បើសិនជាគណបក្សណាមួយឈ្នះឆ្នោតក្រៅពីបក្សប្រជាជន ក៏យួនបញ្ជាអោយ **ហ៊ុន សែន** ធ្វើវទ្ទង្សនាដោយមានការអន្តរាគមន៍ជំនួយពី ស្តេច **សីហនុ** ឬរដ្ឋប្រហារ ដូចកាលពី **ហ៊ុន សែន** ចាញ់ឆ្នោតកាលពីឆ្នាំ ១៩៩៣ ហើយវាធ្វើរដ្ឋប្រហារសម្លាប់អ្នកស្នេហាជាតិខ្មែរ នៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ បន្តទៀតតាមផែនការយួន។ ហេតុនេះ គណបក្សនយោបាយផ្សេងៗទៀតនោះ បង្កើតឡើងគ្រាន់តែសំរាប់ចំណេញនយោបាយយួន និង **ហ៊ុន សែន** អោយប្រជា-ពលរដ្ឋខ្មែរមើលឃើញថា ជាប្រទេសឯករាជ្យ មានប្រជាធិបតេយ្យ សន្តិភាព តែប៉ុណ្ណោះ។ ប៉ុន្តែបើយើងជាអ្នកស្នេហាជាតិខ្មែរពិតប្រាកដរួបរួមគ្នាជាធ្លុងមួយ ទើបយើងអាចឈ្នះយួនកុម្មុយនិស្ត។ *ប្រៀបដូចទឹកហូររួមពីដៃទន្លេផ្សេងៗ ចូលសមុទ្រដែលគ្មានអ្វីមករារាំងបានឡើយ*។ បើគណបក្សណា ឬអ្នកស្នេហាជាតិខ្មែរណាចង់ធ្វើនយោបាយនៅប្រទេសខ្មែរ ត្រូវធ្វើតាមគំនូសនយោបាយរបស់គណបក្សប្រជាជន ក្រោមការត្រួតត្រារបស់យួនដែលវាស់ក៏រិតអោយនិយាយ អោយអនុវត្ត។ ព្រោះយួនមានផែនការ តាមយុទ្ធសាស្ត្រមិនអាចទុកអោយគណបក្សណាយកជ័យជំនះលើវាបានឡើយ។ *យើងមើលឃើញយ៉ាងច្បាស់ថា ប្រទេសខ្មែរសព្វថ្ងៃ* ជាប្រទេស

កុម្មុយនិស្ត *ស្ថិតនៅក្រោមអាណានិគមន៍យួនបែបថ្មី។* ដូច្នេះហើយ វាសនាអនាគតជាតិខ្មែរ នឹងដូចចម្ប៉ា និង កម្ពុជាក្រោមមិនខានឡើយ បើយើងមិនតស៊ូរើបំរះ។






**ប្រធានបក្ស សមរង្ស៊ី** **ប្រធានបក្ស សិទ្ធិមនុស្ស** **ប្រធានបក្ស នរោត្តមរណឫទ្ធិ** **គណបក្ស ប្រជាជនកម្ពុជា**

## ៩-កាត់ទោសខ្មែរក្រហម (Khmer Rough Tribunal)

សាលាក្តីខ្មែរក្រហមនេះ បង្កើតឡើងគ្រាន់តែជាល្បែងនយោបាយរបស់ពួកកុម្មុយនិស្ត ដែលមាន **ហ៊ុន សែន** គណបក្សប្រជាជនជាកូនអុក ហើយលាក់បាំងកំហុស **សី ហនុ** ទុកធ្វើជារនាំង សំរាប់គោលដៅចុងក្រោយរបស់យួន ដែលចង់លេបយកទឹកដីខ្មែរប៉ុណ្ណោះ។ វារឹតតែធ្វើអោយខ្មែរកាន់តែវង្វេងជ្រៅទៅ មិនអាចរកឃាតករពិតប្រាកដឃើញទៀតផង។ តែយើងជាជនរងគ្រោះខ្មែរគ្រប់គ្នាដឹងច្បាស់ថា ឃាតករពិតប្រាកដ គឺពួកកុម្មុយនិស្តយួន (ឥណ្ឌូចិន) ដែលបានរៀបចំ និងបំពាក់បំប៉នលទ្ធិនេះឡើងអោយខ្មែរ (ក្រហម) ធ្វើអោយប្រជាពលរដ្ឋខ្មែរស្លាប់រាប់លាននាក់ ទាំងខ្មែរក្រោម និងខ្មែរបច្ចុប្បន្ន ហើយយួនបញ្ជូនពលរដ្ឋខ្លួនមកជំនួស ធ្វើជាខ្មែរថ្មីលើទឹកដីខ្មែរវិញ។ **សី ហនុ** និង **ហ៊ុន សែន** ជាជនកុម្មុយនិស្តបំរើនយោបាយអោយកុម្មុយនិស្ត ដើម្បីអំណាច និងផលប្រយោជន៍ផ្ទាល់ខ្លួនឯងនិងបក្សពួកតែប៉ុណ្ណោះ តែជនកុម្មុយនិស្តទាំងនេះ មិនបានបំរើផល-ប្រយោជន៍អោយជាតិខ្មែរ និងប្រជាពលរដ្ឋខ្មែរទេ។ ហេតុដូច្នេះ កុំសង្ឃឹមថា សាលាក្តីខ្មែរក្រហម និងទទួលបានយុត្តិធម៌ពិតប្រាកដ ព្រោះថា សាលាក្តីនេះដើរក្នុងគំនាបនយោបាយរបស់គណបក្សប្រជាជន ដែលមានយួនជាមេក្លោង។ យួនវាមិនចង់រកយុត្តិធម៌អោយជនរងគ្រោះខ្មែរពិតប្រាកដទេ។ ប៉ុន្តែ សាលាក្តីនេះជាយុទ្ធសាស្ត្រនយោបាយរបស់ពួកកុម្មុយនិស្តយួន ជាអ្នកចំណេញប៉ុណ្ណោះ ( ១-ខ្មែរនៅតែបែកបាក់គ្នា ឈឺចាប់និងខ្មែរ (ក្រហម) ប៉ុល ពត ២-ដឹងគុណ ៧ មករា យួន ហ៊ុន សែន ៣-ប្រជាពលរដ្ឋខ្មែរ នៅតែមិនដឹងការពិតថានរណាជាឃាតករពិតប្រាកដ ៤-បើកឱកាសអោយយួនកុម្មុយនិស្តត្រួតត្រាខ្មែរបន្ត )។

សាលាក្តីនេះកើតឡើងហើយ តែអូសបន្លាយពន្យាពេល វាគ្រាន់តែជាថ្នាំបន្សាបធ្វើអោយប្រជាពលរដ្ឋខ្មែរ ដែលជាជនរងគ្រោះអស់ចិត្តទាំងអយុត្តិធម៌ប៉ុណ្ណោះ ព្រោះការពិតនៅតែមិនបានលាតត្រដាងអោយប្រជាពលរដ្ឋខ្មែរដឹងច្បាស់ឡើយ ថានរណាជាឃាតករសម្លាប់ខ្មែរ មានន័យថា កាំបិតមិនអាចចិតដងខ្លួនឯងឡើយ។ ថ្ងៃ ១៧ មេសា ១៩៧៥ គឺពួកកុម្មុយនិស្ត ដែលយួនលើកអំណាចអោយខ្មែរ (ក្រហម) ដូចគ្នានិង ថ្ងៃ ៧ មករា ១៩៧៩ ដែលពួកកុម្មុយនិស្តយួនឈ្លានពាន លើកបន្ទុបអំណាចខ្មែរ **ហ៊ុន សែន ជា ស៊ីម** និង **ហេង**

**សរិន** ដែរ ចំណែកឯ **សី  ហនុ** ដែលធ្លាប់ធ្វើជាមេខ្មែរក្រហម បង្កើតខ្មែរក្រហម ក៏មិនហ៊ានចេញមកសារភាពទទួលកំហុសទៀត។

ដូច្នេះ សាលាក្តីនេះធ្វើអោយចំណេញ នយោបាយ ៧ មករា របស់យួន ដែលតែងតែលើកឡើងថាយួនមកជួយរំដោះខ្មែរ និងរឹតតែធ្វើអោយខ្មែរវង្វេងកាន់តែជ្រៅ ក្នុងអន្លង់មនោគមន៍កុម្មុយនិស្ត ប្រទេសខ្មែរនៅតែស្ថិតនៅក្រោមកណ្តាប់ដៃរបស់ពួកកុម្មុយនិស្ត ដែលមានយួនជាមេក្លោង។ អន្តរជាតិដែលចង់រកយុត្តធមិអោយប្រជាពលរដ្ឋខ្មែរ និងចង់បំបាត់និទន្តភាព បានចំណាយលុយឥតប្រយោជន៍មកអោយពួកជនពុករលួយ។ ជនទទួលខុសត្រូវកំពូល ជាថ្នាក់ដឹកនាំខ្មែរ (ក្រហម)ពិតប្រាកដ មិនបានយកមកផ្តន្ទាទោសទេ ធ្វើឡប់ឡែរបោកប្រាស់ប្រជាពលរដ្ឋខ្មែរ អោយរងទុក្ខវេទនា ដោយរបបកុម្មុយនិស្ត ដែលយួនលើកបន្តុបដាក់លើប្រទេសខ្មែរតាំងពីរបបខ្មែរក្រហម រហូតមកដល់បច្ចុប្បន្ន។ សរុបមក គោលដៅផលប្រយោជន៍ចុងក្រោយនៃលទ្ធិកុម្មុយនិស្តគឺចំណេញទៅយួន ដែលចង់លេបយកទឹកដីខ្មែរ ដាក់ប្រទេសខ្មែរជាចំណុះរបស់យួន។









**បើចង់រកយុត្តធម៏អោយខ្មែរ ត្រូវកាត់ទោស ប៉ុល ពត និង សីហនុ ហ៊ុន សែន យួន ចិន ដែរ**

### គ-ជម្លោះដីធ្លី (Land Conflict)

ដើម្បីអោយជាតិខ្មែរធ្លាក់ខ្សោយទាំងខាង សេដ្ឋកិច្ច យោធា នយោបាយ និងកេរ្តិ៍ឈ្មោះ សំរាប់ធ្វើអោយយួនងាយស្រួលបំពេញគោលដៅ ក្នុងការកាន់កាប់ត្រួតត្រាលេបយកទឹកដីខ្មែរបាន យួនតែងតែប្រើយុទ្ធសាស្រ្តវាយលុកគ្រប់មធ្យោបាយមកលើប្រទេសខ្មែរយើងជាបន្តបន្ទាប់ ដូចជាយួនចាប់ផ្តើមដុតអោយមានសង្គ្រាមនៅលើទឹកដីខ្មែរនៅឆ្នាំ (១៩៦៤-១៩៧៥) ធ្វើអោយខ្មែរកាប់សម្លាប់ចលាចលនៅចន្លោះឆ្នាំ (១៩៧៥-១៩៧៩) ចូលមកត្រួតត្រា ឈ្លានពានទឹកដីខ្មែរ ប្លន់ទ្រព្យសម្បត្តិពីឆ្នាំ(១៩៧៩-១៩៩១) ដោយយួនបានត្រួតត្រាខ្មែរតាមរូបភាព ***ខ្លាពាក់ស្បែកលា*** ។ យួនយកអាវគណបក្សប្រជាជន ប្រជាធិបតេយ្យ ស្តេច ពាក់បំភាន់ភ្នែកប្រជាពលរដ្ឋខ្មែររហូតដល់បច្ចុប្បន្ន)។ យួនប្រើ **ហ៊ុន សែន** បន្តដាក់បញ្ហាមកលើខ្មែរ ជាបន្តបន្ទាប់មិនព្រមដោះស្រាយ ដូចជា បញ្ហាជនអន្តោប្រវេសន្តយួន បញ្ហាពុករលួយ ទំនិញឡើងថ្លៃ ការសម្លាប់ម្តងមួយជាបន្តបន្ទាប់រីបអូសដីធ្លី និងកាប់ព្រៃឈើយកទៅស្រុកយួនជាដើម។ យួនយកលុយមកជិរតទិញដីប្រជាពលរដ្ឋខ្មែរដែលក្រីក្រ

ដោយយកឈ្មោះក្រុមហ៊ុន ជាលេសថា វិនិយោគ និងអភិវឌ្ឍន៍។ បញ្ហាទាំងអស់នេះ ពួកត្រួតត្រា **ហ៊ុន សែន** មិនព្រមដោះស្រាយទេ ទីបំផុត ទឹកដីខ្មែរទាំងនេះនឹងក្លាយទៅជាកម្មសិទ្ធិយួន ចំណែកខ្មែរមានតែសម្បកប្រទេសឈ្មោះថា **កម្ពុជា** តែប៉ុណ្ណោះ។ យួនមិនចាំបាច់ធ្វើសង្គ្រាមបង្ហូរឈាមដណ្តើមយកដីខ្មែរដូចកាលមុនៗទៀតឡើយ នេះហើយគេហៅថា **នយោបាយត្រជាក់**។ តាមទ្រឹស្តី **ស៊ុន ស៊ូ** អ្នកដែលពូកែខាងយុទ្ធសាស្ត្រ គឺ *មិនមែនអ្នកដែលច្បាំងឈ្នះ សត្រូវរាប់រយសមរភូមិនោះទេ តែគឺជាអ្នកឈ្នះសត្រូវដោយមិនចាំបាច់ប្រយុទ្ធ ឬឈ្នះសត្រូវដោយគ្មានឈាមហូរមួយដំណក់ ឬឈ្នះសត្រូវដោយមិនខូចខាតសម្ភារៈអ្វីបន្តិចសោះឡើយ។*

ដើម្បីអោយប្រជាពលរដ្ឋខ្មែរលក់ដីអោយយួន យួនបានប្រើយួនដែលចេះខ្មែរ ឬខ្មែរដែលបំរើវា យកលុយដុល្លាមកទិញដី ដំឡើងដីអោយថ្លៃ ធ្វើអោយអ្នកមានអំណាចរឹបអូសដីកសិករក្រីក្រ យកទៅលក់អោយពួកវា បើទោះជាមិនចង់លក់ ក៏ពួកវាប្រើល្បិចផ្សេងៗ ដើម្បីទិញ ដូចជាគំរាមអោយលក់ បើមិនអញ្ចឹងទេ វារឹបអូសយកទទេៗ។ តាមយុទ្ធសាស្ត្រកុម្មុយនិស្តយួន វា*កាត់ផ្តាច់ស្បៀង កាត់ផ្តាច់ហិរញ្ញវត្ថុ លុយ និងកាត់ផ្តាច់ សម្ភារៈពីសត្រូវ* (ខ្មែរ) ដើម្បីអោយខ្មែរខ្សោយ។ បើប្រជាពលរដ្ឋខ្មែរ មិនលក់ដីអោយពួកវា គាត់ខ្លាចបាត់បង់ទទេ ហេតុដូចនេះ គាត់លក់ទាំងស្តាយទាំងចិត្តខ្លោចផ្សារ ព្រោះដីនេះហើយជាឆ្នាំងបាយរបស់គាត់។ យួនប្រើល្បិចក្រោមរូបភាពផ្សេងៗទៀត ធ្វើអោយខ្មែរធុញទ្រាន់ ដោយបង្កបញ្ហាផ្សេងៗដូចជា គេទិញដីដែលហ៊ុំព័ទ្ធជុំវិញដីរបស់គាត់ហើយ ទើបគេបង្ខំអោយគាត់លក់ បើមិនលក់ គាត់គ្មានផ្លូវចូលទៅដីគាត់ បញ្ឆោតអោយផ្តិតមេដៃថាអញ្ចេះអញ្ចុះ រួចហើយពួកគេបានលេស ឆ្លើយទំលាក់កំហុសថា ប្រជាពលរដ្ឋជាអ្នកលក់ដីអោយវាវិញ ឬវាបង្ករអោយមានជម្លោះរឿងរ៉ាវជាដើម។ ខ្មែរត្រូវផ្លាស់ចេញពីតំបន់សំខាន់ៗ ដូចជា តំបន់សេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយ ទៅកន្លែងដែលដាច់ស្រយាល កាប់ព្រៃរស់នៅតាមទីជនបទជាដើម ឬ ពួកវាចោទ គំរាម តាមចាប់ តាមសម្លាប់អោយរត់ចោលប្រទេសជាតិជាដើម។ ប្រជាពលរដ្ឋខ្មែរដែលមានចំនួន ៨៥ ភាគរយ ជាកសិករកាន់តែក្រីក្រយ៉ាប់យ៉ឺន ស្រែកហៅរកអ្នកជួយរកយុត្តិធម៌ តែពួក ហ៊ុន សែន មិនដោះស្រាយជូនខ្មែរឡើយ។ ជាក់ស្តែង ប្រជាពលរដ្ឋខ្មែរទាំងក្មេងចាស់ បានដើរតាំងពីខេត្តបាត់ដំបងមកផ្ទះ **ហ៊ុន សែន** នៅតាខ្មៅ ខេត្តកណ្តាល ដើម្បីអោយជួយ តែទីបំផុតត្រូវអង្គរក្ស **ហ៊ុន សែន** វាយធ្វើបាបបែកក្បាល ចំណែកឯ **ហ៊ុន សែន**វិញ បែរទៅការពារពួកឈ្មួញវិនិយោគយួនវិញ ដោយនិយាយថា *កុំនិយាយរឿងដីធ្លី ពីព្រោះខ្លាចប៉ះពាល់រឿងជាតិ។*

ការដែលដីឡើងថ្លៃមកពីមានកំណើនប្រជាពលរដ្ឋ ប៉ុន្តែតាមពិតកំណើននោះ វាមិនមែនជាកំណើនចំនួនប្រជាពលរដ្ឋខ្មែរទេ គឺកំណើនជនជាតិយួន ដែលវាចូលមកនៅក្នុងតំបន់សំខាន់ៗ ដូចជាសេដ្ឋកិច្ច បឹងទន្លេសាប ភ្នំពេញ ក្រុងព្រះសីហនុ កំពង់ចាម មាត់ទន្លេមេគង្គ សៀមរាប ប៉ោយប៉ែត ដែលជាបេះដូងខ្មែរ។ ពួកវារៀនភាសាខ្មែរអោយចេះ វាផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងផ្សេងទៀត ធ្វើជាអ្នកចំណូលខ្មែរថ្មីដោយខ្មែរយើងស្រុកស្រែចំការមិនបានយល់ដឹងពីបញ្ហានេះឡើយ។ ចំណែកប្រទេសខ្មែរមានប្រជាពលរដ្ឋតិចស្រាប់ វាប្រើនយោបាយផ្សព្វផ្សាយអោយប្រជាពលរដ្ឋខ្មែរ យើងពន្យាកំណើតទៅវិញ។ *នេះហើយជា នយោបាយយួនទួបនិយកម្មនៅលើទឹកដីខ្មែរ។*

## យ-អំពើពុករលួយ (Corruption)

អំពើពុករលួយជាជម្ងឺមួយយ៉ាងសាហាវ ដែលកំពុងរាតត្បាតក្នុងសង្គមខ្មែរបច្ចុប្បន្ន ព្រោះជនផ្តាច់ការកញ្ជះបរទេស **ហ៊ុន សែន** ល្មោភអំណាចបំរើផលប្រយោជន៍យួន គ្មានឆន្ទៈដោះស្រាយបំបាត់អំពើពុករលួយអោយអស់ក្នុងសង្គម ខ្មែរទាល់តែសោះ។ ជនផ្តាច់ការ **ហ៊ុន សែន** គ្មានចេតនាដោះស្រាយបញ្ហាដែលកំពុងប្រឈមមុខចំពោះសង្គមខ្មែរទេ ថែមទាំងបង្កើតបញ្ហាអោយកាន់តែច្រើនទៀតដូចជា ការដណ្តើមដីធ្លីប្រជាពលរដ្ឋក្រីក្រ ចេតនាធ្វើដូចនេះ គឺគេមានបំណងអោយប្រជាជាតិខ្មែរកាន់តែក្រ និងខ្សោយទៅៗ ងាយស្រួល **ហ៊ុន សែន** បន្តកាន់អំណាច បំផ្លាញជាតិ លាក់បាំងកុំហុសមេដឹកនាំមួយចំនួន ដែលធ្វើខុសចំពោះជាតិខ្មែរកន្លងមក ជាពិសេស **ហ៊ុន សែន** មានចេតនារក្សាការពាររបបកុម្មុនិស្តក្រោមឥទ្ធិពលយួនអោយស្ថិតស្ថេរនៅលើប្រទេសកម្ពុជា ជាអមតៈ។

អំពើពុករលួយនេះជាឫសគល់ ធ្វើអោយប្រជាពលរដ្ឋខ្មែរស្ថិតនៅក្នុងភាពក្រីក្រ ហើយអ្នកក្រកាន់តែក្រទៅៗ ជាពិសេស អ្នកស្រុកស្រែចំការកាន់តែមានជីវភាពក្រីក្រ គ្មានលទ្ធភាពរៀនសូត្រជ្រៅជ្រះ មានស្មារតីទន់ខ្សោយទៅៗ គិតតែរឿងជីវភាព លង់ជឿការបោកប្រាស់របស់ពួកផ្តាច់ការ **ហ៊ុន សែន** ដែលបាននឹងកំពុងបំផ្លាញផលប្រយោជន៍ជាតិ ដូចជួយពង្រឹងអំណាចអោយជនផ្តាច់ការថែមទៀតប៉ុណ្ណោះ។

អំពើពុករលួយជាទុនមួយសំរាប់ពង្រឹងអំណាចបក្សពួក **ហ៊ុន សែន** អោយកាន់តែរឹងមាំ និងមានជីវភាពធូរធារ តែប្រជាពលរដ្ឋខ្មែរកាន់តែក្រីក្រទៅ បាក់ស្បាតមិនអាចងើបឡើងប្រឆាំងតទល់និងការគៀបសង្កត់របស់ពួកមានអំណាច ដែលយកការដឹកនាំតាមរបៀបកុម្មុយនិស្ត ក្រោមអាណានិគមយួន។

អំពើពុករលួយធ្វើអោយបាត់បង់ថវិកាជាតិ ក្នុងមួយថ្ងៃរហូតទៅដល់ ១ លាន ដុល្លា ហើយបើគិតក្នុងមួយឆ្នាំជាមធ្យមត្រូវបាត់បង់ចំនួន ២៥០លានដុល្លា ទៅ៣០០លានដុល្លា។ តើលុយអស់ទាំងនោះជារបស់នរណា? លុយទាំងនោះជារបស់ជាតិខ្មែរ មិនមែនជារបស់បក្សពួក **ហ៊ុន សែន** នោះទេ តើគេមានប្រាក់ខែប៉ុន្មាន ? បានមាន ឡាន វីឡា និង ស្រីយួន ចំណែកមន្រ្តីរាជការ លោកគ្រូ អ្នកគ្រូ កម្មករ ដែលមិនមែនបក្សពួក **ហ៊ុន សែន** ប្រាក់ខែតិចតួច មិនគ្រប់គ្រាន់ ហើយកាន់ក្រីក្រទៅវិញ។

រដ្ឋាភិបាលផ្តាច់ការ **ហ៊ុន សែន** ទទួលបានជំនួយ និងខ្ចីបរទេសរាប់លានដុល្លាក្នុងមួយឆ្នាំៗ តើលុយទាំងនោះពួក **ហ៊ុន សែន** យកទៅណា? លុយទាំងអស់នោះជាលុយរបស់ជាតិខ្មែរ ឬជារបស់ **ហ៊ុន សែន** តែម្នាក់ឯង បានជានាំគ្នាលួចយកទ្រព្យសម្បត្តិជាតិ យកទៅដាក់នៅធានាគារក្រៅប្រទេស រាប់លានដុល្លា តែទុក្ខវេទនាត្រូវធ្លាក់លើប្រជាពលរដ្ឋខ្មែរទូទៅ ជាអ្នកសងវិញ។ ដូច្នេះ ប្រជាពលរដ្ឋខ្មែរត្រូវជំពាក់បំណុលបរទេសយ៉ាងហោចណាស់ ១៥០០ ដុល្លាក្នុងម្នាក់។

បញ្ហាទាំងអស់នេះ គឺជាគំនិតដ៏ខ្មៅក្រខ្វក់របស់ជនផ្តាច់ការ **ហ៊ុន សែន** បំរើយួន មានចេតនាធ្វើអោយជាតិខ្មែរ ក្រ និង ខ្សោយ ដើម្បីបន្តអំណាចផ្តាច់ការបំផ្លាញជាតិ និងបំរើផលប្រយោជន៍អោយយួនតែប៉ុណ្ណោះ។

## ៥_ទំនោរ និងនិន្នាការប្រជាពលរដ្ឋ (Emotion and Trend of People)

ចំណុចត្រង់នេះមានសារៈសំខាន់ណាស់ ពីព្រោះថា អង្គការនយោបាយយើង តាមគោលការណ៍ គឺយើងធ្វើអ្វីផ្តោតលើផលប្រយោជន៍ ជាតិ សាសនា ប្រជាជាតិខ្មែរ ។ យើងត្រូវតែសិក្សាអោយដឹងច្បាស់អំពីឥរិយបថ ទំនោរ និន្នាការប្រជាពលរដ្ឋ ដើម្បីងាយស្រួលយើងចេញគោលនយោបាយ ឬឃោសនាមានប្រសិទ្ធភាព ។ យើងត្រូវដឹងអំពីចំនួនប្រជាពលរដ្ឋ ប្រុស ស្រី អាយុ កំរិតសិក្សាអប់រំ កំរិតជីវភាព មុខរបរ ទំនៀមទំលាប់ប្រពៃណីជាដើម ។ ទំនោរនយោបាយប្រឆាំងរដ្ឋាភិបាល ឬគាំទ្ររដ្ឋាភិបាល ។ ចំពោះអ្នកដែលបាន ផលប្រយោជន៍ពីរដ្ឋាភិបាលតែងតែគាំទ្រពួកត្រួតត្រា **ហ៊ុន សែន** ។ ចំពោះប្រជាពលរដ្ឋខ្មែរ ពេលបច្ចុប្បន្ននេះ យើងត្រូវឃោសនាផ្អែកចិត្តសាស្រ្តមុនគេបង្អស់ ។ ប្រជាពលរដ្ឋខ្មែរ ស្រឡាញ់ចូលចិត្តចំពោះបុគ្គលណា ដែលមាន សុជីវធម៌ សីលធម៌ ស្គាល់ចាស់ទុំ និងខ្ពស់ទាប ។ ដូចនេះ យើងជាឃោសនិកត្រូវមានសុវជីវធម៌ សីលធម៌ អោនលំទោន គោរពអោយតំលៃ ចំពោះប្រជាពលរដ្ឋខ្មែរអោយបានខ្ពស់បំផុត ធ្វើយ៉ាងណាអោយប្រជាពលរដ្ឋខ្មែរ ជឿកជាក់ និងទុកចិត្ត ។ ព្រោះយើងជាក្តីសង្ឃឹម សំរាប់អាយុជីវិត ជាតិ សាសនា និងប្រជាជាតិខ្មែរ ចុងក្រោយហើយ ។

## ៦_គោលដៅវាយលុក (offensive target)

គោលដៅដែលយើងត្រូវវាយលុក គឺយើងត្រូវប្រើគ្រប់មធ្យោបាយ ឃោសនាវាយលុកទៅលើកុម្មុយនិស្តដែលមានយួនកុម្មុយនិស្តកំពុងត្រួតត្រាខ្មែរ តាមរយៈការប្រើជនកុម្មុយនិស្តផ្តាច់ការ **ហ៊ុន សែន** និងមានស្តេច **សីហនុ** ជាខែលរនាំងបិទបាំងប្រជាពលរដ្ឋខ្មែរ ។ ដូច្នេះ យើងត្រូវស្វែងរកចំណុចខ្សោយ ចំណុចមានអទិភាពបំផុតវាយលុកទៅលើគោលដៅទាំងនោះ ។ យើងមិនត្រូវវាយលុកលើអ្នកស្នេហាជាតិ អ្នកប្រជាធិតេយ្យដូចគ្នាទេ ដូចជាគណបក្សសមរង្សី និងគណបក្សសិទ្ធិមនុស្សជាដើម ។ អ្នកទាំងនេះ យើងត្រូវលើកទឹកចិត្តជានិច្ច ។ ប៉ុន្តែ ចំពោះអ្នកស្នេហាជាតិ ដែលមាននិន្នាការនយោបាយខាងរាជានិយម និងអ្នកនៅក្នុងគណបក្សប្រជាជន យើងត្រូវលើកហេតុផលបង្ហាញ ចំពោះគ្រោះថ្នាក់ប្រទេសជាតិ ដើម្បីអោយគេជួយគាំទ្រយើងជាសម្ងាត់ តែយើងមិនត្រូវនិយាយកិច្ចការ ឬផែនការស៊ីជំរៅអោយគេដឹងឡើយ ។ *ត្រូវចាំថា គោលដៅវាយលុកដែលមានប្រសិទ្ធភាពឈ្នះសត្រូវ យើងអាចធ្វើជាចំហរ និងសម្ងាត់ ជាពិសេស គឺពេលដែលយើងអាចការពារខ្លួនពីសត្រូវ មិនអោយវាយលុកមកលើយើងបាន ។ ប៉ុន្តែ យើងអាចឈ្នះសត្រូវបាន គឺអាស្រ័យលើការវាយឆ្មក់ តាមគោលការណ៍សម្ងាត់ ។ ការវាយឆ្មក់មានប្រសិទ្ធិភាព អាស្រ័យលើផែនការសម្ងាត់ និងល្បឿន ដែលមានឱកាស និងពេលវេលាកំណត់ព្រមគ្នា ។*

# ជំពូកទី ២




ជាតិខ្មែរម្នាក់ ត្រូវតែប្តេជ្ញាចិត្ត ថែរក្សាទឹកដីខ្មែរ និងផលប្រយោជន៍ជាតិខ្មែរ

# **ផែនការ** (Planning)

## I.**ការធ្វើគំរោង**

អ្នកធ្វើផែនការឃោសនា មិនត្រឹមតែយល់ដឹងគោលនយោបាយ យុទ្ធសាស្រ្តធំរបស់អង្គដឹកនាំនយោបាយទេ ឃោសនិកត្រូវយល់ដឹងគ្រប់ស្ថានការណ៏នយោបាយក្នុងប្រទេស និងក្រៅប្រទេស។ ឃោសនិកត្រូវចេះប្រើគ្រប់យុទ្ធសាស្រ្ត យុទ្ធវិធី និងកល្បិចឃោសនាផ្សេងៗ ដើម្បីអោយមានប្រសិទ្ធភាពសំរេចតាមផែនការ ដល់គោលដៅរបស់អង្គការនយោបាយយើង។

ផែនការឃោសនានៅទីនេះ យើងអាចបែងចែកជាពីរធំៗ គឺ *យុទ្ធសាស្រ្តការពារ* និង*យុទ្ធសាស្រ្តវាយលុក។ ពេលដែលយើងចាញ់ប្រៀប ឬទន់ខ្សោយជាងសត្រូវ យើងត្រូវប្រើយុទ្ធសាស្រ្តការពារ ហើយត្រូវរកវិធីសាស្រ្ត ឬយុទ្ធវិធីវាយលុកទៅលើសត្រូវវិញដែរ ដោយមិនរង់ចាំតែការពាររហូតឡើយ។ នៅពេលដែលយើងមានប្រៀបលើសត្រូវ យើងត្រូវប្រើយុទ្ធសាស្រ្តវាយលុក មានន័យថា នៅពេលដែលយើងមានប្រៀបខាងកម្លាំងស្មារតី ធនធាន សម្ភារៈ យុទ្ធសាស្រ្ត និងបច្ចេកវិទ្យា។* នៅពេលយើងចាប់ផ្តើមធ្វើការឃោសនាម្តងៗ យើងត្រូវមានផែនការដូចតទៅ :

១-កំណត់បញ្ហា

២-ជ្រើសរើសប្រធានបទឃោសនា (ស្របទៅនិងស្ថានការណ៏នយោបាយបច្ចុប្បន្ន)

៣-ជ្រើសរើសគោលដៅឃោសនា

៤- យុទ្ធសាស្រ្តឃោសនាផ្សេងៗ

៥-កម្មវិធីប្រតិបត្តិការ

៦-វិភាគលើលទ្ធផល ខាត ឬ ចំណេញ (នយោបាយ)

៧-ត្រួតពិនិត្យ

### **១.កំណត់បញ្ហា** (Problem Statement)

យើងត្រូវជ្រើសរើសយកប្រធានបទសំខាន់ៗ អោយចំនិងបញ្ហារបស់ប្រជាពលរដ្ឋកំពុងចង់បាន និងផលប្រយោជន៏ប្រទេសជាតិទាំងមូល។ បញ្ហាដែលយើងកំណត់នោះ ត្រូវចាំបាច់ជាឫសគល់នៃបញ្ហា មិនមែនចុងបញ្ហាឡើយ។ បើយើងក្រឡេកមើលបញ្ហានៅក្នុងប្រទេសខ្មែរ ដែលពួក **ហ៊ុន សែន** បង្កើតបញ្ហាឡើងតាមផែនការយួន ជាបន្តបន្ទាប់ ពួកនេះគ្មានសមត្ថភាពដោះស្រាយឡើយ។ តាមពិតទៅ បញ្ហានៅក្នុងប្រទេសខ្មែរវាមានឫសគល់របស់វា ប្រៀបដូចជាដើមឈើមួយដើម ដែលវាមានឫសបែកមែក ដុះស្លឹកជាបន្តបន្ទាប់យ៉ាងដូច្នេះដែរ។ បើយើងកាត់មែក និងកាប់ស្លឹកនោះមែកថ្មីនិងស្លឹកថ្មីដុះចេញមកជាមិនខាន តែបើយើងកាត់ឫសរបស់វាអស់នោះ មែកឈើស្លឹកឈើនោះមិនអាចដុះបានទៀតឡើយ ។ ចំណែកឯបញ្ហានៅក្នុងប្រទេសខ្មែរក៏ដូចគ្នាដែរ បញ្ហាដែលកើតឡើង ដូចជាបាត់បង់ទឹកដី ខ្មែរស្លាប់រាប់លាននាក់ ខ្មែរអស់ទ្រព្យសម្បត្តិ អស់ព្រៃឈើ អំពើពុករលួយ ក្រីក្រ បាត់បង់ដីធ្លី ទាំងអស់នេះជាចុងបញ្ហាទេ។ ចំណែកដើមបញ្ហានៅត្រង់ថា ខ្មែរស្ថិតនៅ

ក្រោមការត្រួតត្រារបស់កុម្មុយនិស្តយួនបែបថ្មី។ ដូចនេះ ពួកត្រួតត្រាធ្វើការកៀបសង្កត់ ធ្វើទុក្ខបុកម្នេញ កាប់សម្លាប់ជាតិខ្មែរគ្មានត្រាប្រណីឡើយ។ ការកំណត់បញ្ហាត្រូវធ្វើឡើង និងជ្រើសរើសប្រធានបទ ដែលមានអទិភាពបំផុត។ មានន័យថា យើងមេដឹកនាំត្រូវដោះស្រាយឫសគល់នៃបញ្ហាសំរាប់ប្រទេសជាតិ មិនត្រូវដោះស្រាយចុងបញ្ហាឡើយ។ ចំណែកឯឃោសនិកវិញ ត្រូវកំណត់តាមគោលការណ៍រួមរបស់អង្គការនយោបាយយើង គឺលើកយកឫសគល់ បញ្ហាធ្វើជាប្រធានបទ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋខ្មែរអោយដឹង។ បញ្ហាដែលកំពុងកើតឡើងនៅក្នុងប្រទេសខ្មែរបច្ចុប្បន្ន ដូចជាកំណើនជនអន្តោប្រវេសន៍យួន ជម្លោះដីធ្លី ទំនិញឡើងថ្លៃ ប្រាក់ខែទាប អំពើពុករលួយ ។ល។ទាំងអស់នេះជាចុងបញ្ហាទេ។ ឫសគល់នៃបញ្ហាពិតប្រាកដរបស់ប្រទេសខ្មែរ គឺយួនកុម្មុយនិស្តត្រួតត្រា បញ្ហាខ្មែរកុម្មុយនិស្តដែលលង់មនោគមន៍យួន។

## ២.ជ្រើសរើសប្រធានបទឃោសនា (Selected Topic)

ដើម្បីលើកយកប្រធានបទមួយ ឬគោលនយោបាយមួយ មកឃោសនាដល់ប្រជាពលរដ្ឋ មេដឹកនាំ ឬឃោសនិកត្រូវធ្វើតាមគោលការណ៍របស់អង្គការនយោបាយនោះ ដោយចេះបត់បែនតាមទៅតាមកាលៈទេសៈ សំរបទៅតាមស្ថានការណ៍នោះ។ យើងត្រូវសិក្សាពតិមានអោយល្អិតល្អន់ ច្បាស់លាស់ពីផលចំណេញ និងខាតនយោបាយ តើគេប្រឆាំង ឬគាំទ្រ។ តើអ្វីដែលយើងខិតខំធ្វើ វាជាផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ និងជាតិខ្មែរឬទេ?។ ក្រោយពីប្រមូលបានពតិមានយកមកសិក្សាល្អិតល្អន់ហើយ ទើបយើងលើកយកចំណុចដែលមានអទិភាពបំផុតមកឃោសនា។ ចំណុចអទិភាពនេះ គឺ ជាតំរូវការចាំបាច់របស់ប្រជាជាតិខ្មែរ ដែលកំពុងចង់បាន ឬជាចំណុចខ្សោយនៃចំណុចស្លាប់ (weakness of Center Gravity ) រស់របស់គូរប្រកួតប្រជែង (យួន និងគណបក្សប្រជាជន)។

## ៣.ជ្រើសរើសគោលដៅឃោសនា (Select Target For Propaganda)

ការជ្រើសរើសគោលដៅវាយលុក ជាកត្តាសំខាន់បំផុតសំរាប់ធ្វើអោយនយោបាយយើងមានប្រៀបអាចយកជ័យជំនះសត្រូវបាន។ *នៅពេលឃោសនា យើងវាយចំណុចខ្សោយនៃចំណុចស្លាប់រស់របស់គូរប្រកួតប្រជែង ឬវាយប្រហារលើកន្លែងណាដែលសត្រូវមិនអាចការពារខ្លួនបាន។* ពោលគឺឃោសនិកត្រូវតែយល់ច្បាស់ អំពីគោលដៅដែលយើងត្រូវឃោសនា។ យើងអាចបែងចែកការឃោសនា ជាផ្នែកផ្សេងៗគ្នា ដូចជានៅទីកន្លែងសាធារណះ ទីប្រជុំជន សាលារៀន វត្តអារាម ទីផ្សារ ទីកន្លែងកំសាន្ត ពិធីបុណ្យ រោងចក្រ សហគមន៍ ការធ្វើដំណើរ ភោជនីយដ្ឋាន ស្រុក ឃុំ ភូមិ ជាក្រុមតូចៗ ឬ បុគ្គល ឬកន្លែងដែលប្រជាពលរដ្ឋកំពុងតែមានបញ្ហា ដូចជា អ្នកមានអំណាចដណ្តើមដីធ្លី កម្មករធ្វើកូដកម្ម ដោយសារថៅកែមិនបើកប្រាក់បៀវត្ស ទំនិញឡើងថ្លៃជាដើម ។ល។ យើងជាអ្នកស្នេហាជាតិខ្មែរ ត្រូវពុះពារសកម្មបំផុតក្នុងការឃោសនា លើសយួនរាប់សិបដង ដើម្បីការពារផលប្រយោជន៍ ជាតិ សាសនា និងប្រជាជាតិខ្មែរ អោយគង់វង្សសំរាប់កូនចៅខ្មែរជំនាន់ក្រោយទៀត។

### ៤-យុទ្ធសាស្ត្រឃោសនាផ្សេងៗ (Other Propoganda Strategies)

#### ក-បង្ហាញអំពីគោលការណ៍ និងអង្គការនយោបាយ (Show Principles and Political Organization)

ឃោសនិកមុនធ្វើជាអ្នកឃោសនា ដ៏មានប្រសិទ្ធភាពសំរាប់អង្គការនយោបាយ ជាដំបូងយើងត្រូវចូលជាសមាជិកនៃអង្គការនយោបាយនោះសិន ដើម្បីអោយយើងយល់ដឹងអំពីគោលការណ៍ទាំងឡាយរបស់អង្គការនយោបាយនោះ អោយបានច្បាស់លាស់។ បន្ទាប់មក ឃោសនិកចាប់ផ្តើមទំនាក់ទំនង ផ្សព្វផ្សាយ ចេញឃោសនាដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ទំនាក់ទំនងចាប់តាំងពីបុគ្គលម្នាក់ ពីរនាក់ ឬច្រើននាក់ឡើងទៅ។ ដំបូងយើងត្រូវតែស្វែងរកបុគ្គលដែលស្នេហាជាតិពិតប្រាកដ និងអ្នកមានទេពកោសល្យ ដែលមានលក្ខណៈមេដឹកនាំ។ ប្រៀបដូចជា **ឡាវ ពី** និងបងប្អូនពីរនាក់ទៀតនៅក្នុងរឿងភាគចិនមួយដែលមានឈ្មោះថា **សាមកុក** សុខចិត្តស៊ូទ្រាំគ្រប់បែបយ៉ាង ដើម្បីអញ្ជើញ **ខុង ម៉េង** មកជួយរំដោះស្រុកទេសយ៉ាងដូច្នោះដែរ។ ការផ្សព្វផ្សាយនេះដើម្បីពន្យល់បង្ហាញប្រជាពលរដ្ឋខ្មែរ យល់អំពីគោលការណ៍ដឹកនាំរបស់អង្គការនយោបាយខ្លួន និងអោយប្រជាពលរដ្ឋខ្មែរ មើលឃើញអំពីគ្រោះថ្នាក់របស់ប្រទេសជាតិ។ យួនកំពុង*ប្រើយុទ្ធសាស្ត្រ ដង្កូវខ្មួង ដែលកំពុងស៊ីរូងផ្ទៃក្នុងប្រទេសខ្មែរសព្វថ្ងៃនេះ* ទីបំផុតជាតិខ្មែរត្រូវស្លាប់។ យើងជាឃោសនិកធ្វើយ៉ាងណា អោយប្រជា-ពលរដ្ឋខ្មែរគាំទ្រ ឬចូលរួមជាមួយយើង ដោយលះបង់ទាំងពេលវេលា សម្ភារៈ កម្លាំងកាយ ចិត្ត ដើម្បីអោយសំរេចជោគជ័យតាមគោលការណ៍នោះ។ មិនថាសត្រូវនោះ តូច ឬ ធំ ប៉ុណ្ណាឡើយ ក៏យើងជាអ្នកស្នេហាជាតិខ្មែរអាចយកឈ្នះសត្រូវបានជានិច្ច *អោយតែយើងមានផែនការល្អបំផុត* (The Best Plan)។ *យើងប្រៀបដូចជាម្ជុលតូចមួយដែលតូច ហើយអាចចាក់ចំបេះដូងមនុស្ស ធ្វើអោយមនុស្សស្លាប់បានយ៉ាងដូច្នេះដែរ*។ ឃោសនិកត្រូវបង្ហាញបកស្រាយ អំពីគោលការណ៍ និងឈ្មោះរបស់អង្គការដឹកនាំ ធ្វើមនោគមន៍នយោបាយ សង្គ្រាមនយោបាយ ចិត្តសាស្ត្រ តាមសកម្មភាពផ្សេងៗ ដែលខ្លួនមានសមត្ថភាពអាចរៀបចំបាន។

ឧទាហរណ៍ ដើម្បីអោយខ្មែរ និង ឡាវ ចូលរួមជាមួយបក្សកុម្មុយនិស្តឥណ្ឌូចិន យួនបានបង្ហាញ អំពីគោលការណ៍កុម្មុយនិស្តមួយចំនួន តាមម៉ាកឡេនីន ហើយបញ្ចុះបញ្ចូលអោយខ្មែរ និងឡាវ ជួយប្រឆាំងនឹងអាណានិគមនីបារាំង និងអាមេរិក ដែលមកត្រួតត្រាឥណ្ឌូចិន។ តែតាមការពិត យួនធ្វើបែបនេះ ដើម្បីទុកឱកាសអោយយួន តែម្នាក់ឯងត្រួតត្រាឥណ្ឌូចិន ដណ្តើមផលប្រយោជន៍ខ្មែរទៅវិញ។ ចំពោះគណបក្សប្រជាជនវិញ តែងតែលើកយកថ្ងៃ ៧ មករា ជាគោលការណ៍នយោបាយបោកប្រាស់ប្រជាពលរដ្ឋខ្មែរ ថាខ្លួនបានរំដោះប្រជាពលរដ្ឋខ្មែរចេញពីរបបប្រល័យពូជសាសន៍។ តែផ្ទុយទៅវិញ គណបក្សប្រឆាំងនានា តែងតែលើកឡើងថា ៧ មករា ជាថ្ងៃដែលយួនឈ្លានពាន ប្លន់ទ្រព្យសម្បត្តិខ្មែរ និងលេបយកទឹកដីខ្មែរ។ ចំណែកយើងជាជាតិខ្មែរ ត្រូវយល់ថាមានតែខ្មែរទេជាអ្នកស្រឡាញ់ខ្មែរ មិនមែនបរទេសទេ។ ប៉ុន្តែយើងទាំងអស់គ្នា ឈប់ជឿពួកមេដឹកនាំខ្មែរមួយចំនួន ដែលលង់ក្នុងការបំពាក់បំប៉នមនោគមន៍កុម្មុយនិស្តពីយួនទៀតហើយ ពីព្រោះយើងបានសិក្សាអំពីយុទ្ធសាស្ត្រយួនច្បាស់លាស់ណាស់ ហើយមើលឃើញថា ចាប់ពី ១៧ មេសា ១៩៧៥ មក គឺជាថ្ងៃជ័យជំនះរបស់ពួកកុម្មុយនិស្ត រហូតដល់ ៧ មករា ១៩៧៩ គឺនៅតែពួកកុម្មុនិស្តដដែល គេគ្រាន់តែដូរមនុស្ស និង

ឈ្មោះតែប៉ុណ្ណោះ ដើម្បីបំភ័ន្តខ្មែរ ងាយស្រួលកុម្មុយនិស្តយួនត្រួតត្រាបន្ត ដណ្តើមផលប្រយោជន៍ខ្មែរ។ យើងអាចមើល **ដង្កូវខ្ចង** ពេលវាស៊ីអស់រូងបណ្តូលក្នុងដើមឈើអស់ហើយ ទីបំផុតដើមឈើនោះអាចងាប់ ឬយើងប្រៀបទៅដើមជ្រៃដែលរុំព័ទ្ធដើមត្នោតរហូតដល់ស្លាប់។

ឃោសនិកត្រូវលើកយកគោលការណ៍របស់អង្គការនយោបាយ មកបកស្រាយ និងបង្ហាញដល់សាធារណៈជន ដើម្បីអោយគេដឹង ទទួលដំណឹងយកទៅផ្សព្វផ្សាយបន្ត ជាពិសេស ឃោសនិកត្រូវលើកតំកើង និងសសើរអំពីគោលការណ៍របស់អង្គការនយោបាយខ្លួន។ ពីព្រោះមានតែអង្គការនយោបាយនេះហើយ ដែលជាអ្នកស្នេហាជាតិ និងគិតគូររឿងអាយុជីវិតប្រទេសជាតិពិតប្រាកដ។ ឃោសនិកត្រូវផ្សព្វផ្សាយលើកតំកើងគោលការណ៍យើង ដោយធានាចំពោះប្រជាពលរដ្ឋថា ពិតជាអាចដឹកនាំប្រទេសជាតិអោយមានការរីកចំរើនដូចគោលការណ៍តាមអ្វីដែលប្រជាពលរដ្ឋចង់បាន។ ចំណុចសំខាន់នៃការឃោសនានេះ អ្នកឃោសនាត្រូវរើសចំណុចដែលខុសគ្នាពីសត្រូវនិងមានប្រៀបលើអង្គការនយោបាយដ៏ទៃ ដូចជា មេដឹកនាំ យុទ្ធសាស្ត្រ គោលការណ៍អង្គការនយោបាយ ការរៀបចំប្រទេស និងចំណុចដែលនាំទៅយើងទទួលបានជោគជ័យជាដើម។ យើងត្រូវធ្វើការប្រៀបធៀប រវាងគោលការណ៍របស់អង្គការនយោបាយខ្លួន និងអង្គការនយោបាយរបស់អ្នកដ៏ទៃ ដែលជាគោលដៅក្នុងការប្រកួតប្រជែង។ ឃោសនិកត្រូវបកស្រាយអំពី អ្វីដែលអង្គការនយោបាយនោះមាន ដូចជា ឡូកូ ឈ្មោះ ពាក្យពេចន៍ អត្ថន័យ ខ្លឹមសារ និងសកម្មភាពរបស់មេដឹកនាំផ្សេងៗ។ល។

### ខ-ទីកន្លែងឃោសនា និងឱកាស (Place and Time)

ចំពោះការឃោសនាជាចំហរ ឃោសនិកត្រូវជ្រើសរើសកន្លែងសាធារណៈដែលមានលក្ខណៈសមរម្យដើម្បីអោយប្រជាពលរដ្ឋអាចទទួលដឹងអំពីគោលនយោបាយ និងគោលការណ៍ផ្សេងៗរបស់យើង។ ដូចជាការរៀបចំកម្មវិធីសិក្ខាសាលា ប្រជុំ ពិធីបុណ្យ ចែកអំណោយ បើកសម្ពោធ បង្រៀន ឬផ្សព្វផ្សាយតាម សារពត៌មានផ្សេងៗ។ *ទីកន្លែងនិងពេលវេលានេះ ជាកត្តាមួយដែលយើងអាចយកឈ្នះលើសត្រូវបាន ទោះជាសត្រូវមានគ្នាច្រើន និងខ្លាំងប៉ុណ្ណាក៏ដោយ ក៏យើងអាចយកឈ្នះបានដែរ។ គ្មាននរណាមួយ ដែលអាចនឹកស្មានដល់ថាខ្សែទ្រមានតែពីរសោះ តែគេអាចលេងបានបទភ្លេងរាប់មិនអស់នោះដែរ ហើយក៏គ្មាននរណានឹកស្មានដល់រស់ជាតិមានតែប្រាំ តែគេអាចបញ្ចូលគ្នា បានរស់ជាតិសំរាប់ម្ហូបរាប់រយមុខនោះដែរ។ ដូចនេះ យើងមិនត្រូវយកយុទ្ធសាស្ត្រដដែលៗ មកធ្វើការឃោសនា ឬវាយលុកលើសត្រូវទេ ពោលគឺយើងត្រូវចេះលេងផ្លាស់ចុះឡើងប្រៀបដូចជា ព្រះអាទិត្យ និងព្រះច័ន្ទ ឬរដូវកាលទាំងបួន ដែលវាវិលវល់ចុះឡើងមិនចេះចប់។*

### គ-ប្រជាពលរដ្ឋ (Citizions)

ដើម្បីអោយជ្រួតជ្រាបដល់ប្រជាពលរដ្ឋខ្មែរ គ្រប់ស្រទាប់ក្នុងសង្គម ឃោសនិកត្រូវផ្សាយពត៌មានដែលខ្លួនមានអោយបានឮដល់ប្រជាពលរដ្ឋ ឬអោយបានដល់ក្រុមគោលដៅដែលយើងចង់ឃោសនា។ យើងអាចធ្វើ តាមរយៈខិតប័ណ្ណ ការសែត វិទ្យុ ទូរទស្សន៍ វែបសាយ ឬបណ្តាញសារពត៌មានផ្សេងៗ ដែលអ្នកស្តាប់អាចទទួលបាន និងចូលចិត្តស្តាប់ភាគច្រើន ។

ត្រង់ចំណុចនេះ ឃោសនិកត្រូវស្គាល់អំពីចិត្តសាស្ត្ររបស់ប្រជាពលរដ្ឋខ្មែរអោយច្បាស់ តើប្រជាពលរដ្ឋខ្មែរត្រូវការអ្វីជាចាំបាច់ មានបញ្ហាអ្វី ទំនៀមទំលាប់ វប្បធម៌ ប្រពៃណី យ៉ាងណា? និងទំនោរយ៉ាងដូចម្តេច? យើងជាឃោសនិកត្រូវចុះផ្ទាល់ដល់ប្រជាពលរដ្ឋតែម្តង ដើម្បីនិយាយ និងពន្យល់អំពីបញ្ហាផ្សេងៗដែលគាត់ចង់ស្តាប់ ដោយយើងចុះផ្ទាល់ទៅដល់គោលដៅ គឺយើងត្រូវធ្វើនយោបាយចិត្តសាស្ត្រជាមុន ធ្វើយ៉ាងណាអោយប្រជាពលរដ្ឋស្រឡាញ់ និងគោរព ការពារយើង ។

ការដែលចុះជួបផ្ទាល់ជាមួយប្រជាពលរដ្ឋ នេះជាកត្តាមួយដែលមានឥទ្ធិពលខ្លាំងបំផុត សំរាប់ឃោសនិកលើប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋអាចវិនិច្ឆ័យ និងសំរេចចិត្តផ្សេងៗ លើអ្នកដែលយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់គាត់ និងការពារផលប្រយោជន៍របស់គាត់ ។ *ហេតុដូចនេះ កត្តាសំខាន់សំរាប់ការជោគជ័យរបស់អង្គការនយោបាយ គឺយើងត្រូវតែលះបង់គ្រប់បែបយ៉ាង ក្នុងការហ្វឹកហ្វឺនអ្នកស្នេហាជាតិខ្មែរ សមាជិក អោយបានល្អ ដើម្បីជួយក្នុងកិច្ចការ បេសកកម្ម និងបំរើប្រជាពលរដ្ឋ ជាពិសេស យើងត្រូវប្រយ័ត្នប្រយែងចំពោះការជ្រើសរើស និងលើកទឹកចិត្តបុគ្គលិក។*

### ឃ-ឃោសនិក (Propagandists)

ឃោសនិក គឺជាបុគ្គលដែលមានសមត្ថភាពក្នុងការឃោសនា មានគុណភាពក្នុងការដឹកនាំ មានចំណេះដឹងខាងនយោបាយ និងចំណេះឯកទេសផ្សេងៗដែលមានឥទ្ធិពលដល់ប្រជាពលរដ្ឋ និងអាចអោយគេជឿជាក់បាន ។ ការរៀបចំបណ្តុំឃោសនិក ជាកត្តាសំខាន់មួយសំរាប់ការឃោសនា ។ ឃោសនិកត្រូវរៀបចំខ្លួនអោយមានល្អដូចមេដឹកនាំដែរ ។ អ្នកស្នេហាជាតិខ្មែរគ្រប់ស្រទាប់ទាំងអស់ ត្រូវធ្វើជាគំរូល្អ ដើម្បីអោយប្រជាពលរដ្ឋមានភាពជឿជាក់លើខ្លួន និងមានការគាំទ្រ ។ ក្រោយពីរៀបចំបណ្តុំ ទៅតាមគោលការណ៍នៃការជ្រើសរើសសមាជិករបស់អង្គការនយោបាយរួចហើយ យើងត្រូវធ្វើការហ្វឹកហាត់សមាជិកទាំងនោះ អោយយល់ដឹងអំពីរបៀបឃោសនា និងលក្ខណៈផ្សេងៗ របស់ការដឹកនាំនៃអង្គការដឹកនាំនយោបាយ ។ *កត្តាជោគជ័យមិនមែនកើតឡើងដោយចៃដន្យទេ តែកើតឡើងដោយសារយើងមានការត្រៀមទុកជានិច្ច និងការហ្វឹកហ្វឺនបណ្តុះបណ្តាល គ្រប់សមាជិកទាំងអស់អោយបានល្អជាទីបំផុត ។* ក្រោយពីការហ្វឹកហាត់រួច ដោយធានាថាឃោសនិកទាំង នោះយល់ដឹង អំពីកិច្ចការផ្សេងៗទាក់ទង និងវិធីឃោសនា ទើបយើងចាត់ចែងអោយឃោនិកនោះចាប់ផ្តើម ធ្វើការតាមផែនការជាយុទ្ធសាស្ត្រ ។ ឃោសនិកត្រូវមានលក្ខណៈសម្បត្តិដូចតទៅ :

១-សមាជិក

២-បណ្តុះបណ្តាល អំពី នយោបាយ ការដឹកនាំ ឃោសនា ចិត្តសាស្ត្រ យុទ្ធសាស្ត្រផ្សេងៗ

៣-អនុវត្តការងារយ៉ាងសកម្ម

ឃោសនិកត្រូវនឹកឃើញដល់ឫសគល់នៃយុទ្ធសាស្ត្រ ក្នុងការឃោសនា *គោលដៅវាយលុក កំលាំង ធនធាន បង្ហាញផ្លូវ ធ្វើកិច្ចការត្រឹមត្រូវ ស្គាល់ហេតុការណ៍ គិតត្រៀមចាញ់ ឆក់ឱកាស ដុតឆន្ទះ ធ្វើអោយប្រសើរឡើង ចេះប្រើបញ្ចូលគ្នា (អង្គការដឹកនាំ ហ្វឹកហាត់ និងការទំនាក់ទំនង)* ។ អ្នកឃោសនា

ធ្វើយ៉ាងណាអោយមានលក្ខណៈសកម្ម ហើយងាយស្រួលយល់ មានលក្ខណៈសាមញ្ញ ស្របទៅនិងចំណេះរបស់ប្រជាពលរដ្ឋ។ អ្នកឃោសនាត្រូវចេះលើកយកហេតុផល អោយមានលក្ខណៈតក្កវិជ្ជា ធ្វើយ៉ាងណាអោយអ្នកស្តាប់ជឿជាក់ និងទទួលយកបាន។ យើងត្រូវមានភាពច្នៃប្រឌិតខ្ពស់ ឈ្លៀសវៃ រើសយកប្រធានបទណាដែលទាក់ទង ជាមួយអ្នកស្តាប់ និងស្ថានការណ៍កំពុងកើតមាននៅទីនោះ។ ការឃោសនា ត្រូវធ្វើឡើងម្តងហើយម្តងទៀតដែលមានលក្ខណៈចំពោះ មិនចំពោះ និងប្រឆាំង ។ល។

ឧទាហរណ៍ យើងលើកអំពីមូលហេតុដែលនាំអោយប្រជាពលរដ្ឋក្រីក្រ គឺបណ្តាលមក ពីទំនិញឡើងថ្លៃហើយប្រជាពលរដ្ឋគ្មានការងារ ប្រាក់ខែតិច និងប្រាក់ចំណូលតិចជាដើម។ នេះគឺជាយុទ្ធសាស្ត្រយួន ធ្វើអោយយើងនៅតែខ្សោយ ខ្សោយទាំងកម្លាំងកាយ ស្មារតី និងបញ្ញា ដើម្បីងាយស្រួល ពួកវាត្រួតត្រាខ្មែរ គេងចំណេញយកផលប្រយោជន៍ខ្មែរ ទ្រព្យសម្បត្តិខ្មែរ និងទឹកដីខ្មែរទាំងមូល ជាក់ស្តែង ប្រទេសចម្ប៉ា និងខ្មែរក្រោមជាឧទាហរណ៍ នេះហើយជាយុទ្ធសាស្ត្រ នយោបាយសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិន។

**ង-រូបភាពខាងក្រៅ** (Physics)

លក្ខណៈសម្បត្តិខាងក្រៅរបស់អង្គការដឹកនាំ គោលនយោបាយ រចនាសម្ព័ន្ធ បុគ្គលិក សម្ភារៈ និងកត្តាផ្សេងៗទៀត ដែលប្រជាពលរដ្ឋអាចមើលឃើញសកម្មភាពប្រចាំថ្ងៃ ពាក្យសម្តី និង ឥរិយាបថជាដើម។ ដូចនេះ យើងជាអ្នកស្នេហាជាតិខ្មែរទាំងអស់ ត្រូវប្រុងប្រយ័ត្នគ្រប់វិនាទី ដើម្បីកុំអោយការងារបរាជ័យ។ យើងជាឃោសនិក ត្រូវប្រកាន់ឥរិយាបថថ្លៃថ្នូរ ជាទីទុកចិត្ត និងជឿជាក់ពីប្រជាពលរដ្ឋ មិនត្រូវលុះក្នុងឧបាយមុខ ដូចជា ល្បែង ស្រី ស្រាឡើយ។ *ចូរយើងកុំមើលរំលងសត្រូវ គិតថាសត្រូវមិនវាយលុកយើង តែយើងត្រូវតែត្រៀមចាំជានិច្ច ដោយគិតថា សត្រូវនិងវាយលុកយើងថ្ងៃណាមួយ។ ការពារជាមុនប្រសើរជាងមានជម្ងឺហើយទើបព្យាបាល។*

**ច-តំលៃអង្គការនយោបាយ** (Value of Political Organization)

យើងត្រូវបង្ហាញអំពីការគាំទ្រ ចំពោះអង្គការនយោបាយយើង ដោយប្រាប់តំលៃពិសេសនៃអង្គការដឹកនាំនេះ ត្រង់ថាចេញពីអ្នកស្នេហាជាតិពិតប្រាកដ ជាអ្នកដែលគិតគូរពីវាសនាប្រទេសជាតិ ផលប្រយោជន៍ប្រទេសជាតិ ក៏ដូចជា សុខទុក្ខរបស់ប្រជាពលរដ្ឋ ទឹកដី សំរាប់ជាតិខ្មែរទាំងមូល មិនមែនជាអ្នកអាត្មានិយម គិតប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួកមួយក្រុមតូចនោះឡើយ។ អង្គការនយោបាយនេះ និងនាំយកលទ្ធិប្រជាធិបតេយ្យពិតប្រាកដមកជូនប្រជាពលរដ្ឋខ្មែរ អោយមានសិទ្ធិសេរីភាពពេលលេញ ឯករាជ្យ ចេញពីការជិះជាន់អំណាចផ្តាច់ការ **ហ៊ុន សែន** ក្រោមការត្រួតត្រារបស់យួនកុម្មុយនិស្ត និងបំពេញនូវសេចក្តីត្រូវការជូនប្រជាពលរដ្ឋតាមការចង់បាន ពេលដែលអង្គការនយោបាយនេះ ដឹកនាំជាតិខ្មែរក្នុងអនាគតដ៏ខ្លីខាងមុខ។

### ឆ-សកម្មភាព ពាក្យពេចន៍ និងអត្ថន័យឃោសនា (Action, Words and Meaning)

ដើម្បីអោយមានប្រសិទ្ធភាពក្នុងការឃោសនា ឃោសនិកត្រូវរៀបចំខ្លួនអោយមានសេចក្តីថ្លៃថ្នូរ ចាប់តាំងពីពាក្យសម្តី សកម្មភាព ឥរិយាបថ គំរូល្អ នាំមុខគ្រប់យ៉ាង គួរអោយជឿជាក់និងទុកចិត្តពីប្រជាពលរដ្ឋ។ ឃោសនិកត្រូវស្វែងរកផលប្រយោជន៏ជូនប្រជាពលរដ្ឋ ឬការពារផលប្រយោជន៏របស់ប្រជាពលរដ្ឋ ជាពិសេសការពារផលប្រយោជន៏ប្រទេសជាតិទាំងមូល។ យើងត្រូវរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋ ស្មោះត្រង់ចំពោះជាតិខ្មែរ និងជួយដោះស្រាយបញ្ហារាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋខ្មែរ។ ឃោសនិកត្រូវតែឆ្លងកាត់ការបណ្តុះបណ្តាល ប្រវត្តិសាស្ត្រ ទស្សនវិជ្ជានយោបាយ ប្រវត្តិនយោបាយ ចិត្តសាស្ត្រនយោបាយ សង្គ្រាមនយោបាយ មនោគមនវិជ្ជានយោបាយ គោលការណ៏របស់អង្គការនយោបាយ ភាពជាអ្នកដឹកនាំ និងចំណេះវិជ្ជាឯកទេសមួយរបស់ខ្លួន។ ពេលឃោសនា ឃោសនិកត្រូវតែយកយុទ្ធសាស្ត្រគោលមកប្រើ ធ្វើយ៉ាងណាវាយលុកទៅលើចំណុចខ្សោយនៃចំណុចស្លាប់របស់សត្រូវ។ យើងត្រូវមានភស្តុតាងជាក់ស្តែង ព្រឹត្តិការណ៏ជាក់ស្តែង បកស្រាយជូនប្រជាពលរដ្ឋខ្មែរអោយដឹង។ យើងត្រូវសន្សំសំចៃ ទាំងពេលវេលា ធនធានផ្សេងៗ ដើម្បីអោយមានផលចំណេញផ្នែកនយោបាយ គឺ *ចំណាយតិច តែចំណេញជាអតិបរមា*ដល់ប្រទេសជាតិ។ ត្រូវមានគោលបំណង និងគោលដៅច្បាស់លាស់ក្នុងការវាយលុក។ ឃោសនិកមិនត្រូវធ្វើអោយប៉ះពាល់ផលប្រយោជន៏ជាតិ ប្រជាពលរដ្ឋ ចាប់តាំងពីអារម្មណ៏ ទ្រព្យសម្បត្តិ សម្ភារៈ វប្បធមិ ទំនៀមទំលាប់ប្រពៃណី ផលប្រយោជន៏រួមរបស់ប្រជាពលរដ្ឋឡើយ។*ការឃោសនាដោយសកម្មភាព ឮខ្លាំងជាងការឃោសនាដែលគ្រាន់តែនិយាយ តែមិនធ្វើ។*

### ជ-សកម្មភាពជួយរាល់ទុក្ខលំបាកប្រជាពលរដ្ឋ

ឃោសនិកទាំងអស់ត្រូវយកចិត្តទុកដាក់ជួយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត សម្ភារៈ និងពេលវេលា តាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។ ពេលដែលប្រជាពលរដ្ឋមានបញ្ហាអ្វីមួយដែលពួកគាត់មិនអាចដោះស្រាយបាន ឃោសនិកមានតួនាទីសំខាន់យកចិត្តទុកដាក់ដោះស្រាយបញ្ហាអោយពួកគាត់បានជោគជ័យ។ ឃោសនិកត្រូវចាំថា ខ្លួនយើងជាអ្នកជួយប្រជាពលរដ្ឋ បំរើជាតិខ្មែរ ដូច្នេះ ឃោសនិកត្រូវស្វែងរកផលប្រយោជន៏ជូនប្រជាពលរដ្ឋ ទោះតាមវិធីណាក៏ដោយ ដោយមិនអោយប៉ះពាល់ដល់ផល-ប្រយោជន៏ជាតិ ឬប៉ះពាល់ផលប្រយោជន៏បុគ្គលណាមួយឡើយ។

ដូចកាលដែលកុម្មុយនិស្តយួន (យៀកកុង) យកលទ្ធិកុម្មុយនិស្តមកបំពុលខ្មែរ អោយកាប់សម្លាប់គ្នានោះ ឃោសនិករបស់វាមិនដែលប្រកាន់ខ្លួនឡើយ។ ពេលដែលយួនចូលមកតំបន់ខ្មែរកន្លែងណា យួនតែងតែជួយខ្មែរដូចជារ៉ែកទឹក ពុះអុស ច្រូតស្រូវ លើកអាចម៏គោ ក្របី បោសផ្ទះ អោយប្រជាពលរដ្ឋខ្មែរជាដើម។ *មុននិងយកឈ្នះសត្រូវ ត្រូវយកឈ្នះចិត្តប្រជាពលរដ្ឋសិន*។ ការជួយដោយសប្បុរស អាចធ្វើអោយប្រជាពលរដ្ឋខ្មែរគាំទ្រសុខចិត្តលះបង់គ្រប់យ៉ាង ដើម្បីជួយយើងសំរេចដល់គោលដៅ។ ប្រជាពលរដ្ឋខ្មែរមួយចំនួនបានជួយយួនយៀកកុងជួយលាក់បាំងយួនពីកងទ័ពសាធារណរដ្ឋខ្មែរ កាលពីទសវត្ស ឆ្នាំ ១៩៧០ (សង្គ្រាមឥណ្ឌូចិនលើកទី ២)ក៏ព្រោះតែយួនវាចេះប្រើវិធីចិត្តសាស្ត្រនេះ បន្ទាប់ពីពួកវាបានហ្វឹកហ្វឺនចប់។



ឧត្តមសេនីយ៍ **លន់ នល់** (សម័យសាធារណរដ្ឋខ្មែរ)

FEVRIER 1973

A LA VEILLE DU GRAND DEPART DU NORD VIETNAM AU KAMPUCHEA PAR LA PISTE HO CHI MINH,

LE GENERAL VO NGUYEN GIAP ET SON EPOUSE RENDENT VISITE A NORODOM SIHANOUK ET LA PRINCESSE MONIQUE, EN LEUR RESIDENCE DANS UN ENDROIT "DISCRET" PRES DE HANOI.





( **សី ហនុ ម៉ូនិច** និង គ្រួយួន **យ៉ ង្វៀង យ៉ាប់**)

## ឈ-ទិន្នផលការងារ និងស្នាដៃមេដឹកនាំ

យើងត្រូវបង្ហាញពីស្នាដៃកន្លងមក ដែលអង្គការដឹកនាំនយោបាយយើងបានធ្វើ ឬស្នាដៃរបស់មេដឹកនាំ ដើម្បីអោយប្រជាពលរដ្ឋបានដឹងថា តើយើងអ្វីខ្លះដើម្បីជួយជាតិខ្មែរ? និង តើសមត្ថភាពមេដឹកនាំក៏រិតណាអាច អភិវឌ្ឍន៍ជាតិអោយមានការរីកចំរើនរុងរឿង? ។ សមត្ថផលស្នាដៃផ្សេងៗ សកម្មភាពរបស់មេដឹកនាំ ជាកត្តាមួយ អាចលើកទឹកចិត្ត ជួយជំរុញទឹកចិត្តសមាជិក និងប្រជាពលរដ្ឋផងដែរ ។

## ញ-ចំបញ្ហាប្រជាពលរដ្ឋ

ត្រូវចាំថា ប្រជាពលរដ្ឋមិនចង់ស្តាប់រឿងផ្ទាល់ខ្លួនរបស់យើងឡើយ ប៉ុន្តែ គាត់ចង់ស្តាប់នរណាដែលអាច ការពារផលប្រយោជន៍អោយពួកគាត់ ឬអ្នកដែលជួយដោះស្រាយបញ្ហា អ្នកយកផលប្រយោជន៍មកជូន អោយគាត់ ជាពិសេស គាត់ចង់ស្តាប់រឿងដែលទាក់ទងនឹងរឿងរបស់គាត់ ។ ដូចនេះ យើងជាអ្នកឃោសនា

ត្រូវលើកយកបញ្ហារបស់អ្នកស្តាប់ យកមកនិយាយ និងធ្វើការដោះស្រាយជូនគាត់ ។ ប៉ុន្តែ យើងមិនអាចសន្យា អ្វីដែលយើងមិនអាចធ្វើបាននោះទេ។

### ជ -ប្រតិកម្មភ្លាមៗ

នៅពេលដែលមានការវាយប្រហារ រិះគន់ពីខាងសត្រូវ យើងត្រូវតែធ្វើការការពារខ្លួន បន្ទាប់មកវាយបក ប្រតិកម្មទៅសត្រូវវិញភ្លាម។ យើងធ្វើយ៉ាងណាអោយមានលក្ខណៈប្រៀបលើសត្រូវ ឬអាចវាយសន្ទាប់លើស ត្រូវដោយមិនអោយសត្រូវតដៃបានឡើយ។ ការដែលយើងវាយបកលើសត្រូវ ត្រូវតែធ្វើតាមក្បួនខ្នាត គោល ការណ៍ និងយុទ្ធសាស្ត្រអោយបានត្រឹមត្រូវ។ យើងមិនត្រូវធ្វើតាមកំហឹង ឬធ្វើតាមអារម្មណ៏នោះឡើយ។ យើងត្រូវធ្វើតាមផែនការយ៉ាងត្រឹមត្រូវ ដោយយើងដឹងឱកាស ពេលវេលា ទីកន្លែង ឬយើងអាចដឹង សមត្ថភាពខ្លួនយើង និង សមត្ថភាពសត្រូវច្បាស់លាស់។ បើយើងឈ្នះ យើងត្រូវតែវាយបកភ្លាម តែបើយើងចាញ់ យើងត្រូវការពារខ្លួនអោយមានសុវត្ថិភាព ចាំរកឱកាសវាយបកជាក្រោយ។

## ៥-កម្មវិធីប្រតិបត្តិការ

កម្មវិធីប្រតិបត្តិការនេះ យើងត្រូវរៀបចំអោយបានច្បាស់លាស់ ដោយយើងត្រូវគិតថា យើងចាប់ផ្តើម នៅពេលណា ហើយបញ្ចប់នៅពេលណា? នរណាជាអ្នកទទួលខុសត្រូវក្នុងការងារនោះ? តើវានិងប្រព្រឹត្តទៅ នៅកន្លែងណា? តើមានមនុស្សប៉ុន្មាននាក់និងចូលរួម? តើយើងធ្វើអ្វីខ្លះនៅក្នុងកម្មវិធីនោះ? តើមានរយៈពេល ប៉ុន្មាន? ម៉ោងណាខ្លះ? យើងត្រូវបែងចែកមុខងារអោយច្បាស់លាស់នៅក្នុងកម្មវិធី។

## ៦-វិភាគលើលទ្ធផលខាត ឬចំណេញ (ប្រឆាំង ឬគាំទ្រ)

មុនពេលដែលយើងឃោសនានូវប្រធានបទ ឬ កម្មវិធីអ្វីមួយជាសាធារណៈ ដល់ប្រជាពលរដ្ឋ។ យើងត្រូវ វិភាគអោយបានល្អិតល្អន់ អំពីផលប៉ះពាល់ផ្នែកចិត្តសាស្ត្រដល់ប្រជាពលរដ្ឋ ឬអ្នកនៅតំបន់នោះ។ ត្រូវចាំថា យើងមិនត្រូវធ្វើអោយប៉ះពាល់ផលប្រយោជន៏ សេចក្តីសុខរបស់ប្រជាពលរដ្ឋឡើយ។ យើងត្រូវវិភាគទៅលើ នយោបាយក្នុងស្រុក នយោបាយតំបន់ នយោបាយអន្តរជាតិ សេដ្ឋកិច្ច គូរប្រកួតប្រជែង អ្នកគាំទ្រ ច្បាប់ បរិដ្ឋាន បច្ចេកវិទ្យា វិធីសាស្ត្រ សង្គម ។ល។ តើវាមានផលប៉ះពាល់អ្វីខ្លះ ទទួលបានការគាំទ្រពីសារធាណៈជន ឬត្រូវថ្កោលទោសពីសារធារណៈជន។

ឧទាហរណ៏ថា សាំងឡើងថ្លៃ យើងនាំគ្នាធ្វើបាតុកម្ម។ ពេលនោះ ប្រជាពលរដ្ឋពិតជាគាំទ្រអោយយើង ពីព្រោះវាជាផលប្រយោជន៏យើងទាំងអស់គ្នា។ ប៉ុន្តែ បើយើងធ្វើហើយ តែមិនបានសំរេច វាអាចជះឥទ្ធិពល អាក្រក់មកវិញ ដោយការទាមទាររបស់យើងមិនបានជោគជ័យ។ ម្យ៉ាងទៀត ការប៉ះទង្គិចរវាងពួកអាជ្ញាធរ **ហ៊ុន សែន** និងបាតុករអាចអោយគេមើលឃើញថា ប្រទេសខ្មែរមិនគោរពសិទ្ធិមនុស្ស មិនគោរពច្បាប់ មិនគោរព រដ្ឋធម្មនុញ្ញ ធ្វើអោយអន្តរជាតិថ្កោលទោស ពិសេសលោកខាងលិច ជាប្រទេសសេរី។ វាអាចបង្ហាញប្រជាពលរដ្ឋ អោយឃើញផងដែរ អំពីអសមត្ថភាពរបស់រដ្ឋាភិបាល បំផ្លាញកេរ្តិ៍ឈ្មោះ។

### ៧. ត្រួតពិនិត្យ

យើងត្រូវត្រួតពិនិត្យអោយដឹងថា តើការឃោសនារបស់យើងមានប្រសិទ្ធភាពឬអត់ ក្រោយពីយើងធ្វើការឃោសនាចប់? យើងត្រូវដឹងថា នរណាជាដៃគូរប្រកួតប្រជែងរបស់យើង? តើមានប្រជាពលរដ្ឋចំនួនប៉ុន្មាននាក់គាំទ្រ? ប្រជាពលរដ្ឋចំនួនប៉ុន្មានប្រឆាំង? នរណាជាអ្នកគាំទ្រ ហើយមូលហេតុអ្វីបានជាគេគាំទ្រ? យើងមានយុទ្ធសាស្ត្រអ្វីពិសេស សំរាប់ទាក់ទាញអោយគេគាំទ្រ ឬមានប្រៀបឈ្នះលើគូរប្រកួតប្រជែងយើង? តើនៅកន្លែងណាខ្លះ ដែលប្រជាពលរដ្ឋគាំទ្រយើង កន្លែងណាខ្លះដែលមិនគាំទ្រ? តើចំណុចស្លាប់រស់របស់គូរប្រកួតប្រជែង យើងមានអ្វីខ្លះ ត្រង់ចំណុចណាខ្លះ? ហេតុអ្វីបានប្រជាពលរដ្ឋគាំទ្រគណបក្សប្រជាជន? តើនៅពេលដែលគណបក្សប្រជាជន ធ្វើការវាយលុកខាងឃោសនា ឬសកម្មភាពអ្វីមួយ តើយើងត្រូវប្រតិកម្មភ្លាមៗទៅវិញយ៉ាងដូចម្តេច?

## II. គូរប្លង់យុទ្ធសាស្ត្រឃោសនា (Design Strategy of Propaganda)

ការរៀបចំយុទ្ធសាស្ត្រឃោសនានេះ ឃោសនិកត្រូវគិតរកវិធីដែលប្លែកដាច់ពីគូរប្រកួតប្រជែងរបស់ខ្លួន ដោយជៀសវាងធ្វើតាមវិធីដដែល។ សកម្មភាព លទ្ធផលការងារ និងស្នាដៃ អាចមានប្រសិទ្ធិភាពជាងការនិយាយតែមាត់ទៅទៀត។ ចំណុចសំខាន់គឺយើងអ្នករៀបចំយុទ្ធសាស្ត្រឃោសនា មិនត្រូវមើលតែគោលដៅតំរូវការ និងបញ្ហារបស់ប្រជាពលរដ្ឋដែលត្រូវការនោះទេ គឺយើងត្រូវស្គាល់អំពីគោលដៅវាយលុករបស់គូរប្រកួតប្រជែង។ យើងត្រូវ *ឃោសនាត្រង់ចំណុចខ្សោយ របស់សត្រូវដែលមិនអាចការពារបាន*។

ឧទាហរណ៍ថា ដូចនៅកម្ពុជាក្រោម និងភូមា មានតែព្រះសង្ឃមួយទេ ដែលអាចងើបឡើងតវ៉ា ចំពោះរដ្ឋាភិបាលកុម្មុយនិស្ត។ ព្រោះបើសិនជា រដ្ឋាភិបាលកុម្មុយនិស្តធ្វើទុក្ខបុកម្និញនោះ អន្តរជាតិនឹងថ្កោលទោស ព្រោះនេះជាសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ឬគេថ្កោលទោសអំពីការរំលោភលើជំនឿសាសនាជាដើម (សិទ្ធិជំនឿសាសនា Belief and Religion)។

ខ្មែរក្រោមងើបឡើងតវ៉ា អំពីអាជ្ញាធររឿតណាមដណ្តើមដីធ្លីប្រជាពលរដ្ឋ។ យួនចាប់ដាក់គុកធ្វើទុក្ខបុកម្នេញ គឺរំលោភលើសិទ្ធិជនជាតិភាគតិច ដែលយើងអាចយកបង្ហាញអន្តរជាតិ (សិទ្ធិជនជាតិភាគតិច Indigenous and Minority)។

ចំពោះប្រទេសខ្មែរវិញ ចំណុចណាដែលរដ្ឋាភិបាលមិនអាចការពារបាន ដូចជា រឿងយួនត្រួតត្រាខ្មែរ អន្តោប្រវេសន៍យួនបួនលានកន្លះ (៤ ៥០០ ០០០) ជម្លោះដីធ្លី ទំនិញឡើងថ្លៃ ប្រាក់ខែតិច ប្រជាពលរដ្ឋក្រីក្រ អំពើពុករលួយ បំបិទសិទ្ធិពលរដ្ឋមិនអោយធ្វើបាតុកម្មជាដើម (សង្គ្រាមនយោបាយ ឬ ចិត្តសាស្ត្រនយោបាយ Political Psychology)។ ចំណុចអស់ទាំងនេះ យើងត្រូវលើកយកធ្វើជាប្រធានបទឃោសនា។ យើងត្រូវបង្ហាញ ហេតុការណ៍ជាក់ស្តែងចំពោះមុខ ឬបង្ហាញវិធីដែលត្រូវដោះស្រាយបញ្ហាទាំងអស់នេះ។

ជំរើសយុទ្ធសាស្ត្រឃោសនានេះ វាអាស្រ័យលើអង្គការដឹកនាំនយោបាយ ដែលគេជ្រើសរើសយក។ តើយើងជាសមាជិកទាំងអស់គ្នាត្រូវតែប្តេជ្ញាចិត្តធ្វើអោយជោគជ័យ ឬគ្រាន់តែធ្វើអោយល្បីឈ្មោះមុខគេ ឬគ្រាន់តែប្រណាំងប្រជែង ឬ គ្រាន់តែដើម្បីមុខមាត់។

## III-យុទ្ធសាស្ត្រឃោសនាជាសាធារណៈ (Strategy of Public Relation)

**សកម្មភាពឃោសនាជាសាធារណៈមានដូចតទៅ :**

- ទំនាក់ទំនងជាមួយសារពត៌មាន
- ការប្រកាសអំពីគោលនយោបាយផ្សេងៗ
- ទំនាក់ទំនងទាំងក្នុងនិងខាងក្រៅប្រទេស
- ការបញ្ចុះបញ្ចូល
- ការប្រឹក្សា

**គោលដៅនៃការធ្វើការឃោសនាជាសារធារណៈ**

- ដើម្បីអោយប្រជាពលរដ្ឋដឹងអំពីសកម្មភាពថ្មីៗ និងគោលការណ៍នយោបាយថ្មី
- ដើម្បីកែប្រែគោលនយោបាយអោយនៅថ្មីជានិច្ច ចំពោះនយោបាយដែលទុំចាស់ហើយ
- ដើម្បីបង្កើតអោយមានផលប្រយោជន៍ និង ឱកាស ចំពោះអង្គការនយោបាយយើង
- ធ្វើអោយមានឥទ្ធិពល និង គាំទ្រពីសារធាណៈជន
- ដើម្បីការពារអំពីបញ្ហាដែលកើតឡើងជាសាធារណៈចំពោះគោលនយោបាយ និង អង្គការនយោបាយយើង (ពាក្យចចាមរាម និង ការរិះគន់ផ្សេងៗ)

**បង្កើតគោលដៅឃោសនា**

- ធ្វើអោយប្រជាពលរដ្ឋដឹងឮ ភ្ញាក់រលឹក ដុះឆន្ទៈស្រឡាញ់ជាតិខ្មែរ គិតផលប្រយោជន៍ជាតិធំជាងប្រយោជន៍បុគ្គល
- បង្កើតជំនឿជឿជាក់ដល់សមាជិក និងប្រជាពលរដ្ឋ
- លើកទឹកចិត្តក្រុមការងារ និងប្រជាពលរដ្ឋ
- កាត់បន្ថយការចំណាយឃោសនាផ្សេងៗដែលមិនចំទីសដៅ

**ឧបករណ៍សំរាប់ឃោសនាជាសាធារណៈ** (សិក្សាបន្ថែមក្នុងសៀវភៅពីរបបផ្តាច់ការទៅប្រជាធិបតេយ្យ)

១-ការផ្សព្វផ្សាយជាសារធារណៈ

២-ព្រឹត្តការណ៍

៣-សារពត៌មាន (វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្ដី ព្រឹត្តិប័ត្រ សៀវភៅ ខិតប័ណ្ណទូរស័ព្ទ ទូសារ អ៊ីមែល ភាពយន្ត ថាស ចំរៀង សារ ឯកសារ)

៤-សុន្ទរកថា

៥-សកម្មភាពជួយសង្គម និងសេវាសាធារណៈ

៦-សារពត៌មាន

៧-ភ្នាក់ងារ ទាំង ៥ ប្រភេទ

៨-ហិរញ្ញវត្ថុ

៩-បាតុកម្ម កូដកម្ម ។ល។

## IV. គ្រប់គ្រងបណ្តាញ (Network Management)

ការគ្រប់គ្រងបណ្តាញ គឺដូចគ្នាទៅនិងការគ្រប់គ្រងធនធានមនុស្សដែរ។ ក្រោយពីយើងស្រាវជ្រាវដឹងចំណុចខ្វះខាតរបស់បុគ្គលិក ខ្វះខាតចំនួនបុគ្គលិក ខ្វះខាតបច្ចេកទេស ឬស្មារតី។ យើងត្រូវធ្វើផែនការដើម្បីជ្រើសរើសបុគ្គលិកបន្ថែម ឬបណ្តុះបណ្តាលបុគ្គលិកចាស់អោយចំទីសដៅការងារ។ ក្រោយពីធ្វើផែនការយើងត្រូវជ្រើសរើសតាមផែនការដែលយើងកំណត់ មានន័យថា មុននិងយើងជ្រើសរើសអ្នកណាម្នាក់មកធ្វើជាសមាជិករបស់យើង យើងត្រូវធ្វើតាមគោលការណ៍នយោបាយរបស់យើង ឬតាមលក្ខខណ្ឌជ្រើសរើស។ យើងត្រូវមានគោលការណ៍នៃការជ្រើសរើស និងគោលការណ៍វាយតំលៃសំរាប់ផ្តល់រង្វាន់លើកទឹកចិត្តផ្សេងៗ។ បន្ទាប់មកយើងត្រូវធ្វើការបណ្តុះបណ្តាលបុគ្គលិក អោយទាន់ភាពរីកចំរើនរបស់ពិភពលោក និងមានសមត្ថភាព ខ្លាំងជាងគូរប្រកួតប្រជែងយើង ទាំងចំណេះឯកទេស ទាំងបច្ចេកវិទ្យា យុទ្ធសាស្រ្តផ្សេងៗ ដើម្បីអោយ មានប្រសិទ្ធភាពខ្ពស់ ការងារទទួលទិន្នផលខ្ពស់ និងជោគជ័យ។ បុគ្គលិកមានក្តីសង្ឃឹម និងមានមុខរបរ អាជីពដោយខ្លួនឯងនាពេលអនាគត។

# រៀបចំ (Organizing)

## I.រៀបចំរចនាសម្ព័ន្ធ (Structure Organization)

ការរៀបចំរចនាសម្ព័ន្ធ យើងអាចរៀបចំចែកចេញជាបីផ្នែកផ្សេងៗគ្នា។ ទី ១ យើងអាចរៀបចំរចនាសម្ព័ន្ធតាមឯកទេស ឬអាជីព ឬតាមផ្នែកប្រជាពលរដ្ឋ។ ឧទាហរណ៍ថា ផ្នែកព្រះសង្ឃ និស្សិត កម្មករ គ្រូបង្រៀនជាដើម។ ទី ២ យើងអាចរៀបចំតាមរបៀបត្រីកោណ ដែលមានប្រធាន អនុប្រធាន និងអ្នកឯកទេសមួយ។ ទី ៣ យើងអាចរៀបចំជាលក្ខណះចំរុះ ដែលមានប្រធានម្នាក់ កាន់កាប់មុខងារច្រើនផ្នែក ដូចជាផ្នែកបុគ្គលិក ពតិមាន ឃោសនា ផែនការ និងប្រតិបត្តិការជាដើម។

### ១-រៀបចំបែងចែកមុខងារ (Function Organization)

ការរៀបចំបែងចែកតាមមុខងារ មានសារៈសំខាន់ណាស់ ដើម្បីអោយអង្គការដឹកនាំអាចដំណើរការទៅបានលឿន និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការងារ។ សមាជិកធ្វើកិច្ចការតាមឯកទេស និងទេពកោសល្យរបស់គេរៀងៗខ្លួន។ ការរៀបចំរបៀបនេះ អាចធ្វើអោយទិន្នផលការងារទទួលបានផលខ្ពស់។ យើងត្រូវបែងចែកមុខងារតាមកិច្ចការរដ្ឋបាល ដែលមានប្រធាន អនុប្រធាន លេខា ផ្នែកគ្រប់គ្រងធនធានមនុស្ស (ស្ថិតិ)ផ្នែកពតិមាន ផ្នែកផែនការ ផ្នែកស៊ើបអង្កេត ផ្នែកចិត្តសាស្ត្រ ផ្នែកនយោបាយ និងផ្នែកវិច្ឆេទកម្ម ។ល។ ផ្នែកទាំងអស់អាចរៀបចំតាំងពីថ្នាក់លើដល់ថ្នាក់ក្រោម (ថ្នាក់មូលដ្ឋាន)។

### ២-រៀបចំតាមភូមិសាស្ត្រ (Geographic organization)

ការរៀបចំបែងចែកតាមភូមិសាស្ត្រនេះ គឺយើងបែកចែកអ្នកទទួលបន្ទុក អ្នកទទួលខុសត្រូវ តាមផ្នែកទីតាំងនីមួយៗ ដូចជា ថ្នាក់ភូមិភាគ តំបន់ ខេត្ត ស្រុក ឃុំ និងភូមិជាដើម។

ឧទាហរណ៍ នៅប្រទេសខ្មែរ យើងមានចំនួន ២០ខេត្ត និង៤ក្រុង។ ដូចនេះ យើងត្រូវរៀបចំអោយមានអ្នកទទួលខុសត្រូវតាមខេត្តក្រុងនីមួយៗ ចាប់តាំងពីថ្នាក់ខេត្តរហូតដល់ថ្នាក់មូលដ្ឋាន ភូមិ ឃុំ។ អ្នកទទួលខុសត្រូវចាំបាច់ត្រូវមានសមត្ថភាពខ្ពស់។

### ៣-រៀបចំការបែងចែកតាមប្រភេទប្រជាពលរដ្ឋ ( Kinds of Citizens)

ការរៀបចំតាមប្រភេទប្រជាពលរដ្ឋនេះ គឺយើងត្រូវរៀបចំតាមប្រភេទទាំងអស់ពីគ្រប់ស្រទាប់ក្នុងសង្គម។ ដូចជា ផ្នែកកសិករ ពាណិជ្ជករ ទាហាន ប៉ូលីស និស្សិត គ្រូបង្រៀន កម្មករ សហជីព ម៉ូតូឌុប ។ល។ ក្នុងចំណោមពលរដ្ឋទាំងអស់នេះ យើងត្រូវរៀបចំអោយមានរចនាសម្ព័ន និងប្រព័ន្ធការងារត្រឹមត្រូវ គឺមានអ្នកទទួលខុសត្រូវម្នាក់ក្នុងចំណោមផ្នែកនីមួយៗ។

## II.ការរៀបចំបណ្តាញ (Networks Organizing)

### ១.រៀបចំគំរោងបណ្តាញ (Design the Intelligences Plan)

ក្នុងការរៀបចំគំរោងបណ្តាញ គឺដូចជារៀបចំគំរោងផ្សេងៗដែរ។ មុនដំបូងយើងត្រូវធ្វើការសិក្សាលើគោលដៅ ដែលត្រូវរៀបចំលើផែនទីអោយបានល្អិតល្អន់សិន ទើបយើងយកគំរោងដែលសិក្សានោះ ទៅរៀបចំលើ

តារាងផ្ទាល់។ យើងត្រូវមើលគោលដៅ ធនធាន មនុស្ស វិធីសាស្ត្រ បច្ចេកទេសក្នុងការរៀបចំ និងរយៈពេលដែលប្រតិបត្តិការ ក្រោយមកយើងវាយតំលៃលើលទ្ធផលអតិបរមា ដែលអង្គការនយោបាយយើងអាចទទួលបាន តើអវិជ្ជមាន ឬផលប្រយោជន៍វិជ្ជមាន។

## ២-គោលដៅបណ្ដាញ (Objective of Intelligences)

គោលដៅនៃការរៀបចំបណ្ដាញរបស់យើង គឺយើងត្រូវស្វែងរកសមាជិកថ្មីៗ ពង្រីកសមាជិករបស់យើងនៅក្នុងប្រទេសខ្មែរ ឬខ្មែរនៅបរទេសអោយកាន់តែច្រើន ដើម្បីធ្វើកិច្ចការសំរាប់រំដោះប្រទេសជាតិខ្មែរ អោយសំរេចជោគជ័យ។ ចំពោះសមាជិកនៅក្នុងប្រទេសខ្មែរវិញ យើងត្រូវបែងចែកជាភូមិសាស្ត្រ តាមខេត្ត ក្រុង ស្រុក ឃុំ ភូមិ ឬតាមផ្នែកផ្សេងៗនៃប្រជាពលរដ្ឋ (ប្រជាសាស្ត្រ) ដូចបានរៀបរាប់ខាងលើ។ សមាជិកដែលយើងរើសមករៀបចំជាបណ្ដាញរបស់យើង ត្រូវអនុវត្តតាមគោលការណ៍ជ្រើសរើសសមាជិករបស់អង្គការនយោបាយ យើងដោយធានាថាពួកគេយល់ដឹងអំពីគោលបំណង ទិសដៅ និងគោលការណ៍ផ្សេងៗច្បាស់លាស់។ បន្ទាប់មកពួកគេអាចធ្វើការយ៉ាងសកម្មបំផុត ដើម្បីបង្ហាញ បកស្រាយ ឃោសនា និងឆ្លើយតបចំពោះប្រជាពលរដ្ឋ និងគូរប្រកួតប្រជែងអោយមានប្រសិទ្ធភាព។ ប្រតិកម្មចំពោះមជ្ឈដ្ឋានផ្សេងៗ បំភ្លឺអោយពួកគេយល់កាន់តែច្បាស់អំពីគ្រោះថ្នាក់របស់ប្រទេសជាតិ។ យើងត្រូវជំរុញលើកទឹកចិត្តប្រជាពលរដ្ឋខ្មែរ អោយចូលរួមកាន់តែច្រើន។ សមាជិកបណ្ដាញទាំងអស់ត្រូវយល់ដឹងអំពីភារកិច្ចរៀងខ្លួនៗ ថាតើខ្លួនត្រូវធ្វើអ្វីខ្លះ? យើងជាឃោសនិកត្រូវប្រមូលពតិមាន ចែកចាយឯកសារឃោសនា ឃោសនា (តាមគ្រប់រូបភាព) ដល់ប្រជាពលរដ្ឋខ្មែរ ដើម្បីអោយអង្គការនយោបាយយើងរីកចំរើនទៅគ្រប់មជ្ឈដ្ឋាន។

## ៣-យុទ្ធសាស្ត្របណ្ដាញ (Strategy of Intelligence )

យើងអាចរៀបចំបណ្ដាញអោយបានទូទាំងប្រទេស និងគ្រប់ទីកន្លែងនៅក្នុងប្រទេសខ្មែរ ឬ នៅបរទេស ។ យើងអាចរៀបចំបណ្ដាញក្នុងជួររបស់គូរប្រកួតប្រជែងយើង តាមស្ថាប័នផ្សេងៗ។ ការរៀបចំបណ្ដាញនេះ ដើម្បីអោយពួកគេខិតខំជួយធ្វើការ ប្រឹងប្រែងលើកស្ទួយអង្គការដឹកនាំនយោបាយយើង អោយសំរេចជោគជ័យក្នុងកិច្ចការជួយរំដោះ ការពារជាតិខ្មែរអោយរួចផុតពីកណ្ដាប់ដៃកុម្មុយនិស្តយួន និងរបបកុម្មុយនិស្ត **ហ៊ុន សែន** ។ យើងត្រូវរៀបចំជាខ្សែបណ្ដោយ និងខ្សែទទឹង។ ប៉ុន្តែ ធ្វើយ៉ាងណា មិនអនុញ្ញាតអោយបណ្ដាញនីមួយៗ ស្គាល់គ្នាជាដាច់ខាត។ បុគ្គលម្នាក់អាចរៀបចំមនុស្សរាប់ពាន់នាក់តាមលទ្ធភាពដែលខ្លួនធ្វើបាន ប៉ុន្តែត្រូវធ្វើផ្ទាល់ម្នាក់ទៅម្នាក់ប៉ុណ្ណោះ មិនអនុញ្ញាតអោយស្គាល់មនុស្សទី ៣ ទេ។

ឧទាហរណ៍ថា បុគ្គល ក ទៅរើសបុគ្គល ខ ធ្វើជាបណ្ដាញ ។ ចំណែកបុគ្គល ខ ទៅរើសបុគ្គល គ ហេតុដូច្នេះហើយបុគ្គល ក និងបុគ្គល គ មិនអនុញ្ញាតអោយស្គាល់គ្នាទេ។ បុគ្គល ក ទៅរើសបុគ្គល ច ជាបណ្ដាញទៀត តែមិនត្រូវអោយបុគ្គល ខ និង ច ស្គាល់គ្នាដូចគ្នាដែរ។ ត្រូវចាំថាបុគ្គល ខ និងបុគ្គល ច មិនត្រូវចាំបាច់ប្រាប់បុគ្គល គ និង ឆ ថាមានបុគ្គល ក ជាមេ ឬ ក្រុមការងារឡើយ។ គឺមានន័យថា យើងអនុវត្តតគ្នាជាខ្សែងរហូតដល់ក្រោម។

## ៤. រចនាសម្ព័ន្ធបណ្ដាញ (Structure of Intelligence)

រចនាសម្ព័ន្ធបណ្ដាញ គឺយើងធ្វើយ៉ាងណាអោយមានភាពស្វាហាប់ និងរស់រវើក។ យើងរៀបចំអោយមានភ្នាក់ងារបណ្ដាញនីមួយៗ ស្គាល់ច្បាស់អំពីគោលដៅ តួនាទី និងភារៈកិច្ចរបស់ខ្លួន។ ពួកគេត្រូវមានសមត្ថភាពដូចៗគ្នា។ យើងអាចរៀបចំបណ្ដាញតាមផ្នែកនីមួយៗនៃប្រជាពលរដ្ឋខ្មែរ បណ្ដាញ**ទី១** យើងត្រូវមានមេបណ្ដាញ ព្រះសង្ឃ ទាហាន ប៉ូលីស គ្រូបង្រៀន កម្មករ កម្មការនី យុវជន យុវនារី និស្សិត (ប្រុស ស្រី) និង ប្រជាពលរដ្ឋខ្មែរទូទៅ។ **ទី២** យើងត្រូវរៀបចំសមាជិកតាមភូមិសាស្ត្រនៅក្នុងប្រទេសខ្មែរ ដូចជាភូមិភាគ ខេត្តក្រុង រហូតដល់ភូមិជាដើម។ វាអាចមានមេបណ្ដាញតាមបណ្ដាប្រទេសនីមួយៗនៅក្រៅប្រទេស។ **ទី៣** យើងបង្កើតមេបណ្ដាញតាមភារៈកិច្ច និងតួនាទីមួយៗ ភ្នាក់ងារពតិមាន ចារកម្ម ភ្នាក់ងារស្ទួន ភ្នាក់ងារពិសេស និងក្រុមប្រឆាំងចេញមុខជាដើម។ **ទី៤** យើងអាចប្រើវិធីចំរុះបញ្ចូលគ្នាតែម្ដង តាមភូមិសាស្ត្រនីមួយៗ មេបណ្ដាញមួយត្រូវមើលការខុសត្រូវច្រើនមុខងារផ្សេងៗគ្នា។

## ៥. ទំហំបណ្ដាញ (Scope of Intelligence)

បណ្ដាញយើងត្រូវកំណត់យកត្រឹម ២៤ខេត្តក្រុង តាមរយៈទីតាំងភូមិសាស្ត្រ និងតាមលក្ខណៈប្រជាសាស្ត្រតាមផ្នែកនីមួយៗ ដូចជា និស្សិត ព្រះសង្ឃ កម្មករ ម៉ូតូឌុប គ្រូបង្រៀន ប្រជាពលរដ្ឋ ប៉ូលីស ទាហាន គ្រប់ខេត្តក្រុងទូទាំងប្រទេស។ យើងអាចរៀបចំបណ្ដាញចេញពីគ្រប់គណបក្សនយោបាយ ។ល។

## ៦. ការឧទ្ទាត់អោយបណ្ដាញ (Compensation for Intelligences)

ក្រោយពីការជ្រើសរើសមកធ្វើជាបណ្ដាញអោយយើងហើយ យើងត្រូវគិតគូរលើកទឹកចិត្តបណ្ដាញដែលជាសមាជិកនយោបាយយើង ដើម្បីអោយពួកគេខិតខំធ្វើការរហូតបានដល់ជោគជ័យ ដូចជាការផ្ដល់ជាប្រាក់ខែ ប្រាក់ឧបត្ថម្ភ ប្រាក់បេសកកម្ម និងរង្វាន់លើកទឹកចិត្តផ្សេងៗទៅតាមតំរូវការរបស់ពួកគេ ធ្វើយ៉ាងណាដើម្បីអោយការងារកាន់តែមានប្រសិទ្ធភាព និងមានទិន្នផលខ្ពស់។

## ៧. ជ្រើសរើសមេបណ្ដាញ (Selecting The Chief of Intelligence)

ការសំរាំងជ្រើសរើសមេបណ្ដាញដែលមានប្រសិទ្ធិភាពក្នុងការងារមានសារៈសំខាន់ណាស់ ដើម្បីអោយការងារមានការរីកចំរើនលូតលាស់។ យើងអាចធ្វើឡើងតាមរយៈការបោះឆ្នោត ឬការវាយតំលៃចេញពី ៦ មជ្ឈដ្ឋាន។ សំខាន់យើងត្រូវជ្រើសរើសយកសមាជិក ដែលមានលក្ខណៈជាមេដឹកនាំ ឬយើងជ្រើសរើសតាមគោលការណ៍ដឹកនាំរបស់អង្គការនយោបាយយើង។ សមាជិកនោះយ៉ាងហោចណាស់ ត្រូវបញ្ចប់បរិញ្ញាប័ត្រ ឬកំពុងរៀនបន្ត មានចំណេះភាសាបរទេស (អង់គ្លេស) មានចំណេះខាងបច្ចេកវិទ្យា កុំព្យូទ័រជាដើម។ *មេបណ្ដាញនីមួយៗ ដាច់ខាតមិនត្រូវធ្វើអោយអ្នកក្រោមបង្គាប់ស្អប់ ដោយសារចំណុចខ្សោយផ្សេងៗ ដូចជាលោភលន់បុណ្យស័ក្ក អំណាច ល្មោភ ស្រី ស្រា និងល្បែងជាដើម។ បើមេបណ្ដាញនោះគ្មានប្រជាប្រិយ មានន័យថាមេបណ្ដាញនោះ មិនអាចដឹកនាំប្រជាពលរដ្ឋបានឡើយ ហើយអង្គការនយោបាយយើងមិនអាចទទួលបានជោគជ័យដែរ។*

### ៨.ហ្វឹកហាត់មេបណ្តាញ (Training for the Chief of Intelligence)

ការហ្វឹកហាត់មេបណ្តាញនេះ យើងត្រូវធ្វើយ៉ាងណាអោយមេបណ្តាញនីមួយៗ មានប្រសិទ្ធភាពក្នុងការងារ។ មេបណ្តាញនីមួយៗត្រូវតែជាមនុស្សប្រាកដប្រជានឹងការងារ ស្នេហាជាតិពិតៗ និងជាមនុស្សដែលទទួលខុសត្រូវខ្ពស់ក្នុងការងារ។ ពួកគេត្រូវមានឯកទេសក្នុងការងារធ្វើជាបណ្តាញ ភាពជាមេដឹកនាំ ឯកទេសឃោសនា យល់ដឹងអំពីនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗ។ ជាពិសេស មេបណ្តាញនីមួយៗត្រូវស្គាល់អំពីគោលការណ៍ និងគោលនយោបាយទាំងឡាយរបស់អង្គការនយោបាយជាតិខ្មែរ។ មេដឹកនាំបណ្តាញត្រូវស្គាល់អំពីចរិកលក្ខណះ តំរូវការ ទំនោរ បញ្ហាជាអទិភាពរបស់ប្រជាពលរដ្ឋខ្មែរ និងចរិកលក្ខណៈរបស់គូរប្រកួតប្រជែង។ មេដឹកនាំបណ្តាញត្រូវតែយកចិត្តទុកដាក់ធ្វើយ៉ាងណា ដើម្បីអោយការឃោសនាមានប្រសិទ្ធិភាព និងដើម្បីអោយសមាជិករបស់ខ្លួនមានប្រសិទ្ធភាព និងគុណភាពក្នុងការអនុវត្តការងារ។ មេដឹកនាំបណ្តាញត្រូវយល់អំពីនិតិវិធីផ្សេងៗ និងការទទួលខុសត្រូវរបស់ខ្លួន។ ***ពតិមានទាន់ពេលវេលា និងច្បាស់លាស់ ជាកត្តាមួយអាចនាំទៅរកជោគជ័យផងដែរ។***

### ៩.លើកទឹកចិត្តមេបណ្តាញ (Motivating the Intelligences)

ការលើកទឹកចិត្តបុគ្គលិកជាកត្តាសំខាន់ណាស់ ដែលនាំអោយសមាជិកខិតខំប្រឹងប្រែងធ្វើការ ដើម្បីគោលបំណងរួមរបស់អង្គការនយោបាយ។ *កាលបើសមាជិកខិតខំប្រឹងប្រែង ព្រួដចិត្តទាំងអស់គ្នា ធ្វើការសំរាប់គោលបំណងរួម ការងារនោះពិតជាសំរេចជោគជ័យបាន។* យើងប្រៀបប្រដូចកីឡាករបាល់ទាត់ ដែលគេខិតខំលេងទាំងអស់គ្នា ដើម្បីទាត់បញ្ចូលទីយ៉ាងដូច្នោះដែរ។ យើងត្រូវប្រគល់រង្វាន់អ្វី ដែលសមនឹងស្នាដៃរបស់គេ ធ្វើអោយសមាជិកពេញចិត្តនិងការងារ រឹតតែខិតខំប្រឹងប្រែងធ្វើកិច្ចការទ្វេរឡើង។

### ១០.វាយតំលៃបណ្តាញ (Evaluating the Intelligences)

ការវាយតំលៃទៅបាន យើងត្រូវពិនិត្យមើលតាមប្រភពពតិមានដែលទទួលបាន ដូចជា របាយការណ៍របស់ភ្នាក់ងារ ការអង្កេតផ្ទាល់ ការវាយប្រហារិះគន់ផ្សេងៗរបស់ប្រជាពលរដ្ឋ និង គូរប្រកួតប្រជែង សង្គមស៊ីវិល ការស្ទង់មតិ សន្ទនាផ្ទាល់ជាមួយមេបណ្តាញនីមួយៗ និងការប្រជុំបូកសរុបការងារជាដើម។ តើយើងត្រូវវាយតំលៃទៅលើអ្វីខ្លះ?យើងត្រូវវាយតំលៃលើការគាំទ្ររបស់ប្រជាពលរដ្ឋ ការប្រៀបធៀបរវាងប្រសិទ្ធភាពបណ្តាញនីមួយៗ ការប្រៀបធៀបចំនួនគាំទ្រពីអតីតកាល និងបច្ចុប្បន្នកាល។ ការវាយតំលៃទៅលើការចំណាយឃោសនា ចំនួនអ្នកគាំទ្រ អ្នកគាំទ្រថ្មីៗ ការបាត់បង់អ្នកគាំទ្រ។ល។

### ១១.បង្កើនប្រសិទ្ធភាពបណ្តាញ (Capacity Building of Intelligence)

បង្កើនប្រសិទ្ធិភាពបណ្តាញ ជាកត្តាមួយចាំបាច់ ដើម្បីអោយសំរេចជោគជ័យដល់គោលដៅ ការងារនឹងមានប្រសិទ្ធភាព និងបានផលខ្ពស់។ យើងត្រូវផ្តល់ឱកាសដល់បណ្តាញ ត្រូវតែបណ្តុះបណ្តាលពួកគេ តាមរយៈការធ្វើសិក្ខាសិលា ផ្តល់ឱកាសសិក្សាបន្ថែមទាំងចំណេះបច្ចេកទេស និងបច្ចេកវិទ្យា។ យើងផ្តល់ឯកសារស្រាវជ្រាវលើកទឹកចិត្តអោយមានការសិក្សាស្រាវជ្រាវដោយខ្លួនឯង ស្រាវជ្រាវតាមបណ្តាល័យ ការអានសៀវភៅដោយ

ខ្លួនឯង ស្តាប់វិទ្យុ អ៊ីនធឺណែតជាដើម ។ នៅកន្លែងធ្វើការមានការសែត ទូរទស្សន៍ ឬវិទ្យុ សំរាប់បង្កើនចំណេះដឹងថ្មីៗ ។

**១២-ការហ្វឹកហាត់សាពជាអ្នកធ្វើបណ្តាញ** (Training the Intelligences)

ក្រោយពីចូលជាសមាជិករបស់បណ្តាញនៃអង្គការនយោបាយយើង សមាជិកទាំងអស់ត្រូវហ្វឹកហាត់អោយចេះអំពីបច្ចេកទេស និងយុទ្ធវិធីរបស់បណ្តាញ ព្រមទាំងចំណេះផ្សេងៗទៀតទាក់ទងនឹងការងារយើង។ ការបណ្តុះបណ្តាលចែកចេញជា ៣ ដំណាក់កាល។ ដំណាក់កាលទី ១ យើងត្រូវបណ្តុះបណ្តាលបណ្តាញអោយចេះអំពីចំណេះវិជ្ជាដែលយើងធ្វើការ ដើម្បីរំដោះប្រទេសអោយឯករាជ្យ មុខវិជ្ជាទាំងនោះ មានយុទ្ធសាស្ត្រ និងយុទ្ធវិធីភាពជាអ្នកដឹកនាំ នយោបាយ ឃោសនា និងការរៀបចំផ្សេងៗ។ ដំណាក់កាលទី ២ យើងត្រូវបណ្តុះបណ្តាលសមាជិក អំពីរដ្ឋបាលដឹកនាំ សំរាប់ពេលដែលយើងដឹងនាំប្រទេស មានប្រព័ន្ធរដ្ឋបាល ច្បាប់ទំលាប់ផ្សេងៗ។ ដំណាក់ការការងារ យើងអាចបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេស។ ដំណាក់ទី៣ យើងត្រូវបញ្ជូនសមាជិកសំខាន់ៗ ទៅបណ្តុះបណ្តាលតាមបណ្តាប្រទេសមហាអំណាចសេរី ដូចជាសហរដ្ឋអាមេរិក អង់គ្លេស ជប៉ុន កូរ៉េខាងត្បូង និង អូស្ត្រាលី ជាដើម។

**១៣-ឯកទេសចរចារ** (Negotiation Skills)

ការចរចារនេះ កើតឡើងនៅពេលអង្គការនយោបាយផ្សេងៗ ចង់ចូលរួមជាមួយនិងអង្គការនយោបាយយើង ដែលមានចាប់ពី ២ភាគី ឬច្រើនភាគីឡើងទៅ ឬពេលដែលធ្វើកិច្ចសន្យា ចុះហត្ថលេខាលើសន្ធិសញ្ញាផ្សេងៗ ការធ្វើសមាហរណកម្ម (ការដាក់បញ្ចូលគ្នា) ជាដើម។ ការចរចារនេះ មានលក្ខណៈពិសេស ដូចតទៅ :

- ត្រូវមានភាគីយ៉ាងហោចណាស់ ចាប់ពី ២ ឡើងទៅ
- ភាគីដែលមានជម្លោះផលប្រយោជន៍ ឬបញ្ហាច្រើន
- នៅពេលដែលចចារ អ្នកចរចារត្រូវប្រើសមត្ថភាព និងបច្ចេកទេសផ្សេងៗ ដើម្បីសំរេចគោលដៅរបស់ខ្លួន

**គោលការណ៍ នៃការចរចារ** (Principles of Negotiation)

១-ញែកមនុស្សចេញពីបញ្ហា (កុំគិតអំពីបញ្ហាបុគ្គល ឬបុគ្គលិកលក្ខណៈបុគ្គល តែលើកជាបញ្ហា ឬ ផ្តោតលើដោះស្រាយបញ្ហា)។

២-ផ្តោតលើផលប្រយោជន៍របស់ជាតិ ឬ អង្គការនយោបាយយើង មិនមែនផ្តោតលើអំណាចតំណែងទេ។

៣-បង្កើតជំរើសសំរាប់ផលចំណេញទៅវិញទៅមក (ឈ្នះទាំងសងខាង ឬចំណេញទាំងសងខាង) ។

៤-ពិភាក្សាសំណើ អោយចំលក្ខខណ្ឌគោលដៅ

## ១៤. ជំនាញបង្កើតទំនាក់ទំនង (Communication Skill)

ការទំនាក់ទំនងដើម្បីអោយមានសមាជិកថ្មី ជាកត្តាសំខាន់ណាស់ សំរាប់ឃោសនិក យើងត្រូវធ្វើការទំនាក់ទំនង គ្រប់មជ្ឈដ្ឋាន ដែលបានរៀបរាប់ខាងលើ ដើម្បីពង្រីកសកម្មភាពការងារ ដោយយើងបង្កើតឱកាសទំនាក់ទំនង តាមទេពកោសល្យ និងការប៉ិនប្រសព្វរបស់ខ្លួន។ *បើទំពក់មិនទៅ ពៅមិន ជ្រុះឡើយ*។ នេះជាពាក្យទំនាក់ទំនងមួយរបស់ភាសិតខ្មែរសំរាប់យកមកពិចារណា។ បើយើងមិនធ្វើការ ទាក់ទងទៅមនុស្សផ្សេងទៀត ធ្វើដូចម្តេចទើបគេស្គាល់យើង ឬយើងអាចស្គាល់គេ ។ ប្រសិទ្ធភាពនៃទំនាក់ទំនង ត្រូវចេះជួយយកអាសារផ្សេងៗដល់ប្រជាពលរដ្ឋ និងបុគ្គលដ៏ទៃទៀត។ យើងត្រូវស្គាល់ឈ្មោះ និងទីកន្លែងអ្នកដែលទំនាក់ទំនងអោយច្បាស់លាស់។ យើងត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាផ្សេងៗ មិនលើកតំកើង អួតខ្លួនឯង ហើយបន្ទះបន្ទាប់អ្នកដ៏ទៃ និងមើលងាយអ្នកដ៏ទៃ ត្រូវដាក់ខ្លួនសាមញ្ញអោយទាបស្មើនិងអ្នកដែលយើងទំនាក់ទំនង (សំរបតាមស្ថានការណ៍) កុំនិយាយពីបញ្ហារបស់ខ្លួនឯងប្រាប់គេ នេះជារឿងមិនល្អទេ គេមិនចង់ស្តាប់រឿងយើងទេ តែគេចង់ស្តាប់រឿងរបស់គេ។ល។

# អនុវត្តន៍ (Implementing)

I.**ទទួលស្គាល់ និង កំណត់បញ្ហា** (Recognize and Remark Issues)

មុននិងយើងលើកយកប្រធានបទមួយយកមកឃោសនា ឃោសនិកត្រូវកំណត់បញ្ហាអោយបានច្បាស់លាស់ ពោលគឺបញ្ហាដែលសំខាន់ជាងគេ មានអាទិភាពបំផុត ជាឫសគល់នៃបញ្ហា ឫជាបញ្ហាកើតឡើងថ្មីៗ។ កាលណាយើង កំណត់បញ្ហាបានច្បាស់លាស់ហើយ ទើបយើងលើកយកប្រធានបទដែលទាក់ទងនិងបញ្ហានោះយកមក ធ្វើការដោះស្រាយតាមវិធិសាស្ត្រ រូបមន្តត្រឹមត្រូវ ឬឃោសនាតាមផែនការដែលបានគ្រោងទុក។

II.**វាយតំលៃកំរិតអង្គការនយោបាយ** (Evaluate the level of Political Organization)

ការវាយតំលៃកំរិតអង្គការដឹកនាំរបស់អង្គការនយោបាយមួយចែកចេញជា ៣ ផ្នែក។ ផ្នែកទី១ គេអាចវាយតំលៃទៅលើផ្នែកយុទ្ធសាស្ត្រ ទី២ ផ្នែកប្រតិបត្តិការ និងទី៣ ផ្នែកបច្ចេកទេស។ ដូច្នេះដើម្បីអោយមានប្រសិទ្ធិភាព និងឈានទៅរកជោគជ័យ យើងត្រូវធ្វើការប្រៀបធៀបចំណុចទាំង ៣ ខាងលើនេះជាមួយគូរប្រកួតប្រជែងយើង បើយើងមានប្រៀបចំណុចទាំង៣ផ្នែកនេះ ទើបយើងឈ្នះ។ *មានន័យថា មុនយើងចាប់ផ្តើមអនុវត្តន៍ផែនការរបស់យើង យើងត្រូវប្រៀបធៀបខ្លួនយើងជាមួយសត្រូវសិន បើយើងមើលឃើញថាឈ្នះ ទើបយើងអនុវត្តន៍។ តែមិនមានន័យថា សត្រូវមានកម្លាំងច្រើន ឬមានប្រៀបលើយើងគ្រប់យ៉ាង យើងអាចសន្និដ្ឋានថា សត្រូវអាចខ្លាំង ឬយើងមិនអាចយកជ័យជំនះនោះទេ កត្តាសំខាន់ គឺ ឯកទេស និង វិន័យរបស់កម្លាំងយើង ធ្វើការវាយលុកចំណុចស្លាប់រស់របស់សត្រូវ យើងក៏អាចឈ្នះបានដែរ។ យើងត្រូវប្រើយុទ្ធវិធី ឬអ្វីដែលសត្រូវនឹកស្មានមិនដល់។*

ឧទាហរណ៍ នៅសង្គ្រាមលោកលើកទី២ កងទ័ពជប៉ុនរាតត្បាតពាសពេញពិភពលោក ស្ទើតែទទួលបានជ័យជំនះ គ្រួតត្រាពិភពលោកទៅហើយ តែសហរដ្ឋអាមេរិកប្រើគ្រាប់បរមាណូតែ២គ្រាប់ អាចបញ្ចប់សង្គ្រាម និងឈ្នះជប៉ុនបាន នេះជាយុទ្ធសាស្ត្រ ដែលជប៉ុននឹកស្មានមិនដល់ថា សហរដ្ឋអាមេរិកមានគ្រាប់បរមាណណូ ទីបំផុតជប៉ុនចាញ់សង្គ្រាមទៅ។

III.**អនុវត្តវិធីសាស្ត្រឃោសនា** (Implementing the Propaganda Method)

**១_ចិត្តសាស្ត្រទូទៅ** (General Pshchology)

ជាចំណុចសំខាន់បំផុតសំរាប់ស្ថានភាពនយោបាយនៅក្នុងប្រទេសខ្មែរបច្ចុប្បន្ន។ អ្នកឃោសនាត្រូវធ្វើតាមរបៀបចិត្តសាស្ត្រសំរាប់ស្ថានភាពប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន។ អ្នកឃោសនាមិនត្រូវធ្វើអោយប្រជាពលរដ្ឋស្អប់ឡើយ។ យើងរៀបចំខ្លួនអោយថ្លៃថ្នូរ មានសីលធមិ គុណធមិ សប្បុរស ស្មោះត្រង់ ក្លាហាន ដើម្បីអោយប្រជាពលរដ្ឋខ្មែរស្រឡាញ់យើងជាមុនសិន។ ចំណុចផ្សេងទៀត ដែលប្រជាពលរដ្ឋខ្មែរស្រឡាញ់នោះ គឺ យើងត្រូវស្គាល់អំពីទំនៀមទំលាប់ប្រពៃណីរបស់ខ្មែរតាមតំបន់នីមួយៗ សុជីវធម៌ល្អ ឱនលំទោន ជំរាបសួរ អរគុណ សុំទោស និងជួយរាល់កិច្ចការដែលប្រជាពលរដ្ឋខ្មែរត្រូវការជំនួយ មិនប្រកាន់ខ្លួនវាយឫក ទោះជាកិច្ចការតូចឬធំឡើយ។ យើងត្រូវស្គាល់អំពីទំនោរ និងការយល់ដឹងរបស់ប្រជាពលរដ្ឋដល់កំរិតណា ដូច្នេះ ពេលដែលឃោសនា

ពន្យល់ យើងត្រូវលើកបញ្ហា ពាក្យពេចន៍ អ្វីដែលគាត់យល់ ចំនិងកិច្ចការងាររបស់គាត់។ យើងអាចលើកយកមកជជែកគ្នាលេង មានលក្ខណៈសាមញ្ញ តែមានន័យ សកម្ម រស់រវើក និងចាប់អារម្មណ៍។ ចំណុចដែលមានប្រសិទ្ធភាពបំផុត គឺយើងមិនត្រូវប្រាប់ថា ខ្លួនយើងជាបុគ្គលិកនយោបាយណាមួយឡើយ យើងត្រូវនិយាយថាជានិស្សិត ឬអ្នកធ្វើការងារក្រៅរដ្ឋាភិបាល ឬក្នុងនាមជាជាតិខ្មែរម្នាក់ ដែលមានការខ្វាយខ្វល់អំពីអាយុជីវិតប្រទេសជាតិ។ យើងធ្វើដូចនេះ ដើម្បីរក្សាប្រជាប្រិយភាព ពីព្រោះប្រជាពលរដ្ឋខ្មែរ គាត់ខ្លាចពាក្យថា **នយោបាយ** ព្រោះគាត់មិនបានយល់ដឹងជ្រៅជ្រះអំពីនយោបាយឡើយ។

**២-សង្គ្រាមចិត្តសាស្ត្រ ឬ ចិត្តសាស្ត្រនយោបាយ** (Political Psychology)

យោសនិកត្រូវលើកយកបញ្ហាសង្គម ដែលកំពុងប្រឈមមុខចំពោះប្រជាពលរដ្ឋរាល់ថ្ងៃ អ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដូចជាការរំលោភដីធ្លី ជិះជាន់ឡើង ដោយពួកអ្នកមានអំណាច និងពួកយួននៅក្នុងរបបកុម្មុយនិស្ត **ហ៊ុន សែន**។ យើងត្រូវវាយលុកចំចំណុចខ្សោយរបស់សត្រូវ បំបែកចំណុចខ្លាំងរបស់សត្រូវអោយខ្សោយ។ យើងត្រូវលើកអំពីចំណុចអសមត្ថភាពរបស់ពួកយួន និង **ហ៊ុន សែន** ដែលមិនអាចដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ហើយមានតែការជិះជាន់ ធ្វើបាប ក្រោមលេសថា **វិនិយោគ** និង **អភិវឌ្ឍន៍**។ បើសិនជាយើងដឹងថា អ្នកស្តាប់ចង់ស្តាប់អំពីអ្វី យើងត្រូវលើកបញ្ហានោះមកឃោសនា ឬជជែក ជាពិសេសនិយាយអោយចំបញ្ហាអ្នកស្តាប់។

ឧទាហរណ៍ ដូចជាបញ្ហារាល់ថ្ងៃដែលកំពុងកើតមានក្នុងប្រទេសខ្មែរយើង មានជនអន្តោប្រវេសន៍យួន អំពើពុករលួយ រឹបអូសយកដីធ្លី ក្រីក្រ អយុត្តិធម៌ ប្រាក់ខែតិច ព្រំដែន អតិផរណា និងទំនិញឡើងថ្លៃជាដើម ។

ខ្ញុំសូមលើយកបទពិសោធន៍របស់នាយទាហាន ដែលបានទៅរៀននៅប្រទេសម៉ាឡេស៊ី ថ្ងៃមួយនាយទាហានប្រមាណ៦០នាក់កំពុងហ្វឹកហ្វឺនអស់រយៈពេលជាង៣ខែហើយ។ លោកគ្រូមើលឃើញចិត្តសាស្ត្រ ទាហានទាំងអស់ ចង់វិលត្រឡប់មកផ្ទះវិញ ហេតុដូច្នេះហើយ លោកគ្រូក៏ប្រាប់កូនសិស្សអោយរៀបចំឥវ៉ាន់ ដើម្បីត្រៀមឡើងយន្តហោះ ត្រឡប់មកផ្ទះវិញនៅថ្ងៃស្អែក។ ពេលនោះស្រាប់តែ កូនសិស្សបាននិយាយផ្តាំផ្ញើរ គ្នាដោយចិត្តរំភើប ខ្លះសរសេរសំបុត្រ ដើម្បីផ្ញើទៅក្រុមគ្រួសារ ដោយគិតថាជារឿងពិត។ តែពេលស្អែកឡើងម្នាក់ៗត្រៀមឥវ៉ាន់រួចអស់ហើយ ស្រាប់តែដល់ពេលមកដល់សាលារៀន លោកគ្រូចាប់ផ្តើមនិយាយថា តើរៀបចំឥវ៉ាន់ទៅណា ពេលនោះទាហានបានឆ្លើយតាមដូចគ្រូនិយាយ។ ទើបគ្រូឆ្លើយថា មិនមែនទេ នេះហើយ គឺមេរៀន **សង្គ្រាមចិត្តសាស្ត្រ**។

**៣-សង្គ្រាមនយោបាយ** (Political War)

សង្គ្រាមនយោបាយ គឺជាការប្រឆាំងនិងគំនិតនយោបាយរបស់អង្គការនយោបាយណាមួយ ដោយមានហេតុផលផ្សេងៗគ្នា។ ឧទាហរណ៍ គណបក្សប្រជាជនលើកឡើងថា ៧ មករា ១៩៧៩ ជាថ្ងៃរំដោះប្រជាពលរដ្ឋខ្មែរអោយមានជីវិតឡើងវិញ។ ចំណែកមតិខ្លះទៀតថា ៧ មករា ១៩៧៩ ជាការឈ្លានពានរបស់យួន ដែលរំលោភប្លន់យកទ្រព្យសម្បត្តិ និងទឹកដីខ្មែរ។ គណបក្សប្រជាជនតែងតែលើកយករបបប៉ុល ពត យកមកនិយាយដើម្បីដុតកំហឹងដល់ប្រជាពលរដ្ឋខ្មែរ អោយចងកំហឹងនឹងខ្មែរគ្នាឯង ដើម្បីអោយខ្មែរបែកបាក់គ្នា តែដឹងគុណយួន។

ចំណែកអង្គការនយោបាយផ្សេង គេលើកឡើងថា បើគ្មានថ្ងៃ ១៧ មេសា ១៩៧៥ ជាថ្ងៃជោគជ័យរបស់កុម្មុយនិស្ត ដែលដឹកនាំដោយយួន ហើយយួនលើកអំណាចអោយ **សីហនុ** និងខ្មែរដែលយួនបានបណ្តុះមនោគមន៍នយោបាយ ដើម្បីសំរេចផែនការប្រល័យពូជសាសន៍ខ្មែរ ហើយក៏គ្មាន ៧ មករា ១៩៧៩ ទេ។ ខាងក្រោមនេះ គឺជាឧទាហរណ៍ អំពីសង្គ្រាមនយោបាយ ដែលនិយាយអំពីផែនការយួនតាំងពីអតីតកាលមកដល់បច្ចុប្បន្ន។

ដោយសារតែភាពល្ងង់ខ្លៅរបស់មេដឹកនាំខ្មែរ ដែលគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន អំណាចបុណ្យស័ក្តិ លាភសក្ការៈ និងបក្សពួកនិយម បានបណ្តែតបណ្តោយអោយប្រទេសជាតិធ្លាក់ដុនដាបក្នុងភ្លើងសង្គ្រាមវិនាស ហិនហោច ខ្លោចផ្សារ ក្រោមល្បិចកលយួន។ ប្រទេសខ្មែរនឹងអាចឈានទៅរកការបាត់បង់ទឹកដី រលាយពូជ សាសន៍ នាពេលអនាគតដ៏ខ្លីខាងមុខ តាមនយោបាយត្រជាក់យួនដែលកំពុងប្រើ **ហ៊ុន សែន** អោយសម្លាប់ ជាតិខ្មែរសព្វថ្ងៃនេះ។ ផែនការនេះ ដូចផែនការយួនបំភ័ន្តសម្លាប់ខ្មែរក្នុងរបបខ្មែរក្រហម និងរបបរដ្ឋកម្ពុជា កន្លងមក។ ផែនការ ដែលយួនបានអនុវត្ត ចំពោះប្រទេសខ្មែរមានដូចខាងក្រោម :

១-ផែនការយួនបញ្ឆេះសង្គ្រាមសម្លាប់ខ្មែរនៅឥណ្ឌូចិន

២-ផែនការយួនសម្លាប់ខ្មែរដោយមនោគមន៍ក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ទៅ ឆ្នាំ១៩៧៩

៣-ផែនការយួនសម្លាប់ខ្មែរក្នុងរបប **ហេង សំរិន ហ៊ុន សែន** ពីឆ្នាំ១៩៧៩ ទៅ ឆ្នាំ ១៩៩៣

៤-ផែនការយួនប្រើ **ហ៊ុន សែន** សម្លាប់ខ្មែរក្នុងរបបព្រះរាជាណាចក្រក្លែងក្លាយពីឆ្នាំ១៩៩៣ រហូតមក ដល់ សព្វថ្ងៃនេះមាន ៣ សំខាន់ៗ:

ក-**យួនសម្លាប់ផ្នែកសេដ្ឋកិច្ច** គឺធ្វើអោយប្រជាពលរដ្ឋខ្មែរ ក្រីក្រ អត់ឃ្លាន រហូតដល់ស្លាប់។

ខ-**យួនសម្លាប់ផ្នែកគំនិត** និង **ស្មារតី** គឺធ្វើអោយប្រជាពលរដ្ឋខ្មែរ ល្ងង់ខ្លៅ គ្មានគំនិតជាតិ និយម ខ្លាច បាក់ស្បាត អស់សង្ឃឹមក្នុងការរស់នៅ ប្រៀបដូចជាកង្កែបនៅក្នុងអណ្តូងតាម ការបំពាក់ បំប៉នមនោគមវិជ្ជាយួន។

គ-**សម្លាប់ជីវិតខ្មែរ** តាមរបៀបប្រយោលថ្មី។

**១-ផែនការយួនបញ្ឆេះសង្គ្រាមសម្លាប់ខ្មែរនៅឥណ្ឌូចិន**

ចាប់ពីឆ្នាំ១៩២០ យួនបានរៀបចំផែនការដើម្បីលេបយកទឹកដីខ្មែរ ដំបូងឡើយយួនបានបង្កើតបក្ស កុម្មុយនិស្ត វៀតណាម ហើយក្រោយមកទៀតយួនបានបង្កើតសហព័ន្ធឥណ្ឌូចិន ដែលមានប្រទេស ខ្មែរ វៀតណាម ឡាវ នៅឆ្នាំ ១៩៣០ ដើម្បីពង្រីកឥទ្ធិពលកុម្មុយនិស្តនៅតំបន់ឥណ្ឌូចិន។ បន្ទាប់មក យួនបានដណ្តើមយក ទឹកដីកម្ពុជាក្រោម នៅឆ្នាំ ១៩៤៩ តាមល្បិចកលរបស់ពួកគេ ដែលធ្វើអោយបារាំងកាត់ទឹកដីខ្មែរក្រោមចំនួន ២១ ខេត្ត អោយយួនក្នុង **រាជ្យ ស្តេច សីហនុ** ជាអ្នកគ្រងរាជ្យនៅប្រទេសខ្មែរ។

ក្រោយពីយួនបានសំរេចយកបានទឹកដីកម្ពុជាក្រោមបានហើយ យួនបានបន្តផែនការលេបយកទឹកដីខ្មែរ សព្វថ្ងៃនេះបន្តទៀត។ នៅឆ្នាំ១៩៥០ យួនបានចាប់យកកូនក្មេងខ្មែរតូចៗ ទៅបំពាក់បំប៉នមនោគមវិជ្ជាចំនួន ៤០០០ នាក់ ដើម្បីមកបំពេញផែនការសម័យខ្មែរក្រហម អោយសម្លាប់ខ្មែរ បំភ័ន្តមតិជាតិ និងអន្តរជាតិ អោយយល់ច្រឡំថា ខ្មែរសម្លាប់ខ្មែរ។ ក្រោយមក យួនបានបញ្ឆេះសង្គ្រាមឥណ្ឌូចិនផ្ទុះឡើង ដើម្បីរុញសង្គ្រាម

នោះអោយធ្លាក់មកលើប្រទេសខ្មែរ បង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋខ្មែរ ធ្វើអោយប្រជាពលរដ្ឋខ្មែរស្លូតត្រង់បានស្លាប់អស់ ចំនួន ៦០០ ០០០ នាក់ ក្នុងសង្គ្រាម រវាងយៀកណាមខាងជើង និងយៀកណាមខាងត្បូង។ នៅពេលនោះ យួនខាងជើងបានធ្វើសង្គ្រាមជាមួយយួនខាងត្បូង ទឹសដៅរបស់វាគឺតែមួយដូចគ្នាសំដៅមកលេបយកទឹកដីកម្ពុជាសព្វថ្ងៃ។ យួនបានប្រើល្បិចបោកប្រាស់ **ស្តេចសីហនុ** សុំដាក់មូលដ្ឋានទ័ពយៀកកុងនៅតាមបណ្តោយ ព្រំដែនខ្មែរ ក្នុងខេត្ត ៥ គឺខេត្តរតនៈគីរី មណ្ឌលគីរី ក្រចេះ កំពង់ចាម ស្វាយរៀង និងដឹកអាវុធស្បៀង តាមច្រកក្រុងព្រះសីហនុ កាត់តាមកំពង់ស្ពឺ រហូតដល់ខេត្តកំពត ដើម្បីធ្វើសង្គ្រាមនៅលើទឹកដីខ្មែរ បណ្តាលអោយប្រទេសខ្មែរបាត់បង់អព្យាក្រិត្យភាព អធិបតេយ្យភាព និងសន្តិភាព ។

